# កិច្ចប្រជុំក្រុមពិគ្រោះយោបល់ឆ្នាំ ២០០២
# នៅប្រទេសកម្ពុជា

## *វិភាគទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ីចំពោះ*
## *ការពិភាក្សាលើគោលនយោបាយ*

ភ្នំពេញ

ថ្ងៃទី ១៩-២១ ខែ មិថុនា ឆ្នាំ ២០០២

## ADB DISCLAIMER FOR TRANSLATED DOCUMENTS

This document has been translated from English in order to reach a wider audience. However, English is the official language of the Asian Development Bank and the English original of this document is the only authentic (that is, official and authoritative) text. Any citations must refer to the English original of this document.

## សេចក្ដីអះអាងរបស់ ADB ចំពោះឯកសារបកប្រែនេះ

ឯកសារនេះត្រូវបានបកប្រែចេញពីភាសាអង់គ្លេស ដើម្បីផ្សព្វផ្សាយដល់សវនកៈឱ្យកាន់តែទូលំទូលាយ ។ ប៉ុន្តែភាសាអង់គ្លេស គឺជាភាសាផ្លូវការរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និង ឯកសារដើមជាភាសាអង់គ្លេសនៃឯកសារនេះ គឺជាអត្ថបទត្រឹមត្រូវតែមួយគត់ (មានន័យថា ជាឯកសារផ្លូវការនិងអាចយកជាការបាន)។ ការស្រង់ចេញនានាត្រូវតែយោងទៅលើឯកសារដើមជាភាសាអង់គ្លេស ។

# តារាងមាតិកា

ទិដ្ឋភាពរួមផ្នែកម៉ាក្រូសេដ្ឋកិច្ច និងសារពើពន្ធ

សំណៅពិភាក្សាលើផ្នែកគោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី

- អភិបាលកិច្ច និងកំណែទំរង់រដ្ឋបាលសាធារណៈ
- ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព
- បញ្ហានានានិងបញ្ហាប្រឈមនៅក្នុងការធ្វើវិមជ្ឈការ
- ស្ថានភាពនៃយុទ្ធសាស្ត្រជាតិក្នុងការកាត់បន្ថយភាពក្រីក្រ
- ការអនុវត្តន៍លំនាំថ្មីនៃភាពជាដៃគូ

ឯកសារបោះផ្សាយថ្មីៗរបស់ធនាគារអភិវឌ្ឍន៍អាស៊ី

## កិច្ចប្រជុំក្រុមពិគ្រោះយោបល់ឆ្នាំ ២០០២ នៅប្រទេសកម្ពុជា
## *ពតិមានទូទៅផ្នែកម៉ាក្រូសេដ្ឋកិច្ច និងសារពើពន្ធ*

ធនាគារអភិវឌ្ឍន៍អាស៊ីសូមចាប់ផ្តើមដោយការលើកសរសើររាជរដ្ឋាភិបាលកម្ពុជា (រដ្ឋាភិបាល)ចំពោះជោគជ័យជាបន្តបន្ទាប់នៅក្នុងការរក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច កំណើនសេដ្ឋកិច្ចជាបន្ត និងចំពោះការរក្សាបាននូវវិន័យសារពើពន្ធ។ ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចត្រូវបានពង្រឹងបន្ថែមទៀតដោយការថែរក្សាស្ថេរភាពនយោបាយ ការគ្រប់គ្រងគោលនយោបាយសារពើពន្ធ និងរូបិយវត្ថុបានល្អ និងការអនុម័តនូវយុទ្ធសាស្រ្តវិស័យនៃការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០០១-២០១០ ។ ទាក់ទងនឹងផ្នែកសារពើពន្ធ មានការរីកចំរើនក្នុងការគ្រប់គ្រងថវិកានិងវិធានការថ្មីៗដែលត្រូវបានដាក់អោយមានសំដៅអោយប្រមូលបាននូវប្រាក់ចំណូល។ ទាក់ទងនឹងផ្នែករូបិយវត្ថុវិញ រដ្ឋាភិបាលបានអនុវត្តដោយជោគជ័យនូវកម្មវិធីផ្តល់អាជ្ញាប័ណ្ណសារជាថ្មីចំពោះធនាគារ។ ជាលទ្ធផលនៃគោលនយោបាយសារពើពន្ធ និងរូបិយវត្ថុប្រុងប្រយ័ត្ន អត្រាអតិផរណាត្រូវបានរក្សាអោយមានតួលេខមួយខ្ទង់ ហើយអត្រាប្តូរប្រាក់នៃប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកមានស្ថេរភាពនៅក្នុងរយៈពេលបីឆ្នាំចុងក្រោយ។ គំរោងចូលទៅកាន់ អង្គការពាណិជ្ជកម្មពិភពលោក (WTO)នឹងពង្រឹងសេដ្ឋកិច្ចពិភពលោក នឹងពង្រឹងសមាហរណកម្មទៅក្នុងសេដ្ឋកិច្ចពិភពលោក ក៏ដូចជានឹងបង្កើនការចូលរួមទៅក្នុងសមាគមប្រជាជាតិនៅអាស៊ីអគ្នេយ៍ (ASEAN)និងទៅក្នុងកម្មវិធីសហប្រតិបត្តិការសេដ្ឋកិច្ចក្នុងមហាតំបន់អនុមេគង្គ(GMS)។

លទ្ធផលម៉ាក្រូសេដ្ឋកិច្ចជាកំណើនសេដ្ឋកិច្ចនៅមានភាពរឹងមាំ ទោះបីជាមានគ្រោះទឹកជំនន់នៅឆ្នាំ ២០០០ និង ២០០១ និងទោះជាមានការប្រែប្រួលបរិស្ថាននៅក្នុងតំបន់និងនៅក្នុងពិភពលោកក្តី។ កំណើនដែលផ្អែកលើពតិមានចុងក្រោយបំផុតពីវិទ្យាស្ថានជាតិស្ថិតិ មានកំរិតខ្ពស់ជាងអ្វីដែលបានគិតទុកពីមុន ដោយសារការរីកចំរើនលើវិស័យកាត់ដេរសំលៀកបំពាក់និងទេសចរណ៍។ យើងសូមអបអរសាទររដ្ឋាភិបាលចំពោះសមិទ្ធិផលនេះ។ យើងនូវបន្តទទួលការលើកទឹកចិត្តពីការប្តេជ្ញាដ៏មុឹងម៉ាត់របស់រដ្ឋាភិបាលចំពោះកំណែទំរង់ផ្សេងៗដែលចាំបាច់សំរាប់ធានាអោយមានកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព រាប់ទាំងផ្នែកដ៏លំបាកនៃអភិបាលកិច្ច និងការប្តេជ្ញាសារជាថ្មីចំពោះការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ។

ប៉ុន្តែទោះបីជាមានសមិទ្ធិផលដ៏គួរអោយចាប់អារម្មណ៍នេះក្តី រដ្ឋាភិបាលនៅបន្តប្រឈមមុខជាមួយបញ្ហាប្រឈមដ៏ច្រើនសន្ធឹកសន្ធាប់ក្នុងរយៈពេលខ្លី និងរយៈពេលវែង។ តថភាពអាក្រក់មិនអាចត្រូវបានបំភ្លេចនោះទេ។

**ពតិមានជាក់ស្តែងមួយចំនួនអំពីសេដ្ឋកិច្ចនិងសារពើពន្ធជាមូលដ្ឋាន**

- ពលរដ្ឋកម្ពុជាប្រមាណជា ៣៦% រស់នៅពឹងផ្អែកលើប្រាក់ចំណូលក្រោមបន្ទាត់នៃភាពក្រីក្រ។ ផ្អែកលើតួលេខស្ថិតិថ្មីៗបានអោយដឹងថា ផលិតផលសង្គមសរុបសំរាប់មនុស្សម្នាក់ (ថ្លៃស្ថេរឆ្នាំ ១៩៩៣) គិតជាប្រាក់រៀល បានកើនឡើង ១២% ក្នុងរយៈពេលពីឆ្នាំ ១៩៩៣ ដល់ឆ្នាំ ២០០១។ ជាដុល្លារអាមេរិក ផលិតផលសង្គមសរុបសំរាប់មនុស្សម្នាក់បានកើនឡើងកាលពីពេលថ្មីៗនេះពី ១៨១ ដុល្លារនៅឆ្នាំ ១៩៩៨ ដល់ ១៩៧ ដុល្លារនៅឆ្នាំ ២០០១។ តាមពិត តួលេខប៉ាន់ស្មានបានបង្ហាញថា មានការធ្លាក់ចុះផលិតផលសង្គមសរុបសំរាប់មនុស្សម្នាក់ពីកំរិតខ្ពស់គឺ ២៨៩ ដុល្លារនៅឆ្នាំ ១៩៩៥ មកកំរិតទាបបំផុតចំនួន ១៨១ ដុល្លារ នៅឆ្នាំ ១៩៩៨។ ការធ្លាក់ចុះនេះបណ្តាលមកពីការធ្លាក់ចុះយ៉ាងច្រើននៃកំណើនសេដ្ឋកិច្ចនៅឆ្នាំ ១៩៩៦ ដល់ ១៩៩៨ ជាសំខាន់គឺដោយសារវិបត្តិសេដកិច្ចក្នុងតំបន់ រួមជាមួយវិបត្តិនយោបាយក្នុងប្រទេសនៅឆ្នាំ ១៩៩៧ ។ ក្រៅពីនេះក៏ដោយសារកំណើនប្រជាជនដ៏លឿន និងការធ្លាក់ចុះនូវតំលៃប្រាក់រៀលធៀបនឹងដុល្លារ។ ផលិតផលសង្គមសរុបសំរាប់មនុស្សម្នាក់នៅឆ្នាំ ២០០១ ពុំមែនគ្រាន់តែមានកំរិតទាបជាងគេបំផុតនៅក្នុងតំបន់នោះទេ ប៉ុន្តែវាមានតំលៃមិនដល់ ៧០% ធៀបនឹងផលិតផលសង្គមសរុបសំរាប់មនុស្សម្នាក់នៅឆ្នាំ ១៩៩៥។ (តារាងទី ១ ខាងក្រោម ស្តីពីតួលេខផលិតផលសង្គមសរុបប៉ាន់ស្មាន)។
- ភាពក្រីក្រនៅគ្របដណ្តប់នៅឡើយ លើតំបន់ជនបទ ដែលមានប្រជាពលរដ្ឋរស់នៅប្រមាណជា ៩០%។ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ កំណើនសេដ្ឋកិច្ចនៅមានកំរិតយឺតនៅក្នុងផ្នែកកសិកម្ម ដែលសកម្មភាពសេដ្ឋកិច្ចនៃវិស័យនេះមានសក្តានុពលធំជាងគេក្នុងការរួមវិភាគទានក្នុងការលើកកំពស់គុណភាពនៃការរស់នៅនៃប្រជាពលរដ្ឋក្រីក្រ។ ជាងនេះទៅទៀត ផែនការប្រាំឆ្នាំលើកទីមួយពីឆ្នាំ ១៩៩៦-២០០០ បានដាក់នូវមុខសញ្ញាវិនិយោគក្នុងកំរិត ៦៥/៣៥ នៃការវិនិយោគលើតំបន់ជនបទធៀបនឹងតំបន់ទីក្រុង។ ផ្ទុយទៅវិញ ការអនុវត្តន៏ជាក់ស្តែងមានលក្ខណៈផ្ទុយពីនេះទៅវិញទេ ដូចមានបញ្ជាក់នៅក្នុងការពិនិត្យលើលឡើងវិញនៃផែនការប្រាំឆ្នាំលើកទីមួយ ពីឆ្នាំ ១៩៩៦-២០០០។
- សូចនាករផ្នែកសង្គមរបស់ប្រទេសកម្ពុជាបង្ហាញអោយឃើញថា ប្រទេសនេះមានភាពក្រីក្រជាងបណ្តាប្រទេសនៅអាស៊ីអគ្នេយ៏ដទៃទៀត។ មានប្រជាពលរដពេញវ័យតែ ៦៥% តែប៉ុណ្ណោះដែលជាអក្ខរជន (ធៀបនឹងប្រទេសវៀតណាម ៩៤% និងហ្វីលីពីន ៩៥%។នៅប្រទេសកម្ពុជា ស្ត្រី

គ្មានលទ្ធណៈអំណោយផលដូចនៅប្រទេសដទៃទៀតនៅក្នុងតំបន់ឡើយ។ ដើម្បីជាការបង្ហាញឱ្យឃើញកាន់តែច្បាស់ នៅប្រទេសកម្ពុជាការចុះឈ្មោះចូលរៀនរបស់សិស្សជាស្ត្រីនៅសាលា

**តារាងទី ១: ផលិតផលក្នុងស្រុកសរុបរបស់កម្ពុជា និងផលិតផលក្នុងស្រុកគិតសំរាប់មនុស្សម្នាក់ៗ (គិតលើមូលដានថ្លៃស្ថេរឆ្នាំ ១៩៩៣)**

| បរិយាយ | 1993 | 1994 | 1995 | 1996 | 1997 | 1998 | 1999 | 2000 | 2001 |
|---|---|---|---|---|---|---|---|---|---|
| ផសស ជាពាន់លានរៀល | 6,545 | 7,047 | 7,464 | 7,808 | 8,143 | 8,318 | 8,889 | 9,570 | 10,171 |
| អត្រាកំណើន % | | 7,7 | 5,9 | 4,6 | 4,3 | 2,1 | 6,9 | 7,7 | 6,3 |
| ផសស សំរាប់មនុស្សម្នាក់ៗ គិតជាពាន់រៀល | 691 | 708 | 713 | 708 | 700 | 683 | 711 | 748 | 774 |
| អត្រាកំណើន % | | 2,5 | 0,7 | -0,7 | -1,1 | -2,4 | 4,2 | 5,0 | 3,7 |
| | | | | | | | | | |
| ផសស ជាលានដុល្លារអាមេរិក | 2,382 | 2,742 | 3,026 | 2,957 | 2,723 | 2,204 | 2,331 | 2,480 | 2,592 |
| អត្រាកំណើន % | | 15,1 | 10,3 | -2,3 | -7,9 | -19,0 | 5,7 | 6,4 | 4,5 |
| ផសស សំរាប់មនុស្សម្នាក់ៗ គិតជាដុល្លារអមេរិក | 251 | 275 | 289 | 268 | 234 | 181 | 186 | 193 | 197 |
| អត្រាកំណើន % | | 9,5 | 4,9 | 7,3 | -12,7 | -22,7 | 3,1 | 3,7 | 2,0 |
| | | | | | | | | | |
| ការប្រើប្រាស់ចុងក្រោយរបស់គ្រួសារ | | | | | | | | | |
| ចំណាយ (HFCE) | 6,545 | 6,569 | 6,831 | 6,978 | 6,923 | 7,083 | 7,354 | 7,511 | 7,675 |
| HFCE សំរាប់មនុស្សម្នាក់ គិតជាពាន់រៀល | 691 | 660 | 652 | 632 | 595 | 581 | 588 | 586 | 584 |
| HFCE សំរាប់មនុស្សម្នាក់ក្នុងមួយខែ គិតជារៀល | 57,571 | 54,998 | 54,367 | 52,700 | 49,562 | 48,436 | 49,014 | 48,804 | 48,644 |
| | | | | | | | | | |
| ចំនួនប្រជាជនគិតត្រឹមខែកក្កដា គិតជាលាននាក់ | 9,474 | 9,954 | 10,470 | 11,034 | 11,640 | 12,186 | 12,503 | 12,825 | 13,148 |
| (តួលេខប៉ាន់ស្មានផ្អែកលើជំរឿនប្រជាជនរបស់វិទ្យាស្ថានជាតិស្ថិតិ ខែ មករា ឆ្នាំ ១៩៩៨) | | | | | | | | | |
| អត្រាប្តូរប្រាក់ផ្លូវការ (រៀលក្នុងមួយដុល្លារអាមេរិក) | 2,747 | 2,570 | 2,467 | 2,640 | 2,991 | 3,774 | 3,814 | 3,859 | 3,924 |
| (អត្រាទិញលក់ជាមធ្យមភាគ) | | | | | | | | | |

ប្រភព: វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ-រាជរដ្ឋាភិបាលនៃកម្ពុជា-*ប្រឹត្តបត្តិលេខ ៦ ស្តីពី* *គណនីជាតិនៃកម្ពុជា ឆ្នាំ ១៩៩៣-២០០១* ដែលបោះផ្សាយនៅខែឧសភាឆ្នាំ ២០០២

មធ្យមសិក្សាមានចំនួនតែ ៥៩% នៃសិស្សប្រុសតែប៉ុណ្ណោះ ដែលតួលេខនេះនៅប្រទេសវៀតណាមមាន ៩៣% និងនៅហ្វីលីពីមាន ១០២%។ អត្រាមរណៈប្រមាណនៅកម្ពុជាមានកំរិតខ្ពស់ ហើយជីវិតរស់នៅជាមធ្យមគឺមានរយៈតែ ៥៤ ឆ្នាំតែប៉ុណ្ណោះ ដែលតួលេខនេះធៀបនឹងប្រទេសវៀតណាម និងហ្វីលីពីនគឺ ៦៨ ឆ្នាំ។

- ចំណូលពន្ធគិតជាភាគរយនៃ ផសស នៅមានកំរិតទាមជាងគេនៅក្នុងតំបន់ គឺមានប្រមាណជា ៨,៤% តែប៉ុណ្ណោះនៅឆ្នាំ ២០០១ ហើយចំណូលសរុបមានប្រមាណជា ១១,៧%។ អាស្រ័យហេតុនេះ ប្រទេសកម្ពុជាគ្មានលទ្ធភាពធ្វើហិរញ្ញប្បទានលើការងារវិនិយោគចាំបាច់ ដើម្បីស្តារ និងកែលំអហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងលើកកំពស់គុណភាពនិងបរិមាណនៃការរស់នៅនៃមូលធនមនុស្សនៃប្រទេសនេះបានឡើយ។ ជាក់ស្តែងគំរោងហេដ្ឋារចនាសម្ព័ន្ធទាំងអស់របស់ប្រទេសកម្ពុជាដំណើរការដោយមានការធ្វើហិរញ្ញប្បទានតាមរយៈប្រាក់កំចី ឬក៏ដោយសារទំរង់ដទៃទៀតនៃជំនួយអភិវឌ្ឍន៍។

ការបញ្ចប់នូវផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចលើកទីពីរ ២០០១-២០០៥ (SEDP II) ធ្វើជា*ផែនការយុទ្ធសាស្ត្រដើម្បីអោយសំរេចបាននូវកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ* គឺជាជំហានឆ្ពោះទៅមុខដ៏មានសារៈសំខាន់។ យុទ្ធសាស្ត្រនេះមានគោលដៅបីយ៉ាងៈ (i) កំណើនសេដ្ឋកិច្ចរយៈពេលវែងនិងមានចីរភាពក្នុងកំរិត ៦-៧% ក្នុងមួយឆ្នាំ ( ii ) ការអភិវឌ្ឍន៍សង្គម និងវប្បធម៌ ឆ្ពោះទៅរកការបែងចែកប្រាក់ចំណូលអោយមានសមធម៌នៅថ្នាក់ជាតិ រវាងជនបទនិងទីក្រុង និងរវាងបុរសនិងស្ត្រី និង ( iii ) ការប្រើប្រាស់ធនធានធម្មជាតិអោយមានចីរភាពនិងការការពារបរិដ្ឋាន។ សរសរគ្រឹះទាំងបីនេះមានមូលដ្ឋាននៅលើកំណែទំរង់អភិបាលកិច្ចទូលាយនៅក្នុងផែនការសកម្មភាពស្តីពីអភិបាលកិច្ច ( GAP)។ គោលដៅចំបងសព្វថ្ងៃគឺជាការអនុវត្តន៍អោយមានប្រសិទ្ធភាពនូវគោលនយោបាយសេដ្ឋកិច្ច និងកម្មវិធីកំណែទំរង់ដែលមានចែងនៅក្នុង SEDP II និង GAP។ ក្នុងន័យនេះ កថាខ័ណ្ឌខាងក្រោមលើកឡើងនូវការពិភាក្សាអំពីបញ្ហាប្រឈមមួយចំនួននៅក្នុងបំណងអោយមានការអភិវឌ្ឍន៍ប្រកបដោយចីរភាព។

**ឆ្ពោះទៅកាន់ការអភិវឌ្ឍន៍រហ័សនិងមាននិរន្តរភាពៈ បញ្ហាប្រឈម**

- **ការរក្សាស្ថេរភាពនយោបាយៈ** ការចុះហត្ថលេខាលើកិច្ចព្រមព្រៀង សន្តិភាពទីក្រុងប៉ារីសដែលប្រព្រឹត្តទៅនៅខែតុលាឆ្នាំ ១៩៩១ គិតមកទល់ឥលូវនេះ មានរយៈពេលជាង ១០ ឆ្នាំហើយ ។ អាស្រ័យដោយមានការឧបត្ថម្ភគាំទ្រពីអង្គការសហប្រជាជាតិ ការបោះឆ្នោតជាតិនាឆ្នាំ ១៩៩៣ បានចាប់បើនូវទំព័រប្រវត្តិសាស្ត្រថ្មីរបស់កម្ពុជា ហើយការបោះឆ្នោតជាតិបន្ទាប់មក នាឆ្នាំ ១៩៩៨ បាននាំមកនូវក្តីសង្ឃឹមសារជាថ្មីចំពោះនិតិសម្បទានិងការអភិវឌ្ឍន៍។ បច្ចុប្បន្នប្រទេសកម្ពុជាកំពុងមានមានភាពកក់ក្តៅចំពោះសន្តិភាពនិងស្ថេរភាព ដែលប្រទេសនេះមិនបានទទួលអស់រយៈពេលជិតបីទសវត្សរ៍មកហើយ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ភាពចលាចលផ្នែកនយោបាយនៅឆ្នាំ ១៩៩៤ និង ១៩៩៧ ពុំមែនមិនធ្វើអោយមានការខាតបង់នោះទេ។ កំណើនសេដកិច្ច ដែលជាអាវុធដ៏មានប្រសិទ្ធភាព សំរាប់ប្រយុទ្ធប្រឆាំងជាមួយភាពក្រីក្រ បានចាប់ផ្តើមធ្លាក់ចុះនៅឆ្នាំ ១៩៩៥ ហើយបន្តធ្លាក់មកដល់កំរិតទាបបំផុតនៅឆ្នាំ ១៩៩៨។ កំណើននេះមានកំរិតទាបជាងកំរិតដែលរដ្ឋាភិបាលបានគ្រោងទុកក្នុងកំរិត ៦-៧% ក្នុងផែនការប្រាំឆ្នាំលើកទីមួយទៅទៀត។ មេរៀនដ៏មានសារៈសំខាន់នៅក្នុងដំណាក់កាលប្រវត្តិសាស្ត្រនយោបាយរបស់កម្ពុជា គឺការរក្សាអោយមានសន្តិភាព និងស្ថេរភាពនយោបាយ គឺជា*លក្ខ័ខណ្ឌចាំបាច់*សំរាប់កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍន៍។ អាស្រ័យហេតុនេះជាការសំខាន់ណាស់ដែលថា ការបោះឆ្នោតជាតិលើកក្រោយ ដែលគ្រោងថានឹង

ប្រព្រឹត្តទៅនៅក្នុងខែកក្កដាឆ្នាំ ២០០៣ ត្រូវតែយ៉ាងណាអោយការបោះឆ្នោតនោះប្រព្រឹត្តទៅដោយសន្តិភាព និងស្ថិតក្នុងបរិយាកាសមានយុត្តិធម៌ និងមានស្ថេរភាពនយោបាយ ។

- **ធ្វើអោយមានកំណើនសេដកិច្ចដែលមានចីរភាព:** ដូចបានរៀបរាប់ពីខាងដើម ប្រភពចំបងនៃកំណើនសេដ្ឋកិច្ចគឺវិស័យកាត់ដេរសំលៀកបំពាក់និងទេសចរណ៍ ។ នៅក្នុងខណៈដែលវិស័យទាំងនេះ មានសារៈសំខាន់អំពីវិស័យខ្លួនឯង រដ្ឋាភិបាលទទួលស្គាល់ថាប្រភពនេះផ្តល់នូវមូលដ្ឋានផុយស្រួយដើម្បីធានាអោយមានកំណើនសេដកិច្ចជាបន្ត ។ នៅក្នុងវិស័យកាត់ដេរ កិច្ចព្រមព្រៀងសរសៃសំយោគចំរុះនឹងត្រូវបញ្ចប់នៅឆ្នាំ ២០០៥ ដែលប្រការនេះអាចមានបច្ច័យអវិជ្ជមានចំពោះវិស័យកាត់ដេរនៅកម្ពុជា ហើយជាការពិតណាស់វាក៏មានបច្ច័យអវិជ្ជមានផងដែរចំពោះប្រទេសមួយចំនួនទៀតនៅអាស៊ី ។ មានតំរូវការជាបន្ទាន់ចំពោះរដ្ឋាភិបាលនិងវិស័យឯកជន ក្នុងកិច្ចចាប់ផ្តើមពិចារណាអំពីវិធីដោះស្រាយចំពោះបច្ច័យអវិជ្ជមាននេះ ។ ប្រភពជាមូលដ្ឋានមួយទៀតនៃកំណើនសេដ្ឋកិច្ច គឺទេសចរណ៍ ដែលជោគជ័យនៃវិស័យនេះគេមិនអាចម្ចាស់ការបានទេ ។ ក្នុងខណៈដែលចំនួនមកដល់នៃអ្នកទេសចរបានកើនឡើងយ៉ាងច្រើន ក៏មានបញ្ហាប្រឈមមួយដូចគ្នាដែរគឺការគ្រប់គ្រងកំណើននេះ តែយ៉ាងណាកុំអោយវាមានបច្ច័យអវិជ្ជមានចំពោះការទាក់ទាញទេសចរ និងចំពោះបរិស្ថាន ហើយបន្តរូមវិភាគទានដ៏ពិតប្រាកដចំពោះសេដ្ឋកិច្ច ។ ធនាគារអភិវឌ្ឍន៍អាស៊ីបានផ្តល់នូវការគាំទ្រចំពោះការកសាងផែនការត្រឹមត្រូវនៃវិស័យទេសចរណ៍ក្នុងពេលកន្លងមក ហើយយើងទទូចអោយរដ្ឋាភិបាលអនុវត្តនូវវិធានការជាកាតព្វកិច្ចនានា ។
- **បង្កើនសមាហរណកម្មទៅក្នុងតំបន់និងទៅក្នុងពិភពលោក:** មានសញ្ញាវិជ្ជមានជាច្រើនស្តីអំពីមូលដ្ឋានដែលអាចធ្វើអោយការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជាមានដំណើរការល្អ ។ ដូចមានបញ្ជាក់ពីខាងដើម ប្រទេសកម្ពុជាបានទទួលមកវិញនូវកៅអីសហប្រជាជាតិ ហើយបានក្លាយជាសមាជិកមួយនៅក្នុងគ្រួសារនៃសមាគមអាស៊ាន ។ ការចូលទៅក្នុងអង្គការ WTO នឹងពង្រឹងបន្ថែមទៀតនូវសមាហរណកម្មទៅក្នុងសេដកិចពិភពលោក ។ ធនាគារអភិវឌ្ឍន៍អាស៊ីលើកទឹកចិត្តអោយរដ្ឋាភិបាលប្រឹងប្រែងជាបន្ត ដើម្បីធ្វើសមាហរណកម្មសេដ្ឋកិច្ចទៅក្នុងយន្តការសហប្រតិបត្តិការអនុតំបន់ ជាពិសេសគឺធ្វើសមាហរណកម្មទៅក្នុងអនុតំបន់នៃមហាទន្លេមេគង្គ (GMS) ។ យើងក៏លើកទឹកចិត្តរដ្ឋាភិបាលផងដែរ ចំពោះការស្ម័គចិត្តធ្វើជាម្ចាស់ផ្ទះក្នុងកិច្ចប្រជុំកំពូល GMS លើកដំបូងនៃថ្នាក់ដឹកនាំរដ្ឋ នៅក្នុងខែវិច្ឆិកា នាឆ្នាំនេះ ។ យើងសំលឹងឆ្ពោះទៅកិច្ចប្រជុំកំពូលដែលប្រកបដោយជោគជ័យ អមដោយលទ្ធផលនិងសកម្មភាពជាក់ស្តែងចំពោះការអភិវឌ្ឍន៍ដែលមានចីរភាពនិងសមធម៌នៃតំបន់នេះ ។

- **ការព្យាយាមដោះស្រាយអំពើពុករលួយៈ** បញ្ហាប្រឈមមួយដែលធនាគារអភិវឌ្ឍន៍អាស៊ីចង់ធ្វើការគូសបញ្ជាក់គឺ ការលើកកំពស់នៅក្នុងបរិស្ថានអភិបាលកិច្ច និងការលុបបំបាត់អំពើពុករលួយ។ យើងមានសេចក្តីរីករាយចំពោះដំណោះស្រាយសារជាថ្មីរបស់រដាភិបាលក្នុងការប្រឆាំងនឹងអំពើពុករលួយ ហើយព្យាយាមជំរុញអោយរដ្ឋបាលកែសំរួលវិធាននិងបទប្បញ្ញត្តិនានាអោយមានភាពសាមញ្ញ និងមានតំលាភាព។ លទ្ធកម្មសាធារណៈគប្បីអនុវត្តតាមសេចក្តីណែនាំឆ្នាំ ១៩៩៥ ស្តីអំពីលទ្ធកម្មទំនិញនិងសេវា ដែលរៀបរៀងដោយជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ ការអនុវត្តន៏នៃបណ្តាក្រសួងពាក់ព័ន្ធ ដែលចេញប្រកាសដោយគ្មានការរៀបចំផែនការ ឬគ្មានការទំនាក់ទំនង ធ្វើអោយប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះវិស័យឯកជន និងចំពោះតំរូវការនៃការពិនិត្យសារឡើងវិញក្នុងលក្ខណៈប្រញាប់។ ( **យោងកំណត់ហេតុពិភាក្សាគោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ស្តីពីអភិបាលកិច្ចនិងកំណែទំរងរដ្ឋបាលសាធារណៈ**)
- **ព្យាយាមបន្តគ្រប់គ្រងធនធានអោយមាននិរន្តរភាពៈ** ដោយសារការអភិវឌ្ឍន៍បានប្រព្រឹត្តទៅក្នុងល្បឿនលឿន ប្រទេសកម្ពុជាចាំបាច់ត្រូវធានាថានឹងគ្មានបច្ច័យអវិជ្ជមានទៅលើបរិស្ថានធម្មជាតិទេ។ ធនាគារអភិវឌ្ឍន៍អាស៊ីនឹងឯកភាពលើអាទិភាពចំពោះការកសាងសមត្ថភាពនិងការវិនិយោគក្នុងការគ្រប់គ្រងធនធានធម្មជាតិ រួមមានរុក្ខកម្ម ជលផល ដី និងធនធានទឹក។ ការផ្តោតជាចំបងនៃកម្មវិធីគឺបឹងទន្លេសាប ដើម្បីជួយពលរដក្រីក្រនៅជនបទអោយទ្រទ្រង់បាននូវជីវភាពរស់នៅ និងដើម្បីអភិរក្ស និងការពារបរិស្ថាន។ នៅក្នុងបរិបទនេះ ក្នុងឋានៈជាសហប្រធាននៃក្រុមការងារស្តីពីការគ្រប់គ្រងធនធានធម្មជាតិ ធនាគារអភិវឌ្ឍន៍អាស៊ីនឹងសហការយ៉ាងជិតស្និទ្ធជាមួយរដ្ឋាភិបាល និងជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីជំរុញនូវកំណែទំរង់លើគោលនយោបាយចាំបាច់នៅក្នុងវិស័យធនធានធម្មជាតិ ដើម្បីព្យាយាមគ្រប់គ្រងធនធានអោយមានចីរភាព។ ( *យោងកំណត់ហេតុពិភាក្សាគោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី អំពីការគ្រប់គ្រងធនធានធម្មជាតិអោយមាននិរន្តរភាព*)។
- **សំរួលអភិបាលកិច្ចវិមជ្ឈការៈ** កម្ពុជាក៏ដឹកនាំដោយជោគជ័យផងដែរចំពោះការបោះឆ្នោតឃុំ-សង្កាត់ កាលពីដើមឆ្នាំនេះ។ ការអភិវឌ្ឍន៍នេះនឹងសំរួលកិច្ចដំណើរការជាជំហាន១នៃការធ្វើវិមជ្ឈការ ហើយកែប្រែវិធីដែលគំរោងអភិវឌ្ឍន៍ត្រូវបានរៀបចំ និងអនុវត្ត ដោយមានការផ្តល់សិទ្ធិអំណាចដល់ទៅអោយអាជ្ញាធរមូលដ្ឋានសមស្របទៅតាមសមត្ថភាពរបស់ពួកគេ ក្នុងការគ្រប់គ្រងធនធាននានាអោយមានប្រសិទ្ធភាព។ ទោះបីជាយ៉ាងនេះក្តី ជាការសំខាន់ណាស់ដែលថានៅពេលណាដែលគំនិតផ្តួចផ្តើមអំពីការធ្វើវិមជ្ឈការធ្វើអោយការរំពឹងកើនឡើង។ ការរំពឹងទាំងនេះត្រូវបានគ្រប់គ្រងយ៉ាងម៉ត់ចត់ ហើយគ្មានចោទអំពីហានិភ័យណាចំពោះស្ថេរភាពនយោ-

បាយ និងម៉ាក្រូសេដកិច។ ( *យោងកំណត់ហេតុពិភាក្សាគោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី អំពីបញ្ហាប្រឈមនានានៅក្នុងការធ្វើវិមជ្ឈការ* )។

- **បង្កើត និងបងបរិស្ថានសំរាប់វិស័យឯកជនៈ** បញ្ហាប្រឈមមួយក្នុងចំណោមបញ្ហាប្រឈមធំៗ ចំពោះកម្ពុជា គឺធ្វើដូចម្តេចក្នុងការកសាងលើលទ្ធផលអនុវត្តនីរឹងមាំផ្នែកម៉ាក្រូសេដ្ឋកិច្ចនិងសារពើពន្ធ ដើម្បីជំរុញកំណើនសេដ្ឋកិច្ចអោយបានលឿន កាត់បន្ថយភាពក្រីក្រ និងលើកកំពស់កាលានុវត្តភាពចំពោះប្រជាពលរដ្ឋកម្ពុជាអោយទទួលផលពីការប្រែប្រួលយ៉ាងឆាប់រហ័ស និងការធ្វើសមាហរណកម្មទៅក្នុងសេដ្ឋកិច្ចពិភពលោក។ ប៉ុន្តែអត្រាកំណើនសមល្មមនិងថ្លៃទំនិញដែលមានស្ថេរភាពនៅមិនទាន់គ្រប់គ្រាន់នៅឡើយទេ ប្រសិនបើប្រជាពលរដ្ឋនៅមានសេចក្តីស្រេកឃ្លាន ដោយសារតែពួកគេគ្មានការងារដែលផ្តល់ប្រាក់កំរៃនោះ។ មានការលើកឡើងជាញឹកញយថាវិស័យឯកជនជាប្រភពវិស័យសំខាន់នៃកំណើនសេដ្ឋកិច្ច ហើយរដ្ឋាភិបាលក៏បានឯកភាពនឹងគំនិតនេះដែរ។ វិស័យឯកជនដែលមានសំណើរការល្អ មានសភាពរស់រវើក ជាកត្តាសំខាន់ជាសារវន្តដើម្បីធានាអោយមានកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ។ នៅក្នុងខណៈដែលមានការទទួលស្គាល់បែបនេះ ការបង្កលក្ខណៈ (ដូចជាក្រខ័ណ្ឌគ្រប់គ្រងនិងនិតិកម្ម) មានបញ្ហាប្រឈមជាច្រើន។ យើងបានទទួលការលើកទឹកចិត្តតាមរយៈការបង្កើតយន្តការសំរាប់ការជជែកពិភាក្សាជាទៀងទាត់រវាងរដ្ឋាភិបាលនិងផ្នែកឯកជន ហើយសំលឹងឆ្ពោះទៅកាន់ការពិភាក្សាស៊ីជំរៅបន្ថែមទៀត ដើម្បីអោយការពិភាក្សានោះឈានទៅរកដំណោះស្រាយក្នុងការទាក់ទាញការវិនិយោគបរទេសនិងវិនិយោគិនក្នុងស្រុក។
- **អភិវឌ្ឍមូលធនមនុស្សៈ** ដោយមានការឧបត្ថម្ភគាំទ្រយ៉ាងច្រើនពីបរទេស កម្ពុជាបានបង្កើនការចំណាយលើវិស័យអប់រំ និងសុខាភិបាល។ ចំណែកនៃការចំណាយលើវិស័យអប់រំនិងសុខាភិបាលបានកើនឡើងគួរអោយកត់សំគាល់នៅក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ។ ចំពោះវិស័យសុខាភិបាលគឺកើនពី ២.៨% នៅឆ្នាំ ១៩៩៨ ទៅ ៧.៨% នៅឆ្នាំ ២០០១ ហើយចំពោះវិស័យអប់រំគឺកើនពី ៦.៥% ទៅ ១២.៧%។ កិច្ចប្រឹងប្រែងរបស់រដាភិបាលក្នុងការចំណាយដោយងាកចេញពីចំណាយលើវិស័យការពារជាតិមកកាន់ចំណាយលើការអប់រំនិងសុខាភិបាល សមនឹងមានការទទួលស្គាល់។ យើងជឿជាក់ថាវិធានការទាំងនេះ ពុំមែនងាយស្រួលក្នុងការអនុវត្តនីនោះទេ ហើយសូមថ្លែងសរសើររដាភិបាលចំពោះសមិទ្ធិផលដ៏សំខាន់នេះ។ ឆ្លងតាមកម្មវិធីតាមវិស័យ និងឆ្លងតាមឥណទានគំរោងរបស់ខ្លួន ធនារគារអភិវឌ្ឍន៍អាស៊ី នឹងបន្តឧបត្ថម្ភគាំទ្រវិស័យសង្គមកិច្ចនានាដើម្បីអោយមាននិរន្តរភាព និងបង្កើនការប្តេជ្ញាក្នុងការអភ្សវឌ្ឍន៍ធនធានមនុស្សរបស់ប្រទេសកម្ពុជា។ ធនាគារអភិវឌ្ឍន៍អាស៊ីមានជំនឿថា ការអភិវឌ្ឍន៍មូលធនមនុស្សគប្បីចាត់ទុក

ថាជាស្នូលនៃកិច្ចប្រឹងប្រែងកាត់បន្ថយភាពក្រីក្រ។ (**យោងកំណត់ហេតុពិភាក្សាគោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី អំពីស្ថានភាពនៃយុទ្ធសាស្រ្តជាតិក្នុងការកាត់បន្ថយភាពក្រីក្រ**)។

- **វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្តៈ** ធនាគារអភិវឌ្ឍន៍អាស៊ីប្តេជ្ញាជួយរដ្ឋាភិបាលក្នុងកិច្ចប្រឹងប្រែងរបស់ខ្លួនដើម្បីស្តារនិងលើកកំពស់ហេដារចនាសម្ព័ន្ធរូបវន្ត។ ប៉ុន្តែទោះជាយ៉ាងនេះក្តី យើងនឹងមានលំអៀងឆ្ពោះទៅរកគំរោងហេដ្ឋារចនាសម្ព័ន្ធណាដែលមានបច្ច័យខ្ពស់និងដោយផ្ទាល់ទៅលើពលរដ្ឋក្រីក្រ ជាពិសេសគឺពលរដ្ឋក្រីក្រនៅតាមជនបទ។ គំរោងហេដ្ឋារចនាសម្ព័ន្ធដែលនឹងបង្កើនប្រសិទ្ធភាពនៃវិស័យកសិកម្ម នឹងបានទទួលអាទិភាពគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី។ ទាំងនោះរួមមានការផ្តល់លទ្ធភាពទៅកាន់ទីផ្សារនិងលទ្ធភាពអោយបានទទួលសេវាសង្គមតាមរយៈបណ្តាញផ្លូវថ្នល់ជាមូលដ្ឋាននិងផ្លូវលំនៅជនបទ ហើយជួយសំរួលការអភិវឌ្ឍន៍ការតភ្ជាប់ថាមពលអគ្គិសនី និងអគ្គិសនីភាវូបនីយកម្មនៅជនបទ សំដៅយកចិត្តទុកដាក់ដល់ការបង្កើតសហគ្រាសធុនតូចនិងមធ្យម។ ទោះជាយ៉ាងនេះក្តី ជាការសំខាន់ណាស់ដែលការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដែលកំពុងអនុវត្តត្រូវធ្វើការថែទាំអោយបានត្រឹមត្រូវ។ ឧទាហរណ៏ កាតព្វកិច្ចផ្នែកហិរញ្ញវត្ថុសំរាប់ថែទាំបណ្តាញផ្លូវសំខាន់ៗនិងផ្លូវលំ បច្ចុប្បន្ននេះមានក៏រិតពី ៣៥-៤០ លានដុល្លារក្នុងមួយឆ្នាំ។ អាស្រ័យហេតុនេះ ជាការសំខាន់ណាស់គំនិតផ្តួចផ្តើមត្រូវប្រកាន់យក ដើម្បីអភិវឌ្ឍន៍ប្រព័ន្ធថែទាំផ្លូវអោយបានល្អ ហើយអភិវឌ្ឍសមត្ថភាពនៅក្រសួងពាក់ព័ន្ធ។ ក្នុងន័យនេះ យើងមានសេចក្តីរីករាយនឹងឃើញវឌ្ឍនភាពរឹងមាំកើតបាននិងកំពុងមាននៅក្នុងជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។
- **ផ្សារភ្ជាប់ទំនាក់ទំនងរវាងគោលនយោបាយនិងការកសាងផែនការជាមួយថវិកានីយកម្មៈ** យើងគាំទ្រកិច្ចប្រឹងប្រែងក្នុងការផ្សារភ្ជាប់ទំនាក់ទំនងរវាងការកសាងផែនការ (SEDP II) ទៅនឹងថវិកាប្រចាំឆ្នាំនិងជាមួយក្របខ័ណ្ឌចំណាយរយៈពេលមធ្យម (MTEF) លើមូលដ្ឋានរំកិលបីឆ្នាំ។ គំនិតផ្តួចផ្តើមផ្នែកគោលនយោបាយនេះនឹងជួយអោយធនធានថវិកាដែលមានក៏រិតត្រូវបានបែងចែកស្របទៅតាមលំដាប់អាទិភាព ដូចដែលបានចែងនៅក្នុងគោលដៅអភិវឌ្ឍន៍រយៈពេលមធ្យមនិងនៅក្នុងឯកសារយុទ្ធសាស្រ្ត។ MTEF អាចត្រូវបានប្រើសំរាប់បង្ហាញអោយឃើញនូវតំលៃឱកាសនៃគោលនយោបាយនិងកម្មវិធីនានា។ ទាក់ទងនឹងចំណុចនេះធនាគារអភិវឌ្ឍន៍អាស៊ីគាំទ្រនូវគំនិតផ្តួចផ្តើមថ្មីៗរបស់រដ្ឋាភិបាលដើម្បីធ្វើការពិនិត្យមើលឡើងវិញនូវចំណាយសាធារណៈ ដែលមានសារៈសំខាន់នៅក្នុងការពិនិត្យរកមើលនូវចំណាយសាធារណៈទៅលើអ្នកមានជីវភាព

ក្រខ្សត់។ (យោងកំណត់ហេតុពិភាក្សារបស់ធនាគារអភិវឌ្ឍន៍អាស៊ីអំពីការអនុវត្តន៍នៃលំនាំថ្មីនៃភាពជាដៃគូ)។

- **បង្កើនអត្រាសន្សំនិងអត្រាវិនិយោគៈ** គោលដៅម៉ាក្រូសេដ្ឋកិច្ចរបស់កម្ពុជាសំរាប់មុខសញ្ញារយៈពេលបីខាងមុខឆ្នាំកត់ត្រានូវការវិនិយោគក្នុងស្រុកខ្ពស់គិតជាភាគរយធៀបនឹង GDP គឺ ១៥.៥% នៅឆ្នាំ ២០០៣ ១៥.៩% នៅឆ្នាំ ២០០៤ និង ១៦.៤% នៅឆ្នាំ ២០០៥។ ប៉ុន្តែទោះជាយ៉ាងនេះក្តី អត្រាវិនិយោគសាធារណៈនឹងជួបឧបសគ្គដោយសារចំណូលពន្ធមានកំរិតទាប។ ធនាគារអភិវឌ្ឍន៍អាស៊ីនឹងគាំទ្រគំនិតផ្តួចផ្តើមបច្ចុប្បន្នក្នុងការបង្កើនចំណូលពន្ធ និងចំណូលមិនមែនពន្ធ តាមរយៈការគ្រប់គ្រងពន្ធ និងតាមរយៈការពង្រីកមូលដ្ឋានយកពន្ធ។ ប៉ុន្តែគន្លឹះនៃការបង្កើនប្រាក់សញ្ច័យ និងការវិនិយោគនៅក្នុងវិស័យឯកជន គឺតាមរយៈកំណែទំរង់ជាបន្តបន្ទាប់នៅក្នុងវិស័យហិរញ្ញវត្ថុ និងការកែលំអក្របខ័ណ្ឌគ្រប់គ្រងចំពោះវិស័យជាគន្លឹះ ដូចជាវិស័យថាមពល គមនាគមន៍ និងដឹកជញ្ជូនតាមរយៈវិធានច្បាប់ដែលអាចប៉ាន់ស្មានបាននិង ដែលមានតំលាភាព។ នៅក្នុងបរិបទនេះ ការអនុម័តនៃចក្ខុវិស័យកាលពីពេលថ្មីៗរបស់រដ្ឋាភិបាលចំពោះការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ គឺជាជំហានមួយបោះទៅកាន់ទិសដៅត្រឹមត្រូវ។ ជាការពិតណាស់ <u>ឥណទានកម្មវិធីលើវិស័យហិរញ្ញវត្ថុ</u>ត្រូវបានរៀបចំឡើងដើម្បីជួយប្រែក្លាយចក្ខុវិស័យនោះអោយទៅជាការពិត។

ជាការសន្និដ្ឋាន យើងសូមបញ្ជាក់ថាកំណែទំរង់គឺជាដំណើការនៃការកែប្រែ ដែលកំពុងបោះជំហានទៅមុខជាបណ្តើរៗ។ នៅពេលណាដែលឈុតមួយនៃគំនិតផ្តួចផ្តើមកំណែទំរង់ត្រូវបានបញ្ចប់ មានគំនិតផ្តួចផ្តើមមួយឈុតទៀតលេចឡើង។ ការគ្រប់គ្រងវិស័យសាធារណៈដែលមានប្រសិទ្ធភាព និងអភិបាលកិច្ចល្អធ្វើអោយមានវិធីសាស្រ្តមួយថេរ មានលក្ខណៈជាប្រព័ន្ធ សំរាប់ដាក់អោយមានកំណែទំរង់តាមបែបមួយទាន់ ឥពេលវេលានិងប្រព្រឹត្តទៅតាមលំដាប់លំដោយ។នៅក្នុងការប្រយុទ្ធប្រឆាំងជាមួយភាពក្រីក្រ ប្រការនេះតំរូវអោយមានការកសាងអោយមានស្ថេរភាពនូវសមត្ថភាពជាតិ នៅគ្រប់ថ្នាក់ ដើម្បីគ្រប់គ្រងដោយប្រុងប្រយ័ត្ននូវកម្មវិធីកំណែទំរង់នានានៅក្នុងវិស័យផ្សេងៗ និងនៅថ្នាក់ផ្សេងៗ ទាំងនៅផ្នែករដ្ឋាភិបាល ទាំងនៅក្នុងសង្គមស៊ីវិល។ ដៃគូអភិវឌ្ឍន៍ ដូចជាធនាគារអភិវឌ្ឍន៍អាស៊ីជាដើម មានមុខងារសំខាន់ណាស់នៅក្នុងកិច្ចប្រឹងប្រែងក្នុងការជួយរដ្ឋាភិបាល ដើម្បីនាំមកនូវតំរូវការលើកការកែប្រែចាំបាច់ តាមរយៈការកសាង

សមត្ថភាព និងតាមរយៈការអភិវឌ្ឍន៍ស្ថាប័ន ការគាំទ្រគោលនយោបាយនិងការពិភាក្សា និងនៅក្នុងកម្មវិធីផ្តល់ប្រាក់កំចី និងកម្មវិធីមិនផ្តល់ប្រាក់កំចី ។

អ្វីដែលបន្តនោះគឺកំណត់ហេតុពិភាក្សាគោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ស្តីពីប្រធានបទមួយចំនួនដែលត្រូវបានជ្រើសរើសសំរាប់ពិភាក្សារវាងដៃគូនានានៅក្នុងកិច្ចប្រជុំពិភាក្សាពិគ្រោះយោបល់នាពេលនេះ ។ យើងមានសេចក្តីរីករាយនឹងឃើញរាល់ប្រធានបទទាំងអស់នៃកិច្ចប្រជុំពិគ្រោះយោបល់នេះជាប្រធានបទស្តីពី *អភិបាលកិច្ចនិងការកាត់បន្ថយភាពក្រីក្រ*។ អាស្រ័យហេតុនេះ កំណត់ហេតុនៃការពិភាក្សាគោលនយោបាយរបស់យើងមានប្រធានបទនេះធ្វើជាចំណុចរួមដែលត្រូវពិភាក្សានៅក្នុងកិច្ចប្រជុំ ។ កិច្ចប្រជុំពិគ្រោះយោបល់នេះ ជាកិច្ចប្រជុំលើកដំបូងដែលត្រូវប្រព្រឹត្តទៅនៅប្រទេសកម្ពុជា ដែលតំណាងអោយកាលានុវត្តភាពតែមួយដើម្បីកសាងលើមូលដ្ឋាននៃសមិទ្ធិផលរយៈពេលមួយទសវត្សរ៍នៅក្នុងការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ច ។ យើងសង្ឃឹមថា វិភាគទានទាំងនេះនឹងជួយអោយមានការជជែកដេញដោលឆ្ពោះទៅរកបញ្ហាគោលនយោបាយអភិវឌ្ឍន៍សំខាន់ៗ ។ ក្នុងឋានៈជាដៃគូអភិវឌ្ឍន៍របស់កម្ពុជា ធនាគារអភិវឌ្ឍន៍អាស៊ីត្រៀមជាស្រេចក្នុងការបន្តការចូលរួមរបស់យើងលើបញ្ហាទាំងនេះ ហើយផ្តល់នូវការប្រឹក្សាចាំបាច់ ដែលស្នើឡើងដោយរដ្ឋាភិបាល ។

# អភិបាលកិច្ច
# និង
# កំណែទំរង់
# រដ្ឋបាលសាធារណៈ

# អភិបាលកិច្ច និងកំណែទំរង់រដ្ឋបាលសាធារណៈ

រដ្ឋាភិបាលកំពុងធ្វើអោយមានវឌ្ឍនភាពក្នុងការអនុវត្តន៍ *ផែនការសកម្មភាពអភិបាលកិច្ច* (GAP) ដោយមានការគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ីនិងពីដៃគូអភិវឌ្ឍន៍ដទៃទៀត។ លទ្ធផលដែលសំរេចបានមានជាអាទិ៍ ការបញ្ចប់នូវជំរឿនមន្ត្រីរាជការ និងការពិនិត្យមើលឡើងវិញមួយចំនួន ស្តីពីមុខងារ បង្កើតគ្រប់គ្រងបុគ្គលិក និងប្រព័ន្ធបើកប្រាក់បៀវត្សរ៍ដោយកុំព្យូទ័រ ការលុបបំបាត់បុគ្គលិកខ្មោច និងបុគ្គលិកជាន់ឈ្មោះពីបញ្ជីផ្តល់ប្រាក់បេវត្សរ៍ ក្របខ័ណ្ឌច្បាប់សំរាប់អភិបាលកិច្ចនៅថ្នាក់ខេត្ត ថ្នាក់ស្រុក និងថ្នាក់ឃុំ និងការបោះឆ្នោតឃុំក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងខែកុម្ភៈ ឆ្នាំ ២០០២។ រដ្ឋាភិបាលកំពុងប្រឹងប្រែងដើម្បីបង្កើនប្រាក់ចំណូល លើកកំពស់ការបើកប្រាក់ផ្តល់អោយវិស័យអាទិភាព ដូចជាសុខាភិបាល និងអប់រំ (ទោះបីជាមានមានការយឺតយ៉ាវជាបណ្តោះអាសន្នក្នុងរយៈពេលប្រាំមួយខែចុងក្រោយនេះក្តី) ហើយសង្ឃឹមថានឹងចាប់ផ្តើម *ក្រុមបេសកកម្មអាទិភាព* (PMGs) ដែលជាក្រុមបានទទួលការជ្រើសរើសដោយប្រយ័ត្នប្រយែង ដើម្បីអនុវត្តការងារដែលផ្អែកលើលទ្ធផល ជាថ្នូរចំពោះការលើកទឹកចិត្តនិងល័ក្ខខ័ណ្ឌការងារប្រសើរជាងមុន។ វឌ្ឍនភាពគួរអោយកត់សំគាល់ដែលបាននិងកំពុងអនុវត្តដោយ *អាជ្ញាធរសវនកម្មជាតិ* (NAA) ក្នុងការរៀបចំអោយមានការិយាល័យនិងបរិក្ខារ ជ្រើសរើសបុគ្គលិក ធ្វើការបណ្តុះបណ្តាល និងរៀបចំធ្វើសវនកម្មជាក់ស្តែងនៃរបាយការណ៍អនុវត្តថវិកាឆ្នាំ ២០០១ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ធនាគារអភិវឌ្ឍន៍អាស៊ីលើកសរសើររដ្ឋាភិបាល សភាជាតិ និងព្រឹទ្ធសភាជាតិដោយគាំទ្រចំពោះការអនុវត្តន៍ច្បាប់សវនកម្ម។ យោធិនប្រមាណជា ១៦.៥០០ នាក់ (ដំណាក់កាលសាកល្បងនៃជំហានទីមួយ ចំនួន ១៥.០០០ នាក់) ត្រូវបានរំសាយ។ ផែនទីត្រូវបានរៀបចំនៅក្រុងភ្នំពេញ និងនៅខេត្តចំនួនប្រាំ ហើយប័ណ្ណកម្មសិទ្ធដីធ្លីប្រមាណជា ២.០០០ ច្បាប់ ត្រូវបានចេញជូនពលរដ្ឋកម្ពុជា។

## វិធីសាស្ត្ររបស់ធនាគារអភិវឌ្ឍន៍អាស៊ីក្នុងការជំរុញអភិបាលកិច្ចល្អ

ធនាគារអភិវឌ្ឍន៍អាស៊ីគាំទ្រផែនការសកម្មភាពអភិបាលកិច្ច និងកម្មវិធីកំណែទំរង់រដ្ឋដោយមធ្យោបាយបួនយ៉ាងៈ

ទីមួយ ធនាគារអភិវឌ្ឍន៍អាស៊ីជួយលើគំនិតផ្តួចផ្តើមអភិបាលកិច្ចជាគន្លឹះ ដូចជា:

- គាំទ្រការធ្វើសេចក្តីព្រាងច្បាប់ស្តីពីសន្តិសុខសាធារណៈជនលើលទ្ធភាពទាញផលពីធនធានដីធ្លី ព្រៃ និងទឹក។
- គាំទ្រចំពោះការអនុវត្តដែលត្រូវបានលើកកំពស់លើថវិកាប្រចាំឆ្នាំ កម្មវិធីសកម្មភាពជាអាទិភាព និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និង
- គាំទ្រការអនុវត្តន៍ច្បាប់សវនកម្ម តាមរយៈការផ្តល់ការឧបត្ថម្ភគាំទ្រទៅអោយអាជ្ញាធរសវនកម្មជាតិដែលត្រូវបានបង្កើតក្នុងពេលថ្មីៗ ការពង្រឹងនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃបណ្តាក្រសួងនានា និងការឧបត្ថម្ភគាំទ្រចំពោះ <u>*គណៈកម្មការហិរញ្ញវត្ថុនិងធនាគារ*</u> នៃរដ្ឋសភា និងព្រឹទ្ធសភា ដែលទាំងអស់នេះនឹងដើរតួយ៉ាងសំខាន់ក្នុងការប្រយុទ្ធជាមួយអំពើពុករលួយជាទូទៅ ហើយបង្កើនតំលាភាពនិងគណនេយ្យភាព។

ទីពីរ ធនាគារអភិវឌ្ឍន៍អាស៊ីគាំទ្រដោយផ្ទាល់ចំពោះការអនុវត្តន៍វិមជ្ឈការ តាមរយៈការជួយក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិទ្រទ្រង់ឃុំ-សង្កាត់ (NCSC) លើការកសាងផែនការ និងសាងសង់មធ្យោបាយនានាសំរាប់ដំណើរការឃុំ-សង្កាត់ វិធានការកសាងសមត្ថភាពក្រុមប្រឹក្សា ទីភ្នាក់ងារទ្រទ្រង់ថ្នាក់ខេត្ត និងថ្នាក់ជាតិ ព្រមជាមួយសកម្មភាពពាក់ព័ន្ធផ្សេងៗអំពីបញ្ហាដីធ្លីនិងដែនសមត្ថកិច្ច។ យើងកំពុងធ្វើការជាមួយរដ្ឋាភិបាល និងជាមួយដៃគូដទៃទៀតក្នុងការផ្តល់ការគាំទ្រចាំបាច់ក្នុងការកំណត់មុខងារនិងតួនាទី ចំពោះថ្នាក់ផ្សេងៗនៃរដ្ឋាភិបាលចុះមកថ្នាក់ឃុំ-សង្កាត់ និងប្រព័ន្ធហិរញ្ញប្បទានវិមជ្ឈការ ការកសាងផែនការនិងការគ្រប់គ្រងដែលរលូន និងការរៀបចំបំពាក់ឧបករណ៍ និងបណ្តុះបណ្តាលបុគ្គលិកនៅគ្រប់ថ្នាក់ ក្នុងទស្សនៈវិស័យជំរុញប្រជាធិបតេយ្យ បង្កើនអោយប្រជាពលរដ្ឋសាមញ្ញមានឱកាសកាន់តែច្រើន និងអភិវឌ្ឍន៍ដែលមាននិរន្តរភាព តាមរយៈអភិបាលកិច្ចល្អ។

ទីបី យើងកំពុងធ្វើអោយប្រាកដថា គំរោងទាំងអស់មានភាពស៊ីសង្វាក់គ្នា ហើយពង្រឹងចំពោះកម្មវិធីកំណែទំរង់របស់រដ្ឋាភិបាល។ ឧទាហរណ៍ ការអនុវត្តន៍ <u>*កម្មវិធីអភិវឌ្ឍន៍វិស័យអប់រំ*</u> ត្រូវបានធ្វើអោយមានទំនាក់ទំនងជាមួយកំណែទំរង់ថវិកានីយកម្មនិងកំណែទំរង់ការគ្រប់គ្រងចំណាយ ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បញ្ញត្តិស្តីពីច្បាប់សវនកម្ម និងកំណែទំរង់លើការទូទាត់និងការផ្តល់ការងារតាមរយៈក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល (CAR)។ <u>*កម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្ម*</u> ដែលកំពុងត្រូវបានរៀបចំ នឹងអនុម័តតាមបែបដូចគ្នា។

ទីបួន យើងមានជំនឿថា ដំណើរការកំណែទំរង់មានផលប៉ះពាល់យ៉ាងច្រើនទៅលើទំនាក់ទំនងរវាងរដ្ឋ និងផ្នែកមិនមែនរដ្ឋ។ ជោគជ័យនឹងអាស្រ័យលើឆន្ទៈនយោបាយ និងការឧទ្ទិស ព្រមទាំងការចូលរួមដ៏សកម្មពីគ្រប់ស្ថាប័នទាំងអស់ នោះគឺ រដ្ឋាភិបាល សភាជាតិ និងព្រឹទ្ធសភា តុលាការ ការិយាល័យឯករាជ្យ ការិយាល័យធម្មនុញ្ញ សង្គមស៊ីវិល វិស័យឯកជន និងទីភ្នាក់ងារផ្តល់ជំនួយនានា។ មុខនាទីសំខាន់របស់ផ្នែកមិនមែនរដ្ឋ មានសភាពជាក់ច្បាស់ណាស់ក្នុងការផ្តល់សេវានិងហេដ្ឋារចនាសម្ព័ន្ធសំរាប់ការអភិវឌ្ឍន៍ជនបទ អភិវឌ្ឍន៍សុខាភិបាល និងអប់រំ។ អង្គការស៊ីវិលក៏មានមុខនាទីសំខាន់ផងដែរក្នុងការជំរុញការពិភាក្សាច្បាប់ថ្មីៗដែលសំខាន់សំរាប់ការកាត់បន្ថយភាពក្រីក្រ។ ទូទៅជាងនេះទៀតនោះ គឺការអនុវត្តន៍កំណែទំរង់រដ្ឋ អាស្រ័យលើការបង្កើតសភាទ្រទ្រង់ក្នុងលក្ខណៈទូលាយ និងការកសាងការឯកភាពគ្នារវាងដៃគូទាំងអស់។ ធនាគារអភិវឌ្ឍន៍អាស៊ីនឹងជួយប្រទេសកម្ពុជាអោយបង្កើតនិងរក្សាបាននូវនិរន្តរភាពនៃសម្ព័ន្ធភាពទ្រទ្រង់សំរាប់កិច្ចប្រឹងប្រែងកំណែទំរង់ តាមរយៈការជំរុញដំណើរការចូលរួមក្នុងការរៀបចំកសាងនិងការ អនុវត្តន៍គំរោងនិងកម្មវិធីអភិវឌ្ឍន៍នានា។

**មាគ៌ាឆ្ពោះទៅមុខ**

*១. ការកសាងសមត្ថភាពនិងការអភិវឌ្ឍន៍ស្ថាប័ន*

ចាំបាច់ត្រូវយកចិត្តទុកដាក់ចំពោះតំរូវការរបស់កម្ពុជាសំរាប់កសាងសមត្ថភាពនិងបណ្តុះបណ្តាល។ ជាលទ្ធផលនៃរបបប្រល័យពូជសាសន៍និងសង្គ្រាម ធនធានមនុស្ស និងសមត្ថភាពស្ថាប័នរបស់កម្ពុជា បានបាត់បង់យ៉ាងច្រើន។ នៅទសវត្សរ៍ទី ១៩៩០ គេឃើញមានកិច្ចប្រឹងប្រែងយ៉ាងច្រើនចំពោះសកម្មភាពជាច្រើន ចំពោះការកសាងឡើងវិញនូវសមត្ថភាពដែលបានបាត់បង់របស់កម្ពុជា។ ទោះបីជាមានការរួមវិភាគទាន ដែលថាមានការកសាងសមត្ថភាពក្តី ជាការច្បាស់ណាស់ដែលថានៅមានចំណុចជាច្រើនសំរាប់ធ្វើការអភិវឌ្ឍន៍បន្ថែមទៀត។ ដើម្បីធានាអោយមានប្រសិទ្ធភាពលើការគាំទ្រការកសាងសមត្ថភាពដែលកំពុងដំណើរការ ទីភ្នាក់ងារប្រតិបត្តិគំរោងអភិវឌ្ឍន៍ដែលបានទទួលហិរញ្ញប្បទានពីបរទេស និងដៃគូអភិវឌ្ឍន៍ត្រូវអនុម័តនូវវិធីសាស្ត្រមួយ ដែលកាន់តែមានលក្ខណៈជាប្រព័ន្ធ ដើម្បីកំណត់និងវាស់វែងនូវបំរែបំរួលរវាងលទ្ធផលអនុវត្តន៍របស់ទីភ្នាក់ងារប្រតិបត្តិធៀបនឹងលទ្ធផលរំពឹងទុក។ ក្នុងន័យនេះ ទីភ្នាក់ងារប្រតិបត្តិអាចរៀបចំរបាយការណ៍ស្តីពីលទ្ធផលអនុវត្តន៍ ដែលកំណត់អត្តសញ្ញាណបំរែបំរួលទៅតាមលំដាប់អាទិភាព ទៅតាមប្រភេទនៃបញ្ហាដែលមានឥទ្ធិពលលើបំរែបំរួល និងតួលេខប៉ាន់ស្មានអំពីអនុបាតជាផលធៀបរវាងចំណាយនិងលទ្ធផល (មានន័យថាចំណាយចាំបាច់ដើម្បីផលិតនូវផលិតផលណាមួយ)។ បំរែបំរួលខ្លះអាចបណ្តាលមកពីបញ្ហាផ្ទៃក្នុង (រចនាសម្ព័ន្ធចាត់តាំង

ការអនុវត្តន៍ នៃធនធានមនុស្ស ជំនាញមិនសមស្រប ប្រព័ន្ធពត៌មាន នីតិវិធីធ្វើកិច្ចសន្យា) ហើយអាចត្រូវបាន ដោះស្រាយដោយការកែប្រែផ្ទៃក្នុង។

លទ្ធផលដទៃទៀតអាចកើតចេញមកពីកត្តាផ្ទៃក្រៅ ដូចជាធនធានមិនគ្រប់គ្រាន់ ឬមិនអាចប៉ាន់ស្មានជាមុនបាន និងមិនសូវមានទំនាក់ទំនងជាមួយទីភ្នាក់ងារជាដៃគូ និងជាមួយភាគីពាក់ព័ន្ធដទៃ។ នៅក្នុងករណីដូចក្នុងចំណុចចុងក្រោយនេះ គប្បីមានការវាយតំលៃមួយពីអំពីទីភ្នាក់ងារប្រតិបត្តិលើ " សមត្ថភាពទំនាក់ទំនងអន្តរភ្នាក់ងារ" និងយថាទស្សន៍សំរាប់កែលំអចំណុចអសកម្មនោះ" ។

របាយការណ៏ស្តីពីលទ្ធផលអនុវត្តរបស់ទីភ្នាក់ងារប្រតិបត្តិអាចផ្តល់នូវការចាប់អារម្មណ៏ជាពិសេសចំពោះចំណុចខ្លាំងនិងចំណុចខ្សោយរបស់ពួកគេក្នុងការបំរើពលរដ្ឋក្រីក្រ។ បញ្ហាដែលត្រូវពិចារណារួមមានៈ តើគ្រួសារក្រីក្រត្រូវរង់ចាំអស់យូរដែរឬទេក្នុងការទទួលអត្ថប្រយោជន៏នានា ដែលមាននីតិវិធីរដ្ឋបាលស្មុគស្មាញ បន្ទុកលើអ្នកប្រើប្រាស់ដែលពួកគេគ្មានលទ្ធភាពបង់ថ្លៃ ឬការការពារដែលគ្មានសមធមិអំពីសិទ្ធតាមផ្លូវច្បាប់? តើកិច្ចប្រជុំជាសាធារណៈ តារាងពត៌មាននៅមូលដ្ឋាន ឬយន្តការសំដែងការកើតទុក្ខមិនសុខចិត្តដទៃទៀតត្រូវបានបង្កើត ដែលអនុញ្ញាតិអោយបានទទួលមតិយោបល់ពីពលរដ្ឋស្តីអំពីប្រសិទ្ធភាពនៃទីភ្នាក់ងារប្រតិបត្តិដែរឬទេ? មានសកម្មភាពណាខ្លះដែលទីភ្នាក់ងារប្រតិបត្តិបានប្រកាន់យក ដើម្បីឆ្លើយតបនឹងមតិយោបល់ទាំងនោះ?

ផ្អែកលើការវិភាគនេះ ទីភ្នាក់ងារប្រតិបត្តិ និងដៃគូអភិវឌ្ឍន៍ នឹងបង្កើតយុទ្ធសាស្រ្តកែប្រែនិងផែនការអនុវត្តន៏ ដើម្បីដោះស្រាយនូវការខុសគ្នាទាំងនេះ និងដើម្បីកាត់បន្ថយគំលាតរវាងលទ្ធផលអនុវត្តន៏ជាក់ស្តែងនឹងលទ្ធផលរំពឹងទុក។ យុទ្ធសាស្រ្តនិងផែនការនឹងត្រូវបានបង្ហាញជាបីផ្នែកៈ ក) បណ្តាធាតុដែលទីភ្នាក់ងារប្រតិបត្តិអាចអនុវត្តដោយខ្លួនឯង ខ) បណ្តាធាតុដែល ទីភ្នាក់ងារប្រតិបត្តិអាចមានឥទ្ធិពល ប៉ុន្តែមិនអាចអនុវត្តដោយខ្លួនឯង ដូចជាការកែលំអទំនាក់ទំនងអន្តរទីភ្នាក់ងារ និង គ) បណ្តាធាតុដែលទីភ្នាក់ងារប្រតិបត្តិមានបំណងលើកសរសើរ ប៉ុន្តែមិនអាចគ្រប់គ្រង ឬមានឥទ្ធិពល ដូចជាបរិបទម៉ាក្រូសេដ្ឋកិច្ចជាដើម។ ដើម្បីធ្វើបែបនេះ ដៃគូអភិវឌ្ឍន៍ និងរដ្ឋាភិបាលគប្បីពិចារណាលើការតំរូវអោយគំរោងឬកម្មវិធីនិមួយៗចាំបាច់ត្រូវមានលក្ខណៈវិនិច្ឆ័យលើលទ្ធផលអនុវត្តន៍ច្បាស់លាស់ និងមានលទ្ធផលជាក់ស្តែង ដែលជំរុញបន្ថែមនូវគណនេយ្យភាព តំលាភាព ភាពដែលអាចប៉ាន់ប្រមាណបាន និងការចូលរួមពីសាធារណជនក្នុងអភិបាលកិច្ច។

*២. ការកសាងនិងសំរបសំរួលគោលនយោបាយ*

មុខងារបង្កើតនិងសំរបសំរួលគោលនយោបាយជាមូលដ្ឋានគ្រឹះសំរាប់អោយរដ្ឋាភិបាលដំណើរការបាន ដោយស្រួល។ យន្តការដែលមានប្រសិទ្ធភាពសំរាប់បង្កើតនិងសំរបសំរួលគោលនយោបាយមានទំនាក់ទំនងជិត ស្និទ្ធជាមួយក្របខ័ណ្ឌពលនយោបាយដែលកាន់តែអាចប៉ាន់ស្មានទុកបាន មានបទប្បញ្ញត្តិកាន់តែល្អ មានអំពើពុករលួយកាន់តែតិច និងមានការគ្រប់គ្រងដោយច្បាប់កាន់តែរឹងមាំ។ កត្តាទាំងនេះមានបច្ច័យ យ៉ាងច្រើនទៅលើសហគ្រិនភាព ការវិនិយោគ និងប្រសិទ្ធភាពផ្នែករដ្ឋបាល ដែលទាំងអស់នេះតំរូវអោយ មានការណែនាំច្បាស់លាស់ និងមានសញ្ញាណនៃការដឹកនាំពីថ្នាក់ដឹកនាំជាន់ខ្ពស់។ នៅក្នុងបរិបទនេះ ផែនការបច្ចុប្បន្នរបស់រដ្ឋាភិបាលក្នុងការអនុវត្តន៏ការវិភាគមុខងារមានសារៈសំខាន់ខ្លាំងណាស់ និង អោយបានទាន់ពេលវេលា។ ទោះជាយ៉ាងនេះក្តី ការពិនិត្យមុខងារសារឡើងវិញ មិនគប្បីត្រូវបានមើលឃើញថាចប់តែត្រឹមនេះនោះទេ។ ក្រសួងនិងស្ថាប័ននានារបស់រដ្ឋាភិបាលអាចត្រូវបានច្របាច់បញ្ចូលគ្នា កែសំរួលរចនាសម្ព័ន្ធសារជាថ្មី និងត្រូវបានបង្កើត ប៉ុន្តែឥរិយាបថ (ហើយលទ្ធផលផ្នែករដ្ឋបាល ក៏គ្មានអ្វីប្រែប្រួលដែរ) នឹងគ្មានការផ្លាស់ប្តូរទេ លុះត្រាតែមានការកែប្រែជាមូលដ្ឋានលើវិធាន នីតិវិធី និងការលើកទឹកចិត្ត។ ឧទាហរណ៏ ការបង្កើតគណៈកម្មការប្រឆាំងនឹងអំពើពុករលួយទោលតែឯង អាចមានប្រសិទ្ធភាពតិចតួចប៉ុណ្ណោះ ក្នុងការលើកកំពស់ភាពសុចរិតសាធារណៈ វៀរលែងតែមានការកែប្រែក្របខ័ណ្ឌនៃការទទួលប្រាក់រង្វាន់ឬទណ្ឌកម្ម។

*៣. អំពើពុករលួយ*

គេបានឯកភាពគ្នាជាទូទៅថា អំពើពុករលួយគឺជាឧបសគ្គចំបងចំពោះកិច្ចប្រឹងប្រែងអភិវឌ្ឍន៏ និងចំពោះការទាក់ទាញវិនិយោគឯកជន។ អំពើពុករលួយ មិនគប្បីត្រូវបានមើលឃើញក្នុងភាពទោលតែឯងនោះទេ ប៉ុន្តែវាជាផ្នែកមួយនៃបញ្ហាទូលំទូលាយនៃអភិបាលកិច្ច និងការគ្រប់គ្រងសាធារណៈដែលមានប្រសិទ្ធភាព។ ស្ថិតនៅកៀកជាមួយបញ្ហាផ្នែកស្មារតីនិងផ្លូវច្បាប់ ឥលូវនេះមានភ័ស្តុតាងជាក់ច្បាស់ថាអំពើពុករលួយធ្វើអោយមានបច្ច័យអាក្រក់ចំពោះប្រសិទ្ធភាពប្រតិបត្តិការ ធ្វើអោយការបែងចែកធនធាន ងាកចេញឆ្ងាយពីប្រសិទ្ធភាពកាន់តែខ្លាំង ទៅកាន់ភាពស្មោះត្រង់កាន់តែតិច និងប៉ះពាល់ជាអវិជ្ជមានយ៉ាងខ្លាំងទៅលើពលរដ្ឋក្រីក្រ។ ជំងឺមហារីកនៃអំពើពុករលួយចាំបាច់ត្រូវចាត់វិធានការជាបន្ទាន់។ នៅក្នុងបរិបទនេះ ធនាគារអភិវឌ្ឍន៏អាស៊ីស្វាគមន៏កិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាល ក្នុងការធ្វើសេចក្តីព្រាង *ច្បាប់ប្រឆាំងអំពើពុករលួយ*។ យើងជំរុញអោយពិនិត្យសេចក្តីព្រាងនោះសារឡើងវិញដោយភាគីពាក់ព័ន្ធក្នុងឋានៈជារដ្ឋ និងមិនមែនរដ្ឋ និងអនុម័តទៅជាច្បាប់ ហើយដាក់អោយអនុវត្តដោយមានប្រសិទ្ធភាពអោយបានឆាប់រហ័សបំផុត។ យើងមានជំនឿថា ដំណើរការនេះអាចត្រូវបាន

កសាងលើការពិភាក្សានៅ ក្នុង *សន្និសីទអន្តរជាតិស្តីពីការកសាងសមត្ថភាពដើម្បីតំលាភាព* (២២-២៣ សីហា ឆ្នាំ ២០០១) ដែលរៀបចំដោយធនាគារអភិវឌ្ឍន៍អាស៊ី សហការជាមួយ មណ្ឌលអភិវឌ្ឍន៍សង្គម តំលាភាពអន្តរជាតិ USAID និង CIDA ។ ដូចគ្នាដែរវិធីធ្វើតាមបែបរហ័ស និងមានពេលវេលាសំរាប់កំណែទំរង់ច្បាប់និង តុលាការ គឺត្រូវបានផ្តល់អាទិភាពខ្ពស់បំផុត។

*៤. ការអភិវឌ្ឍន៍វិស័យឯកជន*

ធនាគារអភិវឌ្ឍន៍អាស៊ីគាំទ្រយ៉ាងម៉ឺងម៉ាត់ចំពោះទស្សនៈរបស់រដ្ឋាភិបាល ដែលថាវិស័យឯកជនគឺជាម៉ាស៊ីនសំរាប់អោយមានកំណើនសេដ្ឋកិច្ច មានការអភិវឌ្ឍន៍សេដ្ឋកិច្ច និងមានយុទ្ធសាស្ត្រកំណើនដោយមានការធ្វើអន្តរាគមន៍យ៉ាងខ្លាំងទៅលើពលរដ្ឋក្រខ្សត់ គឺយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រអោយមានប្រសិទ្ធភាពក្នុងក្របខ័ណ្ឌជាតិ។ អាស្រ័យហេតុនេះ វិស័យនេះមានសារៈសំខាន់ណាស់ ដែលរដ្ឋាភិបាលអនុវត្តអោយបានឆាប់រហ័សនូវការបង្កលក្ខណៈសំរាប់នីតិកម្ម និងក្របខ័ណ្ឌបទប្បញ្ញត្តិ ដែលនឹងជំរុញវិនិយោគឯកជន ជាពិសេសគឺក្នុងផ្នែកផលិត។ នៅក្នុងបរិបទនេះ ការបង្កើតតុលាការពាណិជ្ជកម្មដែលមានលក្ខណៈវិជ្ជាជីវៈ នៅក្នុងពេលខាងមុខដ៏ខ្លី គឺជាវិធានការកសាងនូវជំនឿទុកចិត្តដ៏មានប្រសិទ្ធភាពចំពោះវិស័យឯកជន។

ធនាគារអភិវឌ្ឍន៍អាស៊ីមានជំនឿថាការចូលរួមរបស់វិស័យឯកជនលាតសន្ធឹងហួសពីគ្រឿងផ្សំទៅកាន់នីតិកម្មទៅទៀត។ នៅក្នុងលំនាំអភិវឌ្ឍន៍ថ្មី វិស័យឯកជនអាចមានមុខនាទីជាគន្លឹះនៅក្នុងការផ្តល់សេវា។ ឧទាហរណ៍ ក្រសួងអប់រំ យុវជន និងកីឡា (MOEYS) កំពុងតែបង្កលក្ខណៈនិងជំរុញការដាក់បញ្ចូលវិស័យឯកជនក្នុងការអប់រំតាមមធ្យោបាយផ្សេងៗ។ ជាដំបូង មានការប្រើអ្នកម៉ៅការមកពីវិស័យឯកជន និងក្រុមសាលារៀន-ក្រុមសហគមន៍ នៅក្នុងការអនុវត្តន៍គំរោងកសាងសាលារៀន រួមមានការចូលរួមនៃវិស័យធនាគារពាណិជ្ជក្នុងកម្មវិធីគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យ។ បន្ទាប់មក MOEYS កំពុងតែធ្វើសេចក្តីព្រាងបញ្ចប់នូវនីតិកម្មនិងរៀបចំបទប្បញ្ញត្តិសំរាប់អោយមានការរីកចំរើននៃសាកលវិទ្យាល័យ និងបច្ចេកទេស ការអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈឯកជន។ ក្រោយមក MOEYS នឹងចុះកិច្ចសន្យាជាមួយទីភ្នាក់ងារផ្សព្វផ្សាយឯកជន និងអង្គការក្រៅរដ្ឋាភិបាល ក្នុងការផ្សព្វផ្សាយការយល់ដឹងអំពីជំងឺអេដស៍។ ដូចគ្នាដែរ ក្រសួងមហាផ្ទៃមានបំណងប្រើប្រាស់ទីភ្នាក់ងារផ្សព្វផ្សាយឯកជន សំរាប់អនុវត្តនូវការយល់ដឹងរបស់សាធារណជនចំពោះវិមជ្ឈការតាមរយៈក្រុមប្រឹក្សាឃុំ-សង្កាត់។ ជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ីចំពោះក្រសួងទាំងពីរនេះបានលើកអនុសាសន៍និងគាំទ្រយ៉ាងខ្លាំងនូវភាពជាដៃគូដ៏សំខាន់រវាងវិស័យឯកជន និងរដ្ឋាភិបាល។ គោលដៅចុងក្រោយរបស់យើង ពុំមែន

គ្រាន់តែសំដៅ ការផ្តល់សេវាដែលមានប្រសិទ្ធភាពប៉ុណ្ណោះទេ ប៉ុន្តែក៏សំដៅកសាងយន្តការសំរាប់ពិភាក្សា រវាងរដ្ឋាភិបាល និងវិស័យឯកជនផងដែរ។ វិស័យឯកជនគឺជាជនិតាដ៏ធំបំផុតនៃភោគទ្រព្យជាតិ ។ ក្នុងន័យនេះ វិស័យឯកជនគឺជាដៃគូដ៏មានសារៈសំខាន់នៅក្នុងអភិបាលកិច្ចល្អ និងនៅក្នុងការអភិវឌ្ឍន៍ ដែលមាននិរន្តរភាព។

ការលើកកំពស់អភិបាលកិច្ចនិងប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយនៅកម្ពុជានឹងបានទទួលភោគផល តាមរយៈកំណើនសេដកិច្ច និងការកាត់បន្ថយភាពក្រីក្រ។ អភិបាលកិច្ចល្អនឹងជួយជំរុញការវិនិយោគ និង កាត់បន្ថយភាពងាយរងគ្រោះ ដែលប្រឈមមុខជាមួយកម្ពុជា ចំពោះគ្រោះនៃការធ្លាក់ចុះនៃសេដ្ឋកិច្ច។ វាក៏មានតំលៃបង្កប់ផ្ទៃក្នុងផងដែរក្នុងការជំរុញអោយមានការចូលរួម ការដាក់បញ្ចូល និងការអភិវឌ្ឍន៍ លើមូលដ្ឋានទូលាយ ដែលសារៈសំខាន់នេះត្រូវបានគេទទួលស្គាល់យ៉ាងច្រើន និងមានបញ្ជាក់យ៉ាងច្បាស់ នៅក្នុង *ការវាយតំលៃភាពក្រីក្រដោយមានការចូលរួម* ដែលប្រព្រឹត្តទៅដោយមានជំនួយឧបត្ថម្ភគាំទ្រពី ធនាគារអភិវឌ្ឍន៍អាស៊ី និង "*បង្កើតភាពជាដៃគូជាទូទៅសំរាប់ការអភិវឌ្ឍន៍* "ទូលំទូលាយនៃ *គោលដៅអភិវឌ្ឍន៍ប្រចាំសហស្សវត្សរ៍*។ ធនាគារអភិវឌ្ឍន៍អាស៊ីអាចគាំទ្រប្រទេសកម្ពុជានៅក្នុងកិច្ចប្រឹងប្រែង ដ៏មានសារៈសំខាន់នេះ ប៉ុន្តែពលរដ្ឋកម្ពុជាខ្លួនឯងត្រូវមានមគ្គុទេសភាព និងការប្តេជ្ញាជានិរន្តរ៍ និងមាន កម្មសិទ្ធិភាព។

# ការគ្រប់គ្រង
# ធនធានធម្មជាតិ
# ប្រកបដោយនិរន្តរភាព

កិច្ចប្រជុំក្រុមពិគ្រោះយោបល់ឆ្នាំ ២០០២ នៅប្រទេសកម្ពុជា
*កំណត់ពិភាក្សាគោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី*

# ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព

ប្រទេសកម្ពុជាគឺជាប្រទេសមួយដែលដីមានភាពចំរូងចំរាស់។ សូចនាករអភិវឌ្ឍន៍បង្ហាញថាប្រទេសកម្ពុជាគឺជាប្រទេសមួយដែលមានការអភិវឌ្ឍន៍តិចបំផុត — មានកំណើនប្រជាជនខ្ពស់ - ប្រមាណជា ៩០% នៃប្រជាពលរដ្ឋរស់នៅតំបន់ជនបទ ហើយ ផសស សំរាប់ពលរដ្ឋម្នាក់មានតែ ១៩៧ ដុល្លារប៉ុណ្ណោះ (គិតលើមូលដ្ឋានថ្លៃស្ថេរធៀបនឹងឆ្នាំ ១៩៩៣) នៅឆ្នាំ ២០០១។ ពលរដ្ឋ ៣៦% រស់នៅដោយមានប្រាក់ចំណូលទាបជាងបន្ទាត់នៃភាពក្រីក្រក្នុងក្របខ័ណ្ឌជាតិ។ ពលរដ្ឋកម្ពុជាជាច្រើន មានជីវភាពរស់នៅប្រចាំថ្ងៃតោកយ៉ាក និងតំរូវអោយមានការតស៊ូដើម្បីរស់។

ទោះជាយ៉ាងនេះក្តី កម្ពុជានៅមានជ្រុងមួយទៀត។ ព្រះរាជាណាចក្រនេះមានភោគទ្រព្យជាសម្បត្តិធម្មជាតិ ដែលធ្វើអោយពលរដ្ឋនៃប្រទេសនេះមានអាយុរស់នៅរាប់សតវត្សរ៍មកហើយ។ ស្ថានភាពដីរបស់ប្រទេសកម្ពុជាបង្កអោយប្រទេសនេះសម្បូណ៌ធនធានធម្មជាតិ ដោយសារទីតាំងភូមិសាស្ត្រ ដែលជាតំបន់ទទួលដីល្បប់ដ៏មានជីវជាតិពីទន្លេមេគង្គនៅតាមទីទំនាបទឹកជំនន់ ហើយផ្គត់ផ្គង់ទឹកគ្រប់គ្រាន់សំរាប់ដំណាំស្រូវ ដែលជាប្រភពអាហារសំខាន់។ ត្រី ជាប្រភពប្រូតេអ៊ីនចំបងនៃប្រជាពលរដ្ឋភាគច្រើន ហើយមានច្រើនសន្ធឹកសន្ធាប់នៅក្នុងបឹងទន្លេសាប ដែលបឹងនេះជាបឹងទឹកសាបដ៏ធំបំផុតនៅអាស៊ីអគ្នេយ៍ និងជាផ្នែកមួយនៃប្រព័ន្ធទន្លេមេគង្គ។ ព្រៃឈើនៅកម្ពុជាគ្របដណ្តប់លើផ្ទៃដីសរុបប្រមាណជា ៥០%។ ធនធានដ៏សម្បូរណ៍ទាំងនេះ រួមវិភាគទានបានជួយទ្រទ្រង់តំរូវការប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋនៅតំបន់ជនបទ។ ជាងនេះទៅទៀត ជាមួយនឹងកំណើនដ៏រហ័សនៃចំនួនប្រជាជន សម្ពាធមកលើធនធានទាំងនេះកាន់តែមានសភាពធ្ងន់ធ្ងរឡើងៗ ដែលជួនកាល ពលរដ្ឋមូលដ្ឋានមិនអាចទាញផលពីភោគទ្រព្យទាំងនោះឡើយ។ ភាពសម្បូរណ៍ស្តុកស្តម្ភនៃធនធានទាំងនេះអាចពុំស្ថិតនៅក្នុងសភាពដូចកាលពីមុនទៀតឡើយ។ ក្នុងសភាពដែលធនធាននេះមានសារៈសំខាន់ចំពោះប្រជាជនរស់នៅតាមជនបទ និងចំពោះសេដ្ឋកិច្ចជាតិជាការចាំបាច់ណាស់ នៅក្នុងដំណើរការនៃការអភិវឌ្ឍន៍ រដ្ឋាភិបាលផ្តល់អាទិភាពខ្ពស់ចំពោះការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិអោយមាននិរន្តរភាព។

រដ្ឋាភិបាលបានទទួលស្គាល់ចំណងទាក់ទងយ៉ាងស្អិតរមួតរវាងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាពនិងការកាត់បន្ថយភាពក្រីក្រ។ នៅក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចលើកទីពីរ (SEDP II)ដែលក្នុងផែនការនោះ ការកាត់បន្ថយភាពក្រីក្រគឺជាគោលដៅសំខាន់បំផុត ហើយការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ផែនការនេះ។ រដ្ឋាភិបាលក៏បានកំណត់មុខសញ្ញាលើការគ្រប់គ្រងធនធានធម្មជាតិអោយមាននិរន្តរភាព ថាជាផ្នែកកំណែទំរង់មួយ នៃផ្នែកកំណែទំរង់ជាគន្លឹះនៅក្នុងផែនការសកម្មភាពអភិបាលកិច្ចរបស់ខ្លួន។ នេះគឺជាជំហានមួយមានសារៈសំខាន់ណាស់ ព្រោះថាការផ្តោតទៅលើការសំរេចបាននូវការគ្រប់គ្រងធនធានធម្មជាតិអោយមាននិរន្តរភាព គឺជាវត្តមាននៃអភិបាលកិច្ចល្អ ដែលជំរុញតំលាភាព និងគណនេយ្យភាព ហើយ ធានាលទ្ធភាពឈានទៅរកសមធម៌ចំពោះការទទួលធនធានធម្មជាតិសំរាប់ពលរដ្ឋជនបទ ដែលច្រើនតែពឹងផ្អែកលើធនធានទាំងនោះ។ ធនាគារអភិវឌ្ឍន៍អាស៊ីលើកសរសើររដ្ឋាភិបាលចំពោះការធ្វើដំណើរលើទិសដៅនេះ ជាពិសេសគឺក្នុងការគ្រប់គ្រងដីធ្លី ធនធានទឹក ព្រៃឈើ និងជលផល ហើយលើកទឹកចិត្តយ៉ាងខ្លាំងចំពោះរដ្ឋាភិបាល អោយបន្តតាមមាគ៌ានេះតទៅទៀត។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ធនាគារអភិវឌ្ឍន៍អាស៊ី ឆ្លៀតយកឱកាសនេះ ដើម្បីចែករំលែកនូវបទពិសោធន៍ខ្លះក្នុងការគាំទ្រការអនុវត្តន៍ដែលមានប្រសិទ្ធភាព ចំពោះការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

## ការគ្រប់គ្រងដីធ្លី

*១. អនុក្រិត្យសំរាប់អនុវត្តច្បាប់ភូមិបាល*

ក្រសួងគ្រប់គ្រងដែនដី នគររូបនីយកម្ម និងសំណង់ (MLMUPC) ក្នុងពេលបច្ចុប្បន្ននេះកំពុងរៀបចំអនុក្រិត្យជាច្រើន ដើម្បីអាចអនុវត្តច្បាប់ភូមិបាលបាន។ ជាការសំខាន់ណាស់ ដែលការពិភាក្សាប្រព្រឹត្តទៅដោយយកចិត្តទុកដាក់ ហើយការអនុម័តអនុក្រិត្យប្រព្រឹត្តទៅដោយឆាប់រហ័សរវាង MLMUPC និងក្រុមប្រឹក្សារដ្ឋមន្ត្រី ។ ធនាគារអភិវឌ្ឍន៍អាស៊ី សូមលើកសរសើររដ្ឋាភិបាល ចំពោះការអនុម័តកាលពីពេលថ្មីៗកន្លងទៅនេះ នូវអនុក្រិត្យចំនួនបីៈ ១) អនុក្រិត្យស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈកម្មការសុរិយោដី ២) អនុក្រិត្យស្តីពីការបង្កើតការចុះបញ្ជីដីក្នុងលក្ខណៈជាប្រព័ន្ធ និងទី ៣) អនុក្រិត្យស្តីពីការចុះបញ្ជីដីម្តងម្កាល។ ការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាពនៃអនុក្រិត្យទាំងនេះនឹងធ្វើអោយប្រាកដថាការការពារ កម្មសិទ្ធដីធ្លីត្រូវបានធានាដោយច្បាប់ភូមិបាល នឹងត្រូវបានអនុវត្ត។ អនុក្រិត្យទាំងនោះនៅតំរូវអោយដាក់បញ្ចូលផងដែរនូវសម្បទានផ្នែកសង្គម ។ អនុក្រិត្យកាត់បន្ថយទំហំសម្បទានកសិកម្មដែលបានផ្តល់មុនពេលបង្កើតច្បាប់ថ្មី និងអនុក្រិត្យសំរាប់ផ្តល់សម្បទានកសិកម្មថ្មី។

*២. ការកាន់កាប់អចលនទ្រព្យ*

ទោះបីជាមានការកាន់កាប់អចលនទ្រព្យរបស់រដ្ឋយ៉ាងច្រើនក្តី (ដី និងអគារ) ប្រាក់ចំណូលទៅក្នុងថវិកាពីការជួល ពីភតិសន្យា និងពីសិទ្ធប្រើប្រាស់ដីដទៃទៀត នៅមានកំរិតតិចតួចណាស់។ ពន្ធដែលប្រមូលបានពីការទិញលក់ទ្រព្យសម្បត្តិជាកម្មសិទ្ធឯកជនក៏មានកំរិតទាបជាងការគ្រោងទុកផងដែរ។ ច្បាប់ភូមិបាលបញ្ជាក់ថាសម្បទាននឹងត្រូវកំណត់ត្រឹម ១០.០០០ ហិកតា។ ប៉ុន្តែទោះជាយ៉ាងនេះក្តី សម្បទានមួយចំនួន និងសូម្បីតែសម្បទានកាលពីពេលថ្មីៗកន្លងទៅដែលបានផ្តល់ មានទំហំជាងទំហំដែលបានកំណត់នៅក្នុងច្បាប់នេះដែរ។ ជាងនេះទៅទៀត ដីកសិកម្មល្អនៅទំនេរ ភាគច្រើនមានចំណងទាក់ទងជាមួយសម្បទានដែលមានទំហំលើសពីកំរិត ១០.០០០ ហិកតានេះច្រើនណាស់។ ការកាត់បន្ថយសម្បទានទាំងនេះអោយមកនៅត្រឹមទំហំដែលកំណត់ដោយច្បាប់ នឹងធ្វើអោយដីដែលមានគុណភាពល្អទាំងនេះអាចត្រូវបានកសិករតូចតាចកាន់កាប់។

រដ្ឋាភិបាលគប្បីធ្វើអោយមានតំលាភាពអំពីថ្លៃទ្រព្យសម្បត្តិ ថ្លៃជួល និងប្រាក់ចំណូល។ ចំពោះសម្បទានដីធ្លី ធនាគារអភិវឌ្ឍន៍អាស៊ីផ្តល់អនុសាសន៍អោយរដ្ឋាភិបាលរៀបចំអនុក្រិត្យដូចតទៅៈ (i) អនុក្រិត្យស្តីពីសម្បទានសង្គម ( ii )អនុក្រិត្យកាត់បន្ថយដីសម្បទានកសិកម្ម ( iii )អនុក្រិត្យស្តីពីការផ្តល់សម្បទានកសិកម្មថ្មី។ អនុក្រិត្យដែលមានចំណងទាក់ទងទៅវិញទៅមកនេះ គប្បីត្រូវបានរៀបចំក្នុងពេលស្របគ្នា ដើម្បីធានាអោយអនុក្រិត្យទាំងនោះស៊ីសង្វាក់គ្នា។ រដ្ឋាភិបាលក៏គប្បីធ្វើអោយប្រាកដផងដែរថា ការវាយតំលៃអំពីផលប៉ះពាល់ផ្នែកបរិស្ថាននិងផ្នែកសង្គមត្រូវបានដំណើរការដោយមានការពិគ្រោះដោយពេញលេញជាមួយភាគីពាក់ព័ន្ធនានា និងអនុលោមទៅតាមច្បាប់ស្តីពីការគ្រប់គ្រងបរិស្ថានជាតិ មុនពេលផ្តល់សម្បទានដីធ្លី។

*៣. ការកំណត់ព្រំដីនិងការផ្តល់ប័ណ្ណកាន់កាប់ដីរបស់រដ្ឋ*

ភាពមិនច្បាស់លាស់នៃដីរបស់រដ្ឋបន្ថែមសម្ពាធទៅលើកម្មសិទ្ធដីធ្លីនៅកម្ពុជា ហើយធ្វើអោយមានកំហិតចំពោះសមត្ថភាពរបស់កម្ពុជា ក្នុងការធានាថាពលរដ្ឋទាំងអស់បានទទួលអត្ថប្រយោជន៍ពីការគ្រប់គ្រងសម្បត្តិរដ្ឋ ព្រៃឈើ និងធនធានធលផល ប្រកបដោយនិរន្តរភាព។ ធនាគារអភិវឌ្ឍន៍អាស៊ីជំរុញអោយរដ្ឋាភិបាលចាប់ផ្តើមដំណើរការគូសបញ្ជាក់ព្រំដីរបស់រដ្ឋអោយបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន។

*៤. សម្បត្តិសម្ហបភាពរបស់ពលរដ្ឋម្ចាស់ស្រុក*

ប្រជាពលរដម្ចាស់ស្រុកនៅខេត្តរតនគិរី និងមណ្ឌលគិរី គឺជាជនជាតិភាគតិច ដែលមានវប្បធម៌ផ្ទាល់ខ្លួនផ្សេងពីពលរដ្ឋកម្ពុជាដទៃ។ ចំពោះអ្នកទាំងនោះ ដីមានទាំងតំលៃប្រើប្រាស់ និងមានន័យខាងផ្នែកស្មារតី ហើយកម្មសិទ្ធដីធ្លីមានលក្ខណៈជាសម្ហបភាព ជាជាងជាកម្មសិទ្ធរបស់បុគ្គលម្នាក់ៗ។ បញ្ញត្តិស្តីពីច្បាប់ភូមិបាលទទួលស្គាល់នូវកម្មសិទ្ធតែមួយនៃការប្រតិបត្តិរបស់ពលរដ្ឋម្ចាស់ស្រុក។ ធនាគារអភិវឌ្ឍន៍អាស៊ីមានកង្វល់ថាបណ្តាអ្នកចូលទៅរស់នៅក្នុងខេត្តទាំងនេះកំពុងតែគំរាមកំហែងដីធ្លីសម្ហបភាពរបស់ជនជាតិភាគតិច។ អាស្រ័យហេតុនេះ រដ្ឋាភិបាលគប្បីប្រកាន់យកនូវជំហានសមស្របនានានៅក្នុងរយៈពេលប៉ុន្មានខែខាងមុខ ដើម្បីអនុវត្តបញ្ញត្តិពិសេសស្តីអំពីច្បាប់ភូមិបាល ហើយក្នុងពេលជាមួយគ្នានោះបញ្ឈប់ការបំពានយកដីធ្លីដែលជារបស់ពលរដ្ឋមាស់ស្រុក។

*៥. ការដណ្តើមដីធ្លី*

ការចាប់យកដីធ្លីធ្វើអោយធនាគារអភិវឌ្ឍន៍អាស៊ី និងសមាជិកនៃសហគមន៍ផ្តល់ជំនួយដទៃទៀតមានកង្វល់។ ការបង្កើតឡើងនូវគណៈកម្មការស៊ុរិយោដីរបស់រដ្ឋាភិបាល នៅមូលដ្ឋាន ថ្នាក់ខេត្ត និងថ្នាក់ជាតិដើម្បីចរចារនិងគ្រប់គ្រងលើទំនាស់កម្មសិទ្ធដីធ្លីនិងសិទ្ធស្តីពីកម្មសិទ្ធត្រូវបានលើកសរសើរយ៉ាងខ្លាំង។ ធនាគារអភិវឌ្ឍន៍អាស៊ីលើកទឹកចិត្តរដ្ឋាភិបាលអោយផ្តល់ការគាំទ្រនិងធនធានអោយបានសមស្រប ដើម្បីអោយគណៈកម្មការនេះមានដំណើរការដោយមានប្រសិទ្ធភាព ជាពិសេសគឺនៅថ្នាក់មូលដ្ឋាន។ ធនាគារអភិវឌ្ឍន៍អាស៊ីក៏ជំរុញអោយរដ្ឋាភិបាលប្រកាន់នូវជំហរម៉ឺងម៉ាត់ក្នុងការទប់ស្កាត់ការចាកចោលដីធ្លីនៃពលរដ្ឋក្រីក្រ ដោយសារតែបុគ្គលមានអំណាច។

**ធនធានទឹក**

ទន្លេមេគង្គ ទន្លេសាប និងទន្លេបាសាក់ ព្រមទាំងបឹងទន្លេសាប ទាំងអស់នេះ គឺជាសសៃឈាមនៃប្រទេសកម្ពុជា ។ ប្រការនេះធ្វើអោយមានការយល់ដឹងថា ប្រទេសកម្ពុជាគឺជាប្រទេសមួយដែលសម្បូណ៌ធនធានទឹក។ ប៉ុន្តែ ការពិនិត្យអោយបានដិតដល់បង្ហាញថា ធនធានទឹកនៃកម្ពុជាកំពុងស្ថិតនៅក្នុងភាពតានតឹង ហើយភាពតានតឹងនេះមានកំរិតធ្ងន់ធ្ងរជាងការដែលគេតែងតែរំពឹងគិតទៅទៀត។ ប្រទេសកម្ពុជាសម្បូណ៌ទឹកតែប្រាំមួយខែតែប៉ុណ្ណោះ។ ប្រាំមួយខែទៀត នៅតំបន់ជាច្រើននៃប្រទេសកម្ពុជាមានទឹកមិនគ្រប់គ្រាន់ ហើយគេឃើញមានការដណ្តើមធនធានដ៏មានតំលៃនេះ។ ជាងនេះទៅទៀត សភាពធ្លាក់ចុះនៃបរិស្ថានក៏ធ្វើអោយភាពតានតឹងនេះកាន់តែមានសភាពធ្ងន់ធ្ងរឡើងៗចំពោះធនធានទឹក មានជាអាទិ

(i) អត្រាជំងឺខ្ពស់នៃវត្តមានជំងឺទាក់ទងនឹងការប្រើប្រាស់ទឹក (ដោយសារប្រើប្រាស់ផ្លូវទឹក ជាទូទៅមិនបានត្រឹមត្រូវ តាមរយៈការបង្ហូរកាកសំណល់ ក៏ដូចជាការបរិក្ខាផ្គត់ផ្គង់មិនសមស្រប) (ii) ការចុះថយនៃផលនេសាទនៅក្នុងទន្លេមេគង្គ និងទន្លេសាប (ដោយសារមានការខូចខាតនូវប្រព័ន្ធផ្លូវទឹកនៃតំបន់ជំវិញបឹងទន្លេសាប) (iii) ការកើនឡើងនូវការប្រកួតប្រជែងរវាងកសិករក្នុងការយកទឹកដែលមាននៅក្នុងទន្លេបំរើអោយការស្រោចស្រព និង (iv) ការរីកមាឌនៃទន្លេសាបនិងបឹងទន្លេសាប។ ស្ថានភាពនេះបង្ហាញភាពងាយរងគ្រោះនៃធនធានទឹកនិងសុខភាពទឹកនៃប្រទេសនេះ ថាមានទំនាក់ទំនងដោយផ្ទាល់ជាមួយសុខភាពសេដ្ឋកិច្ចនិងសុខភាពប្រជាជនកម្ពុជា។

រដ្ឋាភិបាលបានបង្កើតក្រសួងធនធានទឹកនិងឧតុនិយមដើម្បីពិនិត្យមើលការគ្រប់គ្រងនិងការប្រើប្រាស់អោយមានផលិតភាពនូវធនធានទឹក។ ប៉ុន្តែ សមត្ថភាពរបស់ក្រសួងនេះនៅខ្សោយ ហើយអាណត្តិការងាររបស់ក្រសួងនេះចាំបាច់ត្រូវថែងអោយបានច្បាស់លាស់និងត្រូវពង្រឹងបន្ថែម។ ក្រសួងនេះចាំបាច់ត្រូវពង្រីកវិសាលភាពនៃការទទួលខុសត្រូវពីការអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពកសិកម្ម មកកាន់ការគ្រប់គ្រងធនធានទឹកដែលបានធ្វើសមាហរណកម្មពេញលេញ ដែលនឹងរួមបញ្ចូលនូវការចូលរួមនិងសហប្រតិបត្តិការនៃភាគីពាក់ព័ន្ធពហុភាគី ហើយសំរេចបាននូវនិរន្តរភាពលើរយៈពេលវែង។ ធនាគារអភិវឌ្ឍន៍អាស៊ីបាននិងកំពុងជំរុញគោលការណ៍ដែលបានទទួលយកជាទូទៅអំពីការគ្រប់គ្រងធនធានទឹកដែលបានធ្វើសមាហរណកម្មនៅក្នុងតំបន់ទាំងមូល ដោយធនាគារនេះមានជំនឿថាការជំរុញអោយមានភាពស្មើគ្នាចំពោះលទ្ធភាពប្រើប្រាស់ទឹក គឺជាគន្លឹះនៃការកាត់បន្ថយភាពក្រីក្រ ការលើកកំពស់ការអភិវឌ្ឍន៍សុខភាពនិងសេដ្ឋកិច្ច។ ក្រសួងធនធានទឹកនិងឧតុនិយមគប្បីរៀបចំការបង្កើតគោលនយោបាយជាតិស្តីអំពីទឹក និងច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកអោយបានឆាប់រហ័ស ធ្វើជាគ្របខ័ណ្ឌឧបករណ៍សំរាប់លើកកំពស់ក្រសួងធ្វើជាអ្នកគ្រប់គ្រងធនធានទឹករបស់ប្រទេសជាតិ។ ធនាគារអភិវឌ្ឍន៍អាស៊ីលើកទឹកចិត្តអោយរដ្ឋាភិបាលផ្តល់ការឯកភាពក្របខ័ណ្ឌទាំងនេះ និងជំរុញការអនុវត្តន៍របស់ខ្លួនអោយមានប្រសិទ្ធភាពនៅពាក់កណ្តាលឆ្នាំ ២០០៣។

## កំណែទំរង់ព្រៃឈើ

បញ្ហាកំណែទំរង់ជាគន្លឹះរួមមាន ១) ការគ្រប់គ្រងសម្បទានព្រៃឈើ ២) ការពិនិត្យមើលសារឡើងវិញនូវអនុក្រិត្យស្តីពីព្រៃឈើសហគមន៍ ៣) ការកំណត់នូវទ្រព្យសម្បត្តិព្រៃឈើអចិន្ត្រៃយ៍របស់ជាតិ។

### *១. ការគ្រប់គ្រងសម្បទានព្រៃឈើ*

កំណែទំរង់ដែលកំពុងប្រព្រឹត្តទៅនៃការគ្រប់គ្រងសម្បទានព្រៃឈើតំរូវអោយអ្នកបានទទួលសម្បទានព្រៃឈើសព្វថ្ងៃដាក់ជូនរដ្ឋាភិបាលពិនិត្យអំពីផែនការគ្រប់គ្រងព្រៃឈើដែលមាននិរន្តរភាព នៅចុងខែកញ្ញា ឆ្នាំ ២០០១។ ស្ទើរតែរាល់សម្បទានទាំងអស់មិនបានដាក់ផែនការរបស់ខ្លួនអោយទាន់កាលកំណត់ទេ ហើយផែនការខ្លះដែលរដ្ឋាភិបាលបានទទួល មានក៏រិតឆ្លើយតបតិចតួចណាស់ទៅនឹងស្តង់ដារអន្តរជាតិដែលអាចទទួលយកបាន។ អាស្រ័យហេតុនេះ រដ្ឋាភិបាលបានពន្យារពេលមួយឆ្នាំទៀត ហើយបិទការកាប់ឈើ ( ប្រកាសលេខ ៥៧២១)ស្តីពីសម្បទានព្រៃឈើដែលមានប្រសិទ្ធភាពចាប់ពីថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០២ តទៅ។

រដ្ឋាភិបាលត្រូវបានជំរុញយ៉ាងខ្លាំងអោយកំណត់ពេលវេលាថ្មីអោយបានម៉ឺងម៉ាត់សំរាប់ដំណើរការចរចារកិច្ចសន្យា។ សម្បទានទាំងឡាយណាដែលអាចបន្តការចរចារសារជាថ្មី គប្បីត្រូវកំណត់ដោយមិនពន្យារពេលបន្តទៅទៀតទេ ហើយត្រូវធ្វើអោយមានតំលាភាពពេញលេញ និងមានការពិគ្រោះជាសាធារណៈឈរលើមូលដ្ឋាននៃលទ្ធភាពពាណិជ្ជកម្មនិងភាពសមស្របនៃផែនការគ្រប់គ្រងព្រៃឈើដែលមាននិរន្តរ-ភាព។ សម្បទានទាំងឡាយណាដែលមិនបានឆ្លើយតបនឹងល័ក្ខខ័ណ្ឌរបស់រដ្ឋាភិបាលចំពោះការចរចារសារជាថ្មីទេនោះ គប្បីលុបចោលជាបន្ទាន់។ រដ្ឋាភិបាលត្រូវបានជំរុញអោយលុបចោលនូវសម្បទានទាំងនោះ ដែលត្រូវបានកំណត់ថាបានធ្វើពាណិជ្ជកម្មមិនធានាភាពយូរអង្វែង ដើម្បីបញ្ឈប់ការវិចរិលព្រៃឈើនិងដីធ្លីបន្ថែមទៀតនៅក្នុងសម្បទានទាំងនោះ។ សេចក្តីសំរេចក្នុងការបំលែងដីព្រៃសម្បទាន ពីដីព្រៃដែលវិចរិល ទៅជាដីព្រៃដែលមិនវិចរិល គប្បីត្រូវពន្យារពេល ហើយការពិនិត្យមើលសារឡើងវិញដោយលក្ខណៈបច្ចេកទេស និងវិទ្យាសាស្ត្រ ក្នុងការកំណត់មើលអំពីភាពសមស្របនៃការប្រើប្រាស់ គប្បីត្រូវបានប្រកាន់យក។ ជាចុងក្រោយ រដ្ឋាភិបាលគប្បីចាត់វិធានការផ្លាស់ប្តូរ ដើម្បីលុបចោលនូវកិច្ចព្រមព្រៀងសម្បទានព្រៃឈើទាំងឡាយណា ដែលរំលោភលើ *ប្រកាសលេខ ៥៧២១* តាមរយៈការធ្វើអាជីវកម្មដោយខុសច្បាប់ ហើយមិនអនុញ្ញាតិអ្នកទាំងនោះមិនអោយដំណើរការចរចារសាជាថ្មី។ ជាងនេះទៅទៀត រដ្ឋាភិបាលត្រូវបានលើកទឹកចិត្តអោយធ្វើយ៉ាងណាដើម្បីអោយអ្នកបានទទួលព្រៃឈើសម្បទានមានវិធានការសមស្រប ក្នុងការការពារសម្បទានរបស់ខ្លួន នៅក្នុងអំលុងពេលហាមឃាត់អាជីវកម្មព្រៃ

ឈើ។ ត្រូវបញ្ឈប់ការកាប់រំលំដើមឈើយកជ័រ ដែលសហគមន៍ព្រៃឈើជាច្រើនពឹងផ្អែកយ៉ាងខ្លាំងទៅលើដើមឈើទាំងនោះ ចំពោះការរកប្រាក់ចំណូល ហើយសកម្មភាពបញ្ឈប់នេះត្រូវបាននាយករដ្ឋមន្ត្រីប្តេជ្ញាការពារសហគមន៍ព្រៃឈើផងដែរ។

ធនាគារអភិវឌ្ឍន៍អាស៊ីបានដឹងនិងសូមស្វាគមន៍សេចក្តីសំរេចរបស់រដ្ឋាភិបាល កាលពីថ្ងៃទី ២៣ ខែឧសភា ចំពោះការហាមឃាត់ការដឹកជញ្ជូនឈើគ្រប់ប្រភេទ។ ការអនុវត្តន៍អោយបានត្រឹមត្រូវនូវសេចក្តីសំរេចនេះនឹងពង្រឹង*ប្រកាសលេខ ៩៧២១*។ ប៉ុន្តែ នៅពេលណាដែលការហាមឃាត់នេះត្រូវបានបញ្ឈប់ហើយ ការដឹកជញ្ជូនឈើមានសកម្មភាពឡើងវិញ ធនាគារអភិវឌ្ឍន៍អាស៊ីជំរុញរដ្ឋាភិបាលយ៉ាងខ្លាំង អោយបង្កើតនូវកម្មវិធីជូនដំណឹងជាសាធារណៈ ដែលក្នុងនោះសាធារណជនត្រូវបានជូនដំណឹងយ៉ាងហោចណាស់រយៈ ពេលពីរសប្តាហ៍ជាមុន ដែលនាយកដ្ឋានរុក្ខានិងប្រមាញ់ចេញលិខិតអនុញ្ញាតដឹកជញ្ជូនចំពោះក្រុមហ៊ុន អាជីវកម្មព្រៃឈើក្នុងការដឹកជញ្ជូនផលិតផលឈើ។ ការជូនដំណឹងជាសាធារណៈក៏គប្បីរួមបញ្ចូលផងដែរ នូវពត៌មាននានាដូចជាៈ តើគេចេញការអនុញ្ញាតិនេះអោយនរណា តើការដឹកជញ្ជូនឈើ គេដឹកពីពីណាទៅណា រយៈពេលនៃការអនុញ្ញាតិ (មិនគប្បីមានរយៈពេលវែងជាងពីរសប្តាហ៍ឡើយ ក្នុងមួយ លើក។) ហើយនឹងបរិមាណឈើដឹកជញ្ជូន។

ការអនុម័តនូវកម្មវិធីជូនដំណឹងជាសាធារណៈគប្បីបង្កានូវមន្ទីលសង្ស័យសាធារណៈដែលថាការដឹកជញ្ជូនឈើកំពុងកើតមាន ហើយបង្ហាញអោយឃើញការប្តេជ្ញារបស់រដ្ឋាភិបាលចំពោះអភិបាលកិច្ចល្អ តាមរយៈការបង្ហាញអោយដឹងពេញលេញនូវសេចក្តីសំរេចដែលបានធ្វើនៅក្នុងវិស័យព្រៃឈើ។ កម្មវិធីនេះនឹងជំរុញមានគណនេយ្យភាពនិងកសាងជំនឿទុកចិត្តលើរដ្ឋាភិបាល ព្រោះថាសាធារណជនត្រូវបានជូនដំណឹងអំពីការសំរេចនានារបស់រដ្ឋាភិបាល។ ក្រៅពីនេះកម្មវិធីនេះក៏ជួយសំរួលការតាមដានការទូទាត់ប្រាក់សួយសារ ចំពោះឈើ ហើយប្រការនេះនឹងបង្ហាញអោយឃើញថាប្រាក់ចំណូលពីអាជីវកម្មឈើត្រូវបានបញ្ចូលទៅក្នុងរតនាគារជាតិ។

*២. ការពិនិត្យមើលសារឡើងវិញ នូវអនុក្រិត្យស្តីពីព្រៃឈើសហគមន៍*

សហគមន៍ព្រៃឈើគឺជាផ្នែកមួយនៃការគ្រប់គ្រងព្រៃឈើអោយមាននិរន្តរភាព ព្រោះថាសហគមន៍នេះលើកកំពស់កម្មសិទ្ធភាពនៃធនធានព្រៃឈើ ការចូលរួម និងកិច្ចសហការរវាងអាជ្ញាធរនិងសហគមន៍នានា។ ប្រសិនបើមានការរៀបចំផែនការ និងការគ្រប់គ្រងបានល្អ សហគមន៍ព្រៃឈើអាចមានលទ្ធភាពឆ្លើយតបនឹងតំរូវការរយៈពេលវែងនិងខ្លីនៃសហគមន៍មូលដ្ឋាន ក្រៅពីរកបាននូវប្រាក់ចំណូល ដែលគេអាច

ប្រើប្រាស់សំរាប់អភិវឌ្ឍសហគមន៍។ ជាការទទួលស្គាល់នូវអត្ថប្រយោជន៍ទាំងនេះ រដ្ឋាភិបាលកំពុងតែប្រកាន់យកនូវជំហាននានាដើម្បីជំរុញនិងទទួលស្គាល់ជាផ្លូវការនូវមុខនាទីរបស់សហគមន៍ក្នុងការគ្រប់គ្រងព្រៃឈើនៅមូលដ្ឋាន។ ថ្មីៗនេះរដ្ឋាភិបាលកំពុងរៀបចំអនុក្រឹត្យមួយស្តីពីព្រៃឈើ ហើយនាយកដ្ឋានរុក្ខានិងប្រមាញ់បានធ្វើការពិគ្រោះយ៉ាងច្រើនជាមួយភាគីពាក់ព័ន្ធនានា ដែលអនុក្រឹត្យនោះត្រូវបានបញ្ចប់កាលពីដើមឆ្នាំ ហើយដាក់ជូននាយកដ្ឋានរុក្ខានិងប្រមាញ់ពិនិត្យមើលសារឡើងវិញ។ ទោះជាយ៉ាងនេះក្តី មានកង្វល់ខ្លះដែលថាការពិនិត្យមើលសារឡើងវិញនេះ នឹងធ្វើអោយមានការកែប្រែអនុក្រិត្យ ដែលអាចធ្វើអោយប៉ះពាល់ដល់វិភាគទានរបស់ភាគីពាក់ព័ន្ធ នៅក្នុងដំណើរការពិគ្រោះ។ ធនាគារអភិវឌ្ឍន៍អាស៊ីជំរុញយ៉ាងខ្លាំងចំពោះការកែប្រែណាដែលប៉ះពាល់ដល់អនុក្រិត្យ ក្រោយពីដំណាក់ការពិគ្រោះ អោយធ្វើការផ្សព្វផ្សាយជូនសាធារណជន និងស្នើអោយទុកពេលគ្រប់គ្រាន់សំរាប់ភាគីពាក់ព័ន្ធធ្វើការឆ្លើយតប។

*៣. ការកំណត់នូវទ្រព្យសម្បត្តិព្រៃឈើអចិន្ត្រៃយ៍របស់ជាតិ*

ទ្រព្យសម្បត្តិព្រៃឈើអចិន្ត្រៃយ៍របស់កម្ពុជាមិនត្រូវបានញែកអោយបានច្បាស់លាស់ទេ។ មានករណីខ្លះដែលសហគមន៍មូលដ្ឋាន និងនាយកដ្ឋានរុក្ខានិងប្រមាញ់ធ្វើការតវ៉ាគ្នានៅតំបន់មួយចំនួន។ រដ្ឋាភិបាលត្រូវបានលើកទឹកចិត្តអោយផ្តួចផ្តើមនូវដំណើរការកំណត់និងបោះសញ្ញាសំគាល់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍របស់រដ្ឋ។ ដំណើរការនេះគប្បីជាដំណើរការដែលមានការចូលរួម។ ជាមួយនឹងសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ដែលមានការកំណត់ច្បាស់លាស់ ប្រទេសកម្ពុជាមានលទ្ធភាពវាយតំលៃនិងអាចធ្វើអោយបានប្រសើរនូវកម្មវិធីគ្រប់គ្រងព្រៃឈើរបស់ខ្លួន ហើយពិចារណាអំពីជំរើសគ្រប់គ្រងផ្សេងៗ ដែលអាចដាក់បញ្ចូលនូវសហគមន៍មូលដ្ឋាន និងផ្នែកឯកជន។ ធនាគារអភិវឌ្ឍន៍អាស៊ីនឹងជួយរដ្ឋាភិបាលក្នុងការរៀបចំក្របខ័ណ្ឌជាយុទ្ធសាស្ត្រចំពោះវិស័យព្រៃឈើ ដែលក្នុងនោះនឹងមានការកំណត់អត្តសញ្ញាណគោលនយោបាយតាមវិស័យ យុទ្ធសាស្ត្រនានា (វិធីសាស្ត្រផ្សេងៗ) ព្រមទាំងអាទិភាពវិនិយោគ។

**កំណែទំរង់ជលផល**

វិស័យជលផលមានការប្រែប្រួលយ៉ាងច្រើននៅចុងឆ្នាំ ២០០០ នៅពេលដែលនាយករដ្ឋមន្ត្រីបានដកយកមកវិញនូវឡូតិ៍នេសាទជាង ៥០% មកអោយសហគមន៍មូលដ្ឋាន ដើម្បីអោយពួកគេគ្រប់គ្រង។ ទោះបីជាមានវិបត្តិកាលពីដើមដំបូងក្នុងការកែតំរូវចំពោះការប្រគល់នេះក្តី សំរាប់រយៈពេលវែង សេចក្តី

សំរេចនេះនឹងធ្វើអោយសហគមន៍ជនបទបានទទួលអត្ថប្រយោជន៍ ដែលសហគមន៍ទាំងនោះនឹងមានការទទួលខុសត្រូវបន្ថែមក្នុងការគ្រប់គ្រងធនធានជលផលផ្ទាល់របស់ខ្លួន។ ធនាគារអភិវឌ្ឍន៍អាស៊ីមានសេចក្តីរីករាយក្នុងការកត់សំគាល់ថាកំណែទំរង់ស្ថាប័នកំពុងដំណើរការ ហើយក្របខ័ណ្ឌច្បាប់ថ្មី កំពុងត្រូវបានរៀបចំ ដើម្បីដៅទិសនាយកដ្ឋានរុក្ខានិងប្រមាញ់ទៅកាន់ការគ្រប់គ្រងជលផល អោយមាននិរន្តរភាព និងលើកកំពស់ការគ្រប់គ្រងធនធានធម្មជាតិដែលមាននៅសហគមន៍។ ដើម្បីជួយរដ្ឋាភិបាលក្នុងបញ្ហានេះ ភាពជាដៃគូជាមួយ GEF, UNDP, សមត្ថភាព ២១, UNESCO និង FAO កំពុងរៀបចំគំរោងកសាង សមត្ថភាព ដើម្បីគាំទ្រ DoF និងសហគមន៍មូលដ្ឋាននៅជុំវិញបឹងទន្លេសាប។

ធនាគារអភិវឌ្ឍន៍អាស៊ីជំរុញរដ្ឋាភិបាលអោយបន្តរៀបចំសេចក្តីព្រាងច្បាប់ស្តីពីជលផល ហើយឈានទៅរកការផ្តល់សច្ចាប័ននៅឆ្នាំ ២០០៣។ អនុក្រិត្យស្តីពីនេសាទសហគមន៍ក្នុងទំរង់បច្ចុប្បន្ន ទំនងជាមិនអាចអនុវត្តបាន។ អនុក្រិត្យនេះគួសបញ្ជាក់យ៉ាងច្រើនអំពីការនេសាទជីវព្រឹត្ត ប៉ុន្តែអនុក្រិត្យនេះក៏គប្បីគិតគូរផងដែរចំពោះសហគ្រាសខ្នាតតូច។ ដើម្បីធានាថារដ្ឋាភិបាលបង្កើតនូវមធ្យោបាយផ្លូវច្បាប់រឹងមាំនិងមានប្រសិទ្ធភាព ដែលមានលក្ខណៈសមស្រប និងមានការទ្រទ្រង់ពីភាគីពាក់ព័ន្ធនានា ធនាគារអភិវឌ្ឍន៍អាស៊ីនិងសមាជិកនៃក្រុមការងារស្តីពីការគ្រប់គ្រងធនធានធម្មជាតិស្នើសុំអោយរដ្ឋាភិបាលពិគ្រោះជាមួយភាគីពាក់ព័ន្ធជាលើកដំបូង ដើម្បីពិនិត្យមើលនូវបញ្ហាដ៏មានសារៈសំខាន់ទាំងនេះនៅមុនពេលកសាងបញ្ចប់អនុក្រិត្យនោះ។

មានការរាយការណ៍ជាបន្តបន្ទាប់នៅក្នុងប្រព័ន្ធផ្សព្វផ្សាយ អំពីទំនាស់លើការប្រើប្រាស់ដែននេសាទ។ ទំនាស់ទាំងនេះទំនងជាមានប្រភពមកពីប្រជាពលរដ្ឋមូលដ្ឋានដែលមិនត្រូវបានអនុញ្ញាតអោយនេសាទនៅតំបន់នេសាទនានា ឬបណ្តាលមកពីកង្វះការយល់ដឹងវិធានច្បាប់ឬបទបញ្ញត្តិបច្ចុប្បន្នអំពីការនេសាទ។ អាស្រ័យហេតុនេះ ធនាគារអភិវឌ្ឍន៍អាស៊ីនិងសមាជិកនៃក្រុមការងារគ្រប់គ្រងធនធានធម្មជាតិលើកសំណើអោយរដ្ឋាភិបាលបង្កើតគណៈកម្មការសំរបសំរួលជលផលសហគមន៍ថ្នាក់ខេត្ត ដែលមានសមាស-ភាពជាភាគីពាក់ព័ន្ធនានា ដើម្បីដោះស្រាយទំនាស់ និងណែនាំការអភិវឌ្ឍន៍កម្មវិធី។ គណៈកម្មការបែបនេះនឹងកសាងជំនុកចិត្តក្នុងចំណោមសមាជិកនានា ដោះស្រាយនូវកង្វល់របស់ប្រជាពលរដ្ឋ និងជំរុញអោយមានការចូលរួមនៅក្នុងការអភិវឌ្ឍន៍មូលដ្ឋានផងដែរ។

## គ្របខ័ណ្ឌភាពស៊ីសង្វាក់គ្នាស្តីពីការគ្រប់គ្រងធនធានធម្មជាតិ

ដូចមានមធ្យោបាយផ្លូវច្បាប់នានាស្តីពីការគ្រប់គ្រងធនធានធម្មជាតិកំពុងត្រូវបាន និងបានបង្កើត មធ្យោបាយទាំងនេះទំនងជាត្រូវអោយមានភាពស៊ីសង្វាក់គ្នា ដើម្បីកុំអោយមានទំនាស់និងកុំអោយមាន ឧបសគ្គចំពោះកិច្ចប្រឹងប្រែងក្នុងការគ្រប់គ្រងធនធានធម្មជាតិរបស់ប្រទេសកម្ពុជា។ ធនាគារអភិវឌ្ឍន៍ អាស៊ីលើកទឹកចិត្តរដ្ឋាភិបាលធ្វើយ៉ាងណាអោយមានសង្គតភាពនៅក្នុងការធ្វើពង្រាងច្បាប់ស្តីពីការគ្រប់ គ្រងធនធានទឹក និងច្បាប់ស្តីពីការគ្រប់គ្រងវិស័យជលផល ហើយច្បាប់ទាំងនេះមានភាពស៊ីសង្វាក់គ្នា ជាមួយច្បាប់ស្តីពីការ គ្រប់គ្រងបរិស្ថានធម្មជាតិ (អនុម័តនៅឆ្នាំ ១៩៩៧)និងស៊ីសង្វាក់ជាមួយច្បាប់ ភូមិបាល (អនុម័តនៅឆ្នាំ ២០០១)និងច្បាប់ព្រៃឈើ (នៅរដ្ឋសភាជាតិ)។

ជាចុងបញ្ចប់ ធនាគារអភិវឌ្ឍន៍អាស៊ីសូមគូសបញ្ជាក់សារជាថ្មីទៀតថា ដីធ្លី ទឹក ព្រៃឈើ និងជលផល មាន សារៈសំខាន់ស្លាប់រស់ និងមានចំណងទាក់ទងគ្នាទៅវិញទៅមកជាមួយធនធានធម្មជាតិ សំរាប់ ប្រទេសកម្ពុជា។ ទំនាក់ទំនងអន្តរកម្មទាំងនេះមានន័យថាវិធីសាស្ត្រគ្រប់គ្រងពេញលេញ និងមាន និរន្តរភាពពិតជាការចាំបាច់បំផុត។ ការធ្លាក់ចុះនូវធនធានទាំងនេះនឹងធ្វើអោយមានបច្ច័យអវិជ្ជមាន ទៅលើធនធានដទៃទៀត។ ធនធានធម្មជាតិទាំងនេះបង្កើតអោយមានប្រាក់ចំណូល និងមានសារៈសំខាន់ ចំពោះការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសកម្ពុជា។ អាស្រ័យហេតុនេះ ការធ្វើអាជីវកម្មចាំបាច់ត្រូវអោយមាន ការរៀបចំផែនការនិងការគ្រប់គ្រងសមស្រប។

ការគប់គ្រងធនធានធម្មជាតិទាំងនេះពុំមែនជាការទទួលខុសត្រូវផ្តាច់មុខរបស់រដ្ឋាភិបាលនោះទេ ពោលគឺ សហគមន៍មូលដ្ឋានមានមុខនាទីយ៉ាងសំខាន់ ហើយការចូលរួមរបស់សហគមន៍ នៅក្នុងការគ្រប់គ្រង ជាការចាំបាច់ ក្នុងការបង្កើនធនធានមនុស្សដែលមានកំរិត និងបន្ថែមសមត្ថភាព ចំពោះរដ្ឋាភិបាល។ ជាចុងបញ្ចប់ ធនាគារអភិវឌ្ឍន៍អាស៊ីធ្វើការសង្កត់ធ្ងន់ថា អភិបាលកិច្ចល្អមានសារៈ សំខាន់ណាស់នៅក្នុង ការគ្រប់គ្រងធនធានធម្មជាតិ ព្រោះថាអភិបាលកិច្ចល្អនេះនឹងជំរុញបន្ថែមនូវ ការវិនិយោគ ផលិតភាព សមធម៌នៃលទ្ធភាពទាញផលនៃពលរដ្ឋក្រីក្រ និរន្តរភាពនៃភោគទ្រព្យរដ្ឋ និង កាត់បន្ថយទំនាស់សង្គម។ នៅពេលណាដែលសំរេចបាននូវចំណុចទាំងនេះ ប្រទេសកម្ពុជានឹងបន្តសំរេចបាននូវគោលដៅរបស់ខ្លួន ក្នុងការលុបបំបាត់ភាពក្រីក្រ។

# បញ្ហានានា
# និងបញ្ហាប្រឈម
# នៅក្នុងការធ្វើវិមជ្ឈការ

កិច្ចប្រជុំក្រុមពិគ្រោះយោបល់ឆ្នាំ ២០០២ នៅប្រទេសកម្ពុជា

*កំណត់ពិភាក្សាគោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី*

# បញ្ហានានានិងបញ្ហាប្រឈមនៅក្នុងការធ្វើវិមជ្ឈការ

ធនាគារអភិវឌ្ឍន៍អាស៊ីសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះសេចក្តីសំរេចរបស់រដ្ឋាភិបាលក្នុងការបង្កើតក្រុមប្រឹក្សាដែលជ្រើសតាំងដោយការបោះឆ្នោតចំនួន ១.៦២១ ឃុំ-សង្កាត់នៅកម្ពុជា។ ការរៀបចំសំរាប់ការបោះឆ្នោតនៅមូលដ្ឋានប្រកបដោយជោគជ័យដែលប្រព្រឹត្តទៅនៅខែកុម្ភៈ ២០០២ ការបង្កើតមូលនិធិឃុំសរុបចំនួន ២០ ពាន់លានរៀលសំរាប់ឆ្នាំ ២០០២ និងការសំរេចបន្តអនុវត្តក្របខ័ណ្ឌច្បាប់ថ្មីសំរាប់រដ្ឋាភិបាលមូលដ្ឋានដែលជាប់ឆ្នោត គឺជាសញ្ញាណមួយយ៉ាងច្បាស់ បង្ហាញអោយឃើញនូវការប្តេជ្ញាចិត្តពិតប្រាកដរបស់រដ្ឋាភិបាល ក្នុងការជំរុញនូវលទ្ធិប្រជាធិបតេយ្យ និងវិមជ្ឈការូបនីយកម្ម។ ការបង្កើតឡើងនូវក្រុមប្រឹក្សាឃុំ-សង្កាត់ដែលជ្រើសតាំងដោយការបោះឆ្នោត ឆ្លងតាមការបោះឆ្នោតដែលមានសន្តិភាព ជាលើកដំបូងនៅក្នុងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាផ្តល់ប្រផ្នូលល្អចំពោះការធ្វើអោយមានសន្តិភាព និង សន្តិសុខ លើកកំពស់កំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ ព្រមទាំងពង្រឹងគណនេយ្យភាព តំលាភាព ភាពដែលអាចទាយទុកជាមុនបាន និងមានការចូលរួមនៅគ្រប់ថ្នាក់។

ប៉ុន្តែទោះជាយ៉ាងនេះក្តី បទពិសោធន៍អន្តរជាតិបង្ហាញថាគ្មានអត្ថប្រយោជន៍ជាសក្តានុពលណាមួយនៃវិមជ្ឈការូបនីយកម្មនឹងហូរជាស្វ័យប្រវត្តិពីការបង្កើតនូវក្រុមប្រឹក្សាឃុំ-សង្កាត់តាមរយៈការបោះឆ្នោតនោះទេ។ មានការប្រថុយប្រថានជាច្រើន ពោលគឺក្រុមប្រឹក្សា នឹងក្លាយទៅជាក្រុមប្រឹក្សាដែលមានអំណាច ពោរពេញទៅដោយការពារផលប្រយោជន៍ផ្ទាល់របស់ខ្លួន ធ្វើការដោយគ្មានស្វ័យភាព ហើយនៅតែពឹងផ្អែកលើគណបក្សនយោបាយជាតិ ឬពឹងផ្អែកលើមន្ត្រីថ្នាក់ខេត្ត ក្រុមប្រឹក្សាឃុំ-សង្កាត់មានមុខនាទីតិចតួចក្នុងការផ្តល់សេវា នឹងមានការគ្រប់គ្រងមូលនិធិរបស់ខ្លួនមិនបានល្អ មានប្រាក់ចំណូលផ្ទាល់តិចតួច និង ពឹងផ្អែកលើប្រាក់បង្វែរពីរដ្ឋាភិបាលកណ្តាល និង-ឬពីថ្នាក់ខេត្ត ហើយប្រាក់ទាំងនោះនឹងបាត់រូប តាមរយៈការទូទាត់ទៅអោយមន្ត្រីក្រុមប្រឹក្សានិងមន្ត្រីនានា។ បទពិសោធន៍ផ្នែកស្ថាប័នក៏ប្រាប់យើងផងដែរថា លទ្ធផលវិជ្ជមាន ឬអវិជ្ជមានអាស្រ័យលើចំណុចពីរយ៉ាង។ ទីមួយគឺអាស្រ័យលើការប្តេជ្ញាជាបន្តពី សំណាក់រដ្ឋាភិបាល ធ្វើយ៉ាងណាអោយប្រាកដថា ក្រុមប្រឹក្សាចូលរួម

វិភាគទានពិតប្រាកដចំពោះការកាត់បន្ថយភាពក្រីក្រ និងមានការចូលរួមសស្រាក់សស្រាំដ៏មានន័យ និងទីពីរ ចំពោះសមភាពផ្នែកពតិមាន ប្រព័ន្ធ នីតិវិធី ធនធាន និងការគាំទ្រ ដែលពលរដ្ឋ ក្រុមប្រឹក្សា និងបុគ្គលិករដ្ឋាភិបាលទទួល ហើយសំខាន់ ណាស់ដែរនោះគឺការទំនាក់ទំនងល្អជាមួយភាគីពាក់ព័ន្ធទាំងអស់។

### បញ្ហាគន្លឹះនិងបញ្ហាប្រឈមនានា

*១. ការប្ដេជ្ញារបស់រដ្ឋាភិបាល*

រដ្ឋាភិបាលបានបង្ហាញអោយឃើញនូវការប្ដេជ្ញាយ៉ាងមុតមាំក្នុងការធ្វើវិមជ្ឈការ។ ធនាគារអភិវឌ្ឍន៍អាស៊ីអាចជំរុញអោយរដ្ឋាភិបាលបន្តរក្សាជំហរនិងរក្សាបាននូវដំណោះស្រាយដែលមានវិន័យ ដើម្បីធ្វើយ៉ាងណាអោយក្រុមប្រឹក្សាសំរេចបាននូវលទ្ធផលជាវិជ្ជមាន និងកំណត់ជាបច្ច័យវិជ្ជមានចំពោះជីវភាពរស់នៅរបស់ពលរដ្ឋសាមញ្ញ។ ការប្ដេជាបែបនេះពុំមែនតំរូវអោយមានតែគោលនយោបាយល្អនិងឆន្ទៈប៉ុណ្ណោះទេ ប៉ុន្តែត្រូវមានការអនុវត្តន៍ល្អផងដែរ។ រដ្ឋាភិបាលត្រូវធ្វើយ៉ាងណាអោយការមានការចូលរួមពិតពីសំណាក់ប្រជាពលរដ្ឋ ដើម្បីកាត់បន្ថយហានិភ័យនៃការធ្លាក់ចូលទៅក្នុងសម្ពាធនយោបាយរបស់រដ្ឋាភិបាល។ ការចូលរួមបែបនេះពុំមែនមានន័យថាគ្រាន់តែអញ្ជើញប្រជាពលរដ្ឋចូលរួមប្រជុំនោះទេ ប៉ុន្តែក៏ត្រូវស្ដាប់នូវអ្វីដែលពលរដ្ឋក្រីក្រមានមតិ។ នៅក្នុងដំណើរនៃ*ការវាយតំលៃភាពក្រីក្រដោយមានការចូលរួម* របស់ធនាគារអភិវឌ្ឍន៍អាស៊ី យើងពិនិត្យឃើញថាការយកចិត្តទុកដាក់ស្ដាប់ក្នុងក្ដីគោរព គឺជាមធ្យោបាយមួយដ៏ល្អ ក្នុងការផ្ដល់សិទ្ធអំណាចដល់ពលរដ្ឋក្រីក្រនិងពលរដ្ឋងាយរងគ្រោះ ដើម្បីអោយពួកគេអាចក្លាយជាដៃគូគន្លឹះសំរាប់ការអភិវឌ្ឍន៍នៅមូលដ្ឋាន និងដើម្បីកាត់បន្ថយភាពក្រីក្រដែលមាននិរន្តរភាព។ ធនាគារអភិវឌ្ឍន៍អាស៊ីយល់ឃើញថាការចូលរួមដ៏មានន័យនេះ និងការបង្កើតអោយមាន ការចូលរួមនេះមានសារៈសំខាន់ខ្លាំងណាស់សំរាប់អនុវត្តន៍បាននូវគោលដៅនៃវិមជ្ឈការូបនីយកម្ម។ ជាងនេះទៅទៀត ហានិភ័យនៃការធ្លាក់ចូលក្នុងសម្ពាធនយោបាយរបស់រដ្ឋាភិបាលនៃពលរដ្ឋ ក៏អាចត្រូវបានកាត់បន្ថយប្រសិនបើពលរដ្ឋក្រីក្រត្រូវបានលើទឹកចិត្តអោយរៀបចំារពារនូវផលប្រយោជន៍របស់ក្រុមខ្លួន។

*២. ការសំរបសំរួលអន្តរក្រសួង*

វិមជ្ឈការរឹងមាំ អាស្រ័យលើការមានមណ្ឌលរឹងមាំ និងមានការទ្រទ្រង់ ដូច្នេះការបង្កើតឡើងនូវ គណៈកម្មការជាតិទ្រទ្រង់ឃុំ-សង្កាត់ (NCSC) ដែលសមស្របនិងទាន់ពេលវេលា។ នៅថ្នាក់ជាតិ គណៈកម្មការជាតិទ្រទ្រង់ឃុំ-សង្កាត់បានធ្វើអោយមានការជឿនលឿននៅក្នុងការដឹកនាំកិច្ចដំណើរការទាំងមូល។ អនុគណៈកម្មការបានចាប់ផ្ដើមដំណើរការ។ កិច្ចការភាគច្រើននៅក្នុងផែនការការងាររបស់គណៈកម្មការជាតិទ្រទ្រង់ឃុំ-សង្កាត់ត្រូវបានសំរេច។ ការបណ្ដុះបណ្ដាលលើកដំបូងចំពោះសមាជិក

ក្រុមប្រឹក្សា បុគ្គលិក និងមន្ត្រីនានា កំពុងតែប្រព្រឹត្តទៅ។ នេះគឺជាសមិទ្ធិផលគួរអោយកត់សំគាល់មួយអំពីពេលវេលានិងធនធានមានកំរិតដែលគណៈកម្មការជាតិទ្រទ្រង់ឃុំ-សង្កាត់បានប្រឈម។ ធនាគារអភិវឌ្ឍន៍អាស៊ីលើកសរសើរនូវសមិទ្ធិផលនេះ។

ប៉ុន្តែទោះជាយ៉ាងនេះក្តី នៅមានភាពទន់ខ្សោយពីរយ៉ាងនៅក្នុងកិច្ចដំណើរការរបស់ គណៈកម្មការជាតិទ្រទ្រង់ឃុំ-សង្កាត់មកទល់ពេលនេះ។ ទីមួយ គណៈកម្មការជាតិទ្រទ្រង់ឃុំ-សង្កាត់នៅមិនទាន់សំរេចបាននូវការសំរបសំរួលអន្តរក្រសួងនៅឡើយ។ ក្រសួងដែលជាប្រធាន អនុគណៈកម្មការជាតិទ្រទ្រង់ឃុំ-សង្កាត់និមួយៗដែលទទួលខុសត្រូវក្នុងការរៀបចំអនុក្រិត្យ ឬប្រកាសនិមួយៗ នៅមាននិន្នាការគ្រប់ដណ្តប់លើដំណើរការរៀបចំសេចក្តីព្រាងនិងលើលទ្ធផល។ ក្រសួងនានាបាននិយាយថាពួកគេមិនសូវរីករាយទេជាមួយនីតិវិធីទាំងឡាយដែលរៀបចំដោយក្រសួងដទៃ ហើយគ្រាន់តែផ្តល់ការឯកភាពនៅក្នុងឱកាសកិច្ចប្រជុំពេញអង្គរបស់គណៈកម្មការជាតិទ្រទ្រង់ឃុំ-សង្កាត់នោះទេ។ នៅមានការជជែកដេញដោលរវាងក្រសួងនានាពាក់ព័ន្ធនឹងគណៈកម្មការជាតិទ្រទ្រង់ឃុំ-សង្កាត់ចំពោះនីតិវិធីថ្មីនិងនីតិវិធីដែលបានកែសំរួលទំនងជាមានសារៈសំខាន់ណាស់។ ជាងនេះទៅទៀតនោះ បញ្ហាសំរបសំរួលកាន់តែមានសារៈសំខាន់បន្ថែមទៀត ចំពោះការពិនិត្យមើលឡើងវិញព្រំដែនសមត្ថកិច្ចដែលនឹងក្លាយជាដំណើរការមួយស្មុគ្រស្មាញតំរូវអោយ មានកិច្ចសហប្រតិបត្តិការនិងសំរបសំរួលទាំងនៅថ្នាក់ជាតិនិងនៅថ្នាក់អនុជាតិ។ *អនុគណៈកម្មការដែនដីនិងទត្សរូបនិយកម្ម* នឹងមានតួនាទីចំបងនៅក្នុងអាណត្តិទីមួយ ក្នុងការកំណត់អំពីមុខងារកសាងផែនការ និងគ្រប់គ្រងការប្រើប្រាស់ដីរបស់ក្រុមប្រឹក្សា និងកំណត់ដែនដីឃុំ-សង្កាត់រួចរាល់សំរាប់ការបោះឆ្នោតអាណត្តិទីពីរនៅឆ្នាំ ២០០៧។

ទីពីរ ទំរង់ដែលត្រូវបានប្រើប្រាស់ចំពោះនីតិវិធីនានាជាច្រើន មានភាពទន់ខ្សោយ។ មានអ្នកផ្តល់ពត៌មានជាច្រើន ក្នុងនោះមានទាំងសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ផងដែរ បានបង្ហាញអោយដឹងថាអនុក្រិត្យ និងប្រកាសភាគច្រើន ជាអនុក្រិត្យនិងប្រកាសមានលក្ខណៈវែងជ្រុល ស្មុគ្រស្មាញជ្រុល មិនច្បាស់លាស់ប្រើប្រាស់ពាក្យខុសៗគ្នាចំពោះវត្ថុតែមួយ ហើយមិនសរសេរជាភាសារខ្មែរ មិនច្បាស់ និងមិនអាចយល់បានស្រួល។ នីតិវិធីខ្លះខ្វះខាតនូវវិធានការដែលមានតំលាភាពច្បាស់លាស់ ខ្វះខាតនូវកាតព្វកិច្ចនិងខ្វះនូវការចាត់ចែងស្តីពីការដាក់ទ័ណ្ឌកម្មនិងលើកទឹកចិត្តក្នុងការជំរុញការអនុវត្តន៍។ ប្រសិទ្ធភាពក្នុងការបណ្តុះបណ្តាលបច្ចុប្បន្ននិងអនាគត និងកិច្ចប្រឹងប្រែងកសាងសមត្ថភាព នឹងគ្រាន់តែមានភាពល្អប្រសើរដូចគុណភាពនៃនីតិវិធីនិងប្រព័ន្ធនានា ដែលសមាជិកក្រុមប្រឹក្សា និងមន្ត្រីនានា កំពុងត្រូវបានបណ្តុះបណ្តាល អោយប្រើប្រាស់។ ក្នុងពេលដែលរដ្ឋបាលមូលដ្ឋានមានទំហំកាន់តែធំ និងកាន់តែរឹងមាំ

ធនាគារអភិវឌ្ឍន៍អាស៊ីសង្ឃឹមថានឹងត្រូវចំណាយពេលនិងយកចិត្តទុកដាក់បន្ថែមទៀតចំពោះទំរង់និង នីតិវិធីទាំងនេះនៅពេលដែលមានការកែសំរួលឡើងវិញក្នុងពេលប៉ុន្មានខែខាងមុខ។

*៣. ការធ្វើអោយមានការរំពឹងទុកមានតថភាព និងមានតុល្យភាពជាមួយតថភាពបច្ចុប្បន្ន*

ទស្សនៈរបស់ធនាគារអភិវឌ្ឍន៍អាស៊ីគឺថាលទ្ធផលជាវិជ្ជមានដែលរំពឹងថាបានមកពីការធ្វើវិមជ្ឈការ នឹងទាមទារពេលវេលាច្រើនដើម្បីសំរេចបាននូវលទ្ធផលបែបនេះ។ យើងមិនរំពឹងថាក្រុមប្រឹក្សា ដែលមានសេវាច្រើន នឹងមានស្វ័យភាពច្រើន មានប្រជាធិបតេយ្យខ្ពស់ នៅចុងអាណត្តិទីមួយនេះទេ ហើយទំនងជាសំរាប់រយៈពេលប៉ុន្មានឆ្នាំខាងមុខផងដែរ។ គោលដៅសំខាន់របស់យើងគឺការ កាត់បន្ថយភាពក្រីក្រ។ ការពង្រឹងអភិបាលកិច្ចមានសារៈសំខាន់ណាស់សំរាប់អភិវឌ្ឍ និងការបន្ថយ ភាពក្រីក្រនៅកម្ពុជា ហើយធនាគារអភិវឌ្ឍន៍អាស៊ីប្តេជ្ញាទាំងស្រុងចំពោះកញ្ចប់វិធានការ ដែល មាននៅក្នុង <u>*ផែនការសកម្មភាពអភិបាលកិច្ច*</u>។ ធនាគារអភិវឌ្ឍន៍អាស៊ីយល់ថាសកម្មភាព និង វឌ្ឍនភាពចំពោះកំណែទំរង់អភិបាលកិច្ចមានសភាពបន្ទាន់។

ប៉ុន្តែទោះជាយ៉ាងនេះក្តី ធនាគារអភិវឌ្ឍន៍អាស៊ីក៏យល់ដឹងផងដែរថាបំរែបំរួលនៅក្នុងរចនាសម្ព័ន្ធនៃ អភិបាលកិច្ច ដូចជាវិមជ្ឈការូបនីយកម្មជាដើម ទាមទារអោយមានពេលវេលាយូរជាងការវិនិយោគ របស់ម្ចាស់ជំនួយភាគច្រើន។ ការងារធ្វើអោយប្រជាពលរដ្ឋយល់ដឹងអំពីអំណាចនិងសមត្ថកិច្ច នៃសិទ្ធនិងភារកិច្ចរបស់ខ្លួន ទោះបីជាពួកគេជាពលរដ្ឋក្តី សមាជិកក្រុមប្រឹក្សាក្តី ឬជាមន្ត្រីរដ្ឋាភិបាល ក្តី ពុំមែនជាកិច្ចការដែលអាចសំរេចបានក្នុងរយៈពេលខ្លីនោះទេ។ ប្រសិនបើរដ្ឋាភិបាលធ្វើយ៉ាងណា អោយមានស្ថេរភាពវឌ្ឍនភាពឆ្ពោះទៅរកលទ្ធផលជាវិជ្ជមានដែលបានមកពីការធ្វើវិមជ្ឈការ ធនាគារអភិវឌ្ឍន៍អាស៊ីមានសេចក្តីសោមនស្សរីករាយ ដោយប្រកាន់យកនូវទស្សនៈរយៈពេលវែង ក្នុងការផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុនិងគាំទ្រផ្នែកបច្ចេកទេសចំពោះដំណើរការធ្វើវិមជ្ឈការ។

អាស្រ័យហេតុនេះ យើងមើលឃើញអាទិភាពកិច្ចការសំរាប់អាណត្តិទីមួយ គឺជាដំបូង បំពាក់ ទស្សនាទាន និងកិច្ចដំណើរការប្រជាធិបតេយ្យនិងបំពាកលកិច្ចដំណើរការក្នុងចំណោមក្រុមប្រឹក្សា និងសមាជិករបស់ខ្លួន។ ទីពីរ កសាងសមត្ថភាពជាតិ ដើម្បីគ្រប់គ្រង និងសំរបសំរួលដំណើរការ នៃការធ្វើវិមជ្ឈការ។ ទីបី យោងទៅតាមច្បាប់និងនីតិវិធីនានាដែលកំណត់អំពីវិធីប្រតិបត្តិការ របស់ក្រុមប្រឹក្សា និងបណ្តុះបណ្តាលអ្នកចូលរួមទាំងអស់។ និងទីបួន ផ្តល់ឱកាសអោយកម្ពុជា ពិចារណាថាតើ ឃុំ-សង្កាត់បែបណា ដែលខ្លួនចង់បាននៅមុនពេលបោះឆ្នោតអាណត្តិទីពីរ។

ធនាគារអភិវឌ្ឍន៍អាស៊ីកំពុងគាំទ្រគំនិតផ្តួចផ្តើមជាច្រើនដើម្បីពង្រឹងវិធានការគណនេយ្យភាពនិង វិធានការប្រឆាំងអំពើពុករលួយនៅថ្នាក់ជាតិ។ យើងមានបំណងធ្វើការតាមដានអំពីវិធីបង្កើតក្រុមប្រឹក្សាដែលជ្រើសតាំងដោយការបោះឆ្នោតអាចបង្កើតឱកាសថ្មីៗធ្វើអោយមានគណនេយ្យភាពពីថ្នាក់ក្រោមមកថ្នាក់លើ និងអោយមានសំលេងរបស់ប្រជាពលរដ្ឋច្បាស់។

*៤. ការបែងចែកធនធាន ការកៀងគរធនធាន និងការសំរបសំរួល*

វិមជ្ឈការូបនីយកម្មដែលមានជោគជ័យទាមទារអោយមានធនធានគ្រប់គ្រាន់និងមានការកសាងសមត្ថភាពចំពោះក្រុមប្រឹក្សាឃុំ-សង្កាត់។ មានបញ្ហាប្រឈមធំពីរនៅទីនេះ គឺ សមធមិ និងការសំរបសំរួលធនធាន។

ដំបូង នៅមុនពេលមានការពិនិត្យមើលសារឡើងវិញនូវព្រំដែនសកម្មភាព ការពឹងផ្អែកច្រើនហួសទៅលើ "ចំណូលផ្ទាល់ខ្លួន" (ចំណូលដែលរកបានមកពីការប្រមូលពន្ធនៅមូលដ្ឋាន) ទំនងជាមានបញ្ហាច្រើន។ ឃុំ-សង្កាត់ទាំងឡាយាដែលមិនអាចរកប្រាក់ចំណូលបានគ្រប់គ្រាន់នឹងមានប្រាក់បន្តិចបន្តួចសំរាប់អភិវឌ្ឍសហគមន៍របស់ខ្លួន អាស្រ័យហេតុនេះពួកគេនឹងបាត់បង់នវជំនឿទុកចិត្តពីពលរដ្ឋរបស់ខ្លួន។ នៅក្នុងបរិបទនេះ ពលរដ្ឋមូលដ្ឋានទំនងជាមើលឃើញអង្គភាពដទៃទៀត (អង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិដទៃ) ដែលមានធនធានប្រសើរជាង ដូចជាការទឹកគិតរបស់គាត់។ ជាលទ្ធផលក្រុមប្រឹក្សានឹងបាត់បង់ភាពស្របច្បាប់និងបាត់បង់ជំនឿទុកចិត្តបន្តិចម្តងៗ ថាជាម៉ាស៊ីនសំរាប់អភិវឌ្ឍមូលដ្ឋាន។ លើសពីនេះទៅទៀត ឃុំ-សង្កាត់ ដែលមានមូលដ្ឋានពន្ធធំ នឹងមានឧត្តមភាពយ៉ាងជាក់ច្បាស់ធៀបនឹងឃុំ-សង្កាត់ដែលមានលទ្ធភាពតិចជាង អាស្រ័យហេតុនេះគំលាតរវាងឃុំ-សង្កាត់នៃប្រភេទទាំងពីរនេះនឹងមានទំហំកាន់តែធំ។ ដើម្បីចៀសវាងការរើសអើងក្នុងលក្ខណៈអវិជ្ជមាន នៅក្នុងប្រព័ន្ធនៃការរៀបចំការបង្វែរប្រាក់សារពើពន្ធ រដ្ឋាភិបាលត្រូវដាក់បញ្ចូលនវបញ្ហាសមធមិនិងភាពខុសគ្នាអំពីភាពក្រីក្រ ។ ចំពោះកិច្ចដំណើរការត្រួតពិនិត្យដែនសកម្មភាព ជំហានដំបូងត្រូវឯកភាពលើសភាពនៃភារកិច្ចដែលត្រូវបានបញ្ចប់។ ធនាគារអភិវឌ្ឍន៍អាស៊ីយល់ថាការពិនិត្យមើលសារឡើងវិញនវអំពីព្រំដែនសកម្មភាពធ្វើជាឱកាសល្អសំរាប់ប្រទេសកម្ពុជាក្នុងការសំរេចថាតើឃុំ-សង្កាត់ប្រភេទណាដែលកម្ពុជាត្រូវការនៅពេលអនាគត ដែលបន្តដោយដំណើរការមួយដើម្បីអនុវត្តការកែប្រែទៅតាមវិធីដែលមានយុត្តិធមិ និងតាមបែបដែលមានតំលាភាព។

ស្តីអំពីទំហំនៃឃុំនិងសង្កាត់ គ្មានចំលើយណាដែលត្រូវ ហើយក៏គ្មានចំលើយណាដែលខុសនោះទេ ។ ក្នុងករណីមួយ ឃុំអាចមានទំហំតូចដែលតំណាងអោយប្រជាពលរដ្ឋតែប៉ុន្មានភូមិតែប៉ុណ្ណោះ។ ក្នុងករណីមួយទៀត ឃុំអាចមានទំហំស្មើស្រុក។ ដូចគ្នាដែរ សង្កាត់អាចមានទំហំតូច ឬអាចត្រូវបានច្របាច់បញ្ចូលគ្នាដើម្បីអោយក្លាយទៅជាអាជ្ញាធរទីក្រុងដែលជ្រើសតាំងដោយការបោះឆ្នោតនៅទីកន្លែងមួយចំនួន។ ឃុំ-សង្កាត់អាចមានសភាពក្នុងទំរង់នៃសភាពទាំងពីរ។ ធនគារអភិវឌ្ឍន៏អាស៊ីពុំមានទស្សនៈថាតើជំរើសណាជាជំរើសប្រសើរសំរាប់កម្ពុជានោះទេ។ ជំរើសទាំងអស់តែងមានចំណុចខ្លាំងនិងចំណុចខ្សោយរបស់វា។ ចំណាប់អារម្មណ៏របស់ធនាគារអភិវឌ្ឍន៏អាស៊ីគឺជួយបង្កធានធានអោយរដ្ឋាភិបាលអោយបង្កើតដំណើរការដែលមានពីរថ្នាក់សំរាប់ការពិនិត្យមើលមើលវិញនូវព្រំដែនសកម្មភាព។ ដំណាក់កាលទីមួយគឺ ដំណើរការមួយដែលបង្កលក្ខណៈអោយប្រទេសកម្ពុជាអោយពិភាក្សាលើជំរើសដទៃសំរាប់ទំហំ កិច្ចដំណើរការនិងធនធានឃុំ-សង្កាត់នាពេលអនាគត។ នៅពេលណាដែលការពិភាក្សានេះមានលក្ខណៈពេញលេញហើយនោះ ហើយលក្ខណៈវិនិច្ឆ័យគន្លឹះ (ចំនួនប្រជាពលរដ្ឋជាមធ្យមក្នុងផ្ទៃក្រលាមួយឯកតា ព្រំដែនធម្មជាតិ ប៉ូលអភិវឌ្ឍន៏ អាជ្ញាធរទីក្រុង ។ល។) ត្រូវបានទទួលការឯកភាព ដំណាក់កាលទីពីរគឺសំរាប់គណៈកម្មការឯករាជ្យ ធ្វើសេចក្តីព្រាងអំពីព្រំដែនថ្មីយោងតាមលក្ខណៈវិនិច្ឆ័យដែលបានឯកភាព ដែលត្រៀមជាស្រេចសំរាប់ពិគ្រោះនិងសំរាប់ធ្វើសេចក្តីសំរេចចិត្ត។ ធនាគារអភិវឌ្ឍន៏អាស៊ីយល់ថានៅពេលដែលមានក្រុមប្រឹក្សាដែលជ្រើសតាំងដោយការបោះឆ្នោត បញ្ហាប្រឈមនានានឹងមានភាពចំរូងចំរាសអាស្រ័យហេតុនេះដំណើរការកសាងផែនការដោយប្រុងប្រយ័ត្ននិងដោយមានតំលាភាពគឺជាបញ្ហាដែលមានសារៈសំខាន់។

ធនាគារអភិវឌ្ឍន៏អាស៊ីមើលឃើញដំណើរការពិនិត្យព្រំដែនសារឡើងវិញថាជាចំណុចស្នូលនៅក្នុងការកំណត់អំពីមុខនាទីអនាគតនៃក្រុមប្រឹក្សា នៅក្នុងក្របខ័ណ្ឌអភិបាលកិច្ចជាតិ ហើយយើងត្រៀមខ្លួនជួយផ្គត់ផ្គង់កិច្ចដំណើរការ ជាមួយម្ចាសលអំណោយដទៃទៀត តាមការចាំបាច់។

ទីពីរ ជាមួយនឹងក្រសួងនិងដៃគូអភិវឌ្ឍន៏ជាច្រើនដែលពាក់ព័ន្ធនៅក្នុងកិច្ចប្រឹងប្រែងធ្វើវិមជ្ឈការ ការសំរបសំរួលដែលមានប្រសិទ្ធភាពគឺជាបញ្ហាសំខាន់។ សព្វថ្ងៃមានទីភ្នាក់ងារមួយចំនួនគាំទ្រដោយផ្ទាល់ចំពោះ NCSC និងលេខាធិការដ្ឋាន NCSC; DoLA (ADB, GTZ, KAF, NZODA, UNDP) និងដៃគូដទៃទៀតដែលកំពុងធ្វើការអំពីការធ្វើវិមជ្ឈការជាមួយក្រសួងនានានៃ NCSC ។ ទស្សនៈរបស់ធនាគារអភិវឌ្ឍន៏អាស៊ីគឺថា កិច្ចប្រឹងប្រែងរបស់ពួកគេទាំងនោះត្រូវតែត្រូវបានសំរបសំរួលអោយបាន

ច្បាស់លាស់នៅក្នុងក្របខ័ណ្ឌនៃផែនការការងារទោលរបស់ DoLA រួមមានការរៀបចំផែនការការងាររបស់ NCSC ហើយធនាគារអភិវឌ្ឍន៍អាស៊ីកំពុងធ្វើការងារដើម្បីសំរេចបាននូវចំណុចនេះ។ យើងសូមស្វាគមន៍គំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាលក្នុងការសំរេចនូវការកសាងផែនការនិងការងារសំរបសំរួលអន្តរក្រសួង តាមរយៈការបង្កើតឡើងនូវ NCSC ។

យើងមានជំនឿថា NCSC ចាំបាច់ត្រូវធ្វើការឆ្ពោះទៅកាន់កញ្ចប់សកម្មភាពពេញលេញនិងដែលមានការឯកភាព ដែលចាំបាច់ត្រូវប្រកាន់យក យ៉ាងហោចណាស់សំរាប់អាណត្តិក្រុមប្រឹក្សាលើកទីមួយរហូតដល់ឆ្នាំ ២០០៧ ដែរ។ សកម្មភាពចាំបាច់ជាច្រើនមានលក្ខណៈច្បាស់លាស់រួចហើយ ប៉ុន្តែនៅមានបញ្ហាពិបាកដែលតំរូវអោយមានដំណោះស្រាយ។ ផែនការសកម្មភាពពេញលេញដែលបានព្រមព្រៀងសំរាប់ការធ្វើវិមជ្ឈការនឹងធ្វើអោយកិច្ចការនេះមានលក្ខណៈកាន់តែងាយស្រួលចំពោះម្ចាស់ជំនួយក្នុងការសំរបសំរួលការងាររបស់ខ្លួន ដោយចៀសវៀងនូវការធ្វើកិច្ចការជាន់គ្នា និងធ្វើយ៉ាងណាអោយកិច្ចការសំខាន់ៗបានទទួលធនធានបានត្រឹមត្រូវ។ នៅក្នុងបរិបទនេះ ធនាគារអភិវឌ្ឍន៍អាស៊ីសង្ឃឹមយ៉ាងកក់ក្តៅក្នុងការមើលឃើញនូវអន្តរជាតិភាវូបនីយកម្មនៃកម្មវិធីសិលាទៅក្នុងរចនាសម្ព័ន្ធរបស់រដ្ឋាភិបាលនៅឆ្នាំ ២០០៥។

## អនាគតៈ រដ្ឋាភិបាលដែលត្រូវបានដឹកនាំ ដោយមានការគាំទ្រពីម្ចាស់ជំនួយត្រូវបានសំរបសំរួលបានល្អ

កិច្ចអភិវឌ្ឍន៍ជាច្រើននៅកម្ពុជានៅមានឥទ្ធិពលយ៉ាងច្រើនពីសំណាក់ម្ចាស់ជំនួយ។ ទស្សនៈរបស់ធនាគារអភិវឌ្ឍន៍អាស៊ីគឺថាកំណែទំរង់អភិបាលកិច្ចមិនអាចធ្វើឡើងទៅតាមការដឹកនាំរបស់ម្ចាស់ជំនួយនោះទេ ពោលគឺមានតែពលរដ្ឋកម្ពុជាតែប៉ុណ្ណោះ ដែលអាចសំរេចថាតើពួកគេចង់អោយប្រទេសកម្ពុជាត្រូវបានគេគ្រប់គ្រងយ៉ាងដូចម្តេច។ ការប្តេជ្ញារបស់ធនាគារអភិវឌ្ឍន៍អាស៊ីក្នុងការគាំទ្រការធ្វើវិមជ្ឈការទទួលឥទ្ធិពលយ៉ាងច្រើនពីការប្តេជ្ញាផ្នែកនយោបាយនិងហិរញ្ញវត្ថុរបស់រដ្ឋាភិបាលចំពោះការបោះឆ្នោតឃុំ-សង្កាត់និងចំពោះដំណើរការវិមជ្ឈការូបនីយកម្ម។ ធនាគារអភិវឌ្ឍន៍អាស៊ីសង្ឃឹមយ៉ាងមាំថារដ្ឋាភិបាលនឹងបន្តឈានមុខក្នុងការធ្វើវិមជ្ឈការនិងដឹកនាំការងារនេះឆ្ពោះទៅមុខ ដូចដែលខ្លួនបានធ្វើនិងទទួលជោគជ័យយ៉ាងច្រើននៅក្នុងរយៈពេលដប់ប្រាំបីឆ្នាំកន្លងមក។

កាលពីឆ្នាំកន្លងទៅ ធនាគារអភិវឌ្ឍន៍អាស៊ីបានចាប់ផ្តើមជួយ MoI-DoLA ក្នុងឋានៈជាលេខាធិការដ្ឋានចំពោះNCSC ដើម្បីពង្រឹងការសំរបសំរួលជាមួយម្ចាស់ជំនួយ។ យើងសង្ឃឹមថាកិច្ចសំរបសំរួលនេះនឹង

បន្ត ដោយមានកិច្ចប្រជុំតុមូលជាទៀងទាត់ ដែលរៀបចំដោយ DoLA ។ ការប្តេជ្ញាផ្នែកជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៏អាស៊ីចំពោះ MoI-DoLA នឹងត្រូវបានសំរបសំរួលដោយពេញលេញជាមួយនឹងការងារនៃដៃគូដទៃទៀតដែលកំពុងដំណើរការ ។ ធនាគារអភិវឌ្ឍន៏អាស៊ីពាក់ព័ន្ធជាមួយការងារមួយចំនួនជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាប់ទាំងការរៀបចំ *ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម* (MTEF) និង *កម្មវិធីជំនួយសហប្រតិបត្តិការបច្ចេកទេស* (TCAP) និងស្វែងរកការធ្វើយ៉ាងណាអោយបញ្ហាវិមជ្ឈការូវបនីយកម្មសារពើពន្ធ គិតទាំងការផ្ទេរការគ្រប់គ្រងនិងការរៀបចំកិច្ចការចំណូលនៅមូលដ្ឋានត្រូវបានផ្សារភ្ជាប់បានល្អ ។ ធនាគារអភិវឌ្ឍន៏អាស៊ីក៏ស្វះស្វែងធ្វើយ៉ាងណាអោយការគាំទ្ររបស់ខ្លួនចំពោះការអភិវឌ្ឍន៏យុទ្ធសាស្រ្តតាមផ្នែកនិងការវិនិយោគនៅក្នុងផ្នែកសេវាសំខាន់ៗ ត្រូវបានសំរបសំរួលបានល្អ ជាមួយនឹងកំណែទំរង់វិមជ្ឈការូបនីយកម្មនិងកិច្ចប្រឹងប្រែងរបស់ដៃគូអភិវឌ្ឍន៏ដទៃទៀត ។

សរុបមក ទស្សនៈរបស់ធនាគារអភិវឌ្ឍន៏អាស៊ីគឺថា ការប្តេជ្ញាជាបន្តរបស់រដ្ឋាភិបាល ដែលគាំទ្រដោយជំនួយបច្ចេកទេសនិងហិរញ្ញវត្ថុដែលត្រូវបានសំរបសំរួលល្អ នៅក្នុងក្របខ័ណ្ឌវិមជ្ឈការូបនីយកម្មរួម អាចរួមគ្នាធ្វើអោយប្រាកដថាវិមជ្ឈការូបនីយកម្មជួយសំរេចបាននូវការកាត់បន្ថយភាពក្រីក្រ អោយសំរេចបាននូវការចូលរួម និងអោយសំរេចបាននូវអភិបាលកិច្ចល្អ ។

# ស្ថានភាព
# នៃយុទ្ធសាស្ត្រជាតិ
# កាត់បន្ថយភាពក្រីក្រ

កិច្ចប្រជុំក្រុមពិគ្រោះយោបល់ឆ្នាំ ២០០២ នៅប្រទេសកម្ពុជា

*កំណត់ពិភាក្សាគោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី*

# ស្ថានភាពនៃយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ

ធនាគារអភិវឌ្ឍន៍អាស៊ីពិតជាមានមោទនភាពណាស់ ដោយខ្លួនមានឱកាសធ្វើជាដៃគូមួយរបស់រដ្ឋាភិបាល ក្នុងការជួយកសាងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រដូចមានចែងនៅក្នុង *ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ២០០១-២០០៥* (SEDP II) ។ យើងសូមលើកសរសើររដ្ឋាភិបាលដោយបានបង្កើតនូវជំរើសដ៏ជាក់ច្បាស់មួយចំនួន និងដោយបានដាក់ចេញនូវអាទិភាពនានាសំរាប់ធ្វើសកម្មភាព ។ យើងក៏មានសេចក្តីរីករាយដោយបានឃើញការរៀបចំ *ឯកសារជាយុទ្ធសាស្ត្រសំរាប់កាត់បន្ថយភាពក្រីក្រ* (PRSP) កំពុងត្រូវបានប្រកាន់យកតទៅទៀត ។ ជាលើកដំបូងបង្អស់ ប្រការនេះនឹងអនុញ្ញាតិអោយមានការគិតគូរអំពីចំណាយនៃកម្មវិធីឆ្ពោះទៅរកការកាត់បន្ថយភាពក្រីក្រ និងត្រូវបានដាក់បញ្ចូលទៅក្នុងដំណើរការនៃការកសាងផែនការថវិការបស់រដ្ឋាភិបាល ។ កិច្ចប្រឹងប្រែងចំពោះ*ការពិនិត្យឡើងវិញនូវចំណាយសាធារណៈ* អំពីបញ្ហានេះនឹងអនុញ្ញាតអោយការកំណត់អត្តសញ្ញាណនៃការបែងចែកថវិកានិងធនធានចំពោះវិស័យសាធារណៈផ្តោតទៅលើអ្នកក្រីក្រ រួចហើយដាក់បញ្ចូលទៅក្នុងថវិកាប្រចាំឆ្នាំរបស់រដ្ឋាភិបាល និងបញ្ចូលទៅក្នុង *ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម* (MTEF) ។

## គំនិតផ្តួចផ្តើមអំពីការកាត់បន្ថយភាពក្រីក្រ

យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់រដ្ឋាភិបាលមានភាពស៊ីសង្វាក់គ្នាជាមួយយុទ្ធសាស្ត្រផ្ទាល់របស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែលផ្អែកលើកំណើនសេដ្ឋកិច្ចដែលផ្តោតលើអ្នកក្រីក្រ ផ្តោតលើការអភិវឌ្ឍន៍សង្គម និងផ្តោតលើអភិបាលកិច្ចល្អ ។ កំណើនសេដ្ឋកិច្ចគឺជាល័ក្ខខ័ណ្ឌជាមូលដ្ឋានដំបូងសំរាប់កាត់បន្ថយភាពក្រីក្រ ។ ដូចមានចែងនៅក្នុង SEDP II ប្រការនេះចាំបាច់ត្រូវតែមានតុល្យភាពជាមួយគោលនយោបាយផ្តោតទៅលើអ្នកក្រ ។ ប្រសិនបើគ្រាន់តែមានកំណើនសេដ្ឋកិច្ច គឺនៅមិនទាន់គ្រប់គ្រាន់សំរាប់កាត់បន្តនៅមិនទាន់គ្រប់គ្រាន់សំរាប់កាត់បន្ថយភាពក្រីក្រនៅឡើយទេ ហើយក៏នឹងសំរេចមិនបាននូវគោលដៅកាត់បន្ថយភាពក្រីក្ររបស់រដ្ឋាភិបាលដែរ ។ ចាំបាច់ត្រូវមានគោលនយោបាយជាក់លាក់ផ្តោតទៅលើអ្នកក្រ ដើម្បីអោយអ្នកក្របានទទួលភាគផលពីកំណើនសេដ្ឋកិច្ច ។ យុទ្ធសាស្ត្ររបស់រដ្ឋាភិបាល

ផ្តោតលើគោលនយោបាយទាំងនេះនៅក្នុងវិស័យអាទិភាពចំនួនបួនគឺ សុខាភិបាល អប់រំ កសិកម្ម និង អភិវឌ្ឍន៍ជនបទ។ យើងសូមជំរុញរដ្ឋាភិបាលអោយរក្សាការប្តេជ្ញារបស់ខ្លួនក្នុងការការពារការចំណាយនៅក្នុងវិស័យទាំងនេះតាមរយៈយន្តការ *កម្មវិធីសកម្មភាពអាទិភាព* ។

ធនាគារអភិវឌ្ឍន៍អាស៊ីយល់ថាអន្តរាគមន៍ទូលំទូលាយទៅលើប្រព័ន្ធអាចទាមទារនូវពេលវេលាវែង ដើម្បីបង្ហាញអោយឃើញឥទ្ធិពលច្រើនទៅលើភាពក្រីក្រ។ យុទ្ធសាស្ត្ររយៈពេលមធ្យមទាំងនេះ ចាំបាច់ត្រូវបំពេញបន្ថែមដោយកម្មវិធីកាត់បន្ថយភាពក្រីក្រជាក់លាក់ដោយឆាប់រហ័សនិងដោយមានការប្រុងប្រយ័ត្ន។ ការលើកកំពស់ដែលកំពុងប្រព្រឹត្តទៅនៅក្នុងការកំណត់មុខសញ្ញាភាពក្រីក្រនិងប្រព័ន្ធពតិមានតាមដាន ផ្តល់នូវមូលដ្ឋានគ្រឹះផ្នែកស្ថាប័នយ៉ាងច្រើនចំពោះវិធានការបែបនេះ។ អន្តរាគមន៍ដែលអាចប្រព្រឹត្តទៅបានរួមមានបញ្ជីកំណត់តំលៃប្រើប្រាស់សេវាសុខាភិបាលនិងសេវាគ្លីនិកថែទាំសុខភាព ការចូលរួមកាន់តែច្រើននៃសង្គមស៊ីវិលនៅក្នុងការផ្តល់សេវាសុខាភិបាលនិងអប់រំសុខភាពនៅតាមសហគមន៍ក្រីក្រ និងការលើកទឹកចិត្តដែលផ្តោតទៅលើកុមារមកពីគ្រួសារក្រីក្រអោយចូលរៀននៅសាលាមធ្យមសិក្សានិងឧត្តមសិក្សា។

យើងក៏សូមគូសបញ្ជាក់ផងដែរនូវសារៈសំខាន់នៃគោលនយោបាយនិងផែនការវិមជ្ឈការរបស់រដ្ឋាភិបាលថាជាផ្នែកមួយដ៏មានសារៈសំខាន់នៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់ខ្លួន។ យើងទទួលស្គាល់កិច្ចប្រឹងប្រែងដែលរដ្ឋាភិបាលបានធ្វើនៅក្នុងការធ្វើវិមជ្ឈការការគ្រប់គ្រងថវិកាសេវាសង្គមនៅក្នុងរយៈពេលពីរឆ្នាំកន្លងមក។ ប្រការនេះធ្វើអោយទំហំនៃគណនេយ្យភាពនៅគ្រប់ថ្នាក់កាន់តែមានភាពទូលំទូលាយបន្ថែមទៀត ហើយផ្តល់នូវការកសាងសមត្ថភាពក្នុងពេលធ្វើការងារ។ ធនាគារអភិវឌ្ឍន៍អាស៊ីមើលឃើញឱកាសជាបន្តទៅទៀតនៅបណ្តាឆ្នាំខាងមុខសំរាប់ធ្វើការសាកល្បងការចូលរួមនៃក្រុមប្រឹក្សាឃុំ-សង្កាត់នៅក្នុងការងារសំរបសំរួល និងក្នុងការពិនិត្យមើលសេវាសាធារណៈមួយចំនួន។ ការសាកល្បងបែបនេះអាចជួយធ្វើអោយកៀងគរបាននូវសំលេងប្រជាពលរដ្ឋក្នុងការតាមដានគុណភាពសេវាសាធារណៈ និងបង្កើតនូវអ្វីដែលហៅថាគណនេយ្យភាពទៅវិញទៅមករវាងសហគមន៍និងសេវាសាធារណៈ។

ដូចដែលបានទទួលស្គាល់រួចហើយថា អភិបាលកិច្ចមិនល្អ ហើយជាពិសេសអំពើពុករលួយ មានផលប៉ះពាល់ជាអវិជ្ជមានមកលើពលរដ្ឋក្រីក្រ។ រងគ្រោះដោយផ្ទាល់ ដោយសារតែឥទ្ធិពលអវិជ្ជមាន នៃកំណើនសេដ្ឋកិច្ច និងនៃចំណូលរដ្ឋាភិបាល ហើយរងគ្រោះដោយប្រយោល ដោយសារពលរដ្ឋក្រីក្រនឹងក្លាយជាពលរដ្ឋងាយរងគ្រោះបំផុតចំពោះការផ្តល់សេវាមិនបានល្អ និងការប្រព្រឹត្តអំពើពុករលួយ។ យើង

ត្រូវបានលើកទឹកចិត្តដោយសារដំណោះស្រាយសារជាថ្មីរបស់រដ្ឋាភិបាលចំពោះបញ្ហានេះ។ ទោះជាយ៉ាងនេះក្តី យើងនឹងជំរុញអោយរដ្ឋាភិបាលអោយប្រកាន់យកដោយពិតប្រាកដនូវការអនុវត្តនីវិធានការដែលបានលើកឡើង។ ការអនុវត្តន៍នូវយុទ្ធសាស្រ្តកាត់បន្ថយភាពក្រីក្រណាមួយ នឹងគ្មានបានផលអ្វីទេ ប្រសិនបើការងារនោះមិនមានការគាំទ្រយ៉ាងច្បាស់លាស់ពីវិធានការប្រឆាំងអំពើពុករលួយទេនោះ។

ដើម្បីសំរេចបាននូវគោលដៅកាត់បន្ថយភាពក្រីក្ររបស់រដ្ឋាភិបាល ជាការសំខាន់ណាស់ដែលការអនុវត្តន៍ SEDP II និង PRSP ត្រូវបានតាមដានអោយបានជិតដល់ ដើម្បីអោយសកម្មភាពកែតំរូវអាចធ្វើបានដោយទាន់ពេលវេលា ប្រសិនបើមានការចាំបាច់។ យើងមានសេចក្តីរីករាយចំពោះវត្តមានដែលទើបកើតមាននៃប្រព័ន្ធតាមដានមួយ។ ប្រព័ន្ធតាមដានដែលមានភាពពេញលេញ គប្បីមានបីផ្នែក។ ទីមួយគឺការតាមដាននិងការសំរបសំរួលលើការអនុវត្តន៍គោលនយោបាយ។ ពាក់ព័ន្ធនឹងចំណុចនេះ ឧត្តមក្រុមប្រឹក្សាជាតិមានតួនាទីសំខាន់ណាស់។ ផ្នែកទីពីរគឺការតាមដានការចំណាយសាធារណៈ ធ្វើយ៉ាងណាអោយមូលនិធិត្រូវបានចំណាយទៅលើផ្នែកអាទិភាពនានា។ ការបង្កើតឡើងនូវ MTEF នឹងធ្វើអោយមានចំណងទាក់ទងច្បាស់លាស់និងមានភាពសង្វាក់គ្នារវាង SEDP II/ PRSP និងថវិកា។ ផ្នែកទីបីគឺការតាមដានផលប៉ះពាល់នេះទៅលើជីវភាពរស់នៅជាក់ស្តែងរបស់ប្រជាពលរដ្ឋ។ កិច្ចសហការរវាងអាជ្ញាធរមូលដ្ឋាន ដូចជាក្រុមប្រឹក្សាឃុំ-សង្កាត់ដែលទើបត្រូវបានបង្កើតកាលពីពេលថ្មីៗ មានសារៈសំខាន់ណាស់។ យើងមានសេចក្តីរីករាយជាមួយនឹងគំនិតផ្តួចផ្តើមក្នុងការរៀបចំប្រព័ន្ធតាមដានភាពក្រីក្រដែលមានការចូលរួម ដោយមានការគាំទ្រពី UNDP ។ ប្រការនេះនឹងបំពេញអោយការវាយតំលៃភាពក្រីក្រ ដែលបានគ្រោងទុកនៅក្នុងអនាគត។ ជាការចាំបាច់ណាស់ដែលផ្នែកទាំងបីនេះត្រូវបានត្រូវធ្វើអោយមានការសំរបសំរួលដោយជិតស្និទ្ធជាមួយគ្នា។

## ប្រធានបទពិភាក្សាពិសេសៈ កង្វល់អំពី HIV/AIDS និងបញ្ហាយិនឌ័រ

យើងលើកសរសើររដ្ឋាភិបាលចំពោះវឌ្ឍនភាពដែលប្រទេសកម្ពុជាបានធ្វើនៅក្នុងការប្រយុទ្ធជាមួយ HIV/AIDS ។ ទោះបីជាប្រទេសកម្ពុជាមានអត្រាឆ្លងមេរោគអេដស៍ខ្ពស់ជាងគេនៅក្នុងតំបន់ក្តី កម្ពុជាបានធ្វើអោយមានវឌ្ឍនភាពប្រកបដោយស្មេរភាពក្នុងការលើកកំពស់ការយល់ដឹងអំពីគ្រោះថ្នាក់នៃជំងឺ HIV/AIDS ដែលធ្វើអោយឃើញមានការធ្លាក់ចុះនូវករណីនៃការចំលងរោគនេះគួរអោយកត់សំគាល់។ សមិទ្ធិផលនេះត្រូវបានគេទទួលស្គាល់នៅលើពិភពលោក។

ទោះបីជាកម្ពុជាសំរេចបានគួរអោយសរសើរក្នុងការប្រយុទ្ធជាមួយ HIV/AIDS ក្តី នៅមានការងារបន្ថែមទៀតដែលត្រូវធ្វើ។ HIV/AIDS មានឥទ្ធិពលដ៏ធំធេងចំពោះការបំផ្លិចបំផ្លាញអាយុជីវិតជនរងគ្រោះនិងគ្រួសាររបស់ខ្លួន។ ការវាយតំលៃកាលពីពេលថ្មីៗកន្លងទៅនេះរបស់បណ្តាញថែទាំរបស់កម្ពុជានៅតាមផ្ទះសម្បែង បានរកឃើញថា ៤០ % នៃកុមារនៅក្នុងគ្រួសារដែលរងគ្រោះដោយ HIV/AIDS ត្រូវបានបង្ខំអោយរស់នៅដោយគ្មានអាហារនិងតំរូវការដទៃទៀតបានគ្រប់គ្រាន់ទេ។ ប្រសិនបើគ្មានការឧបត្ថម្ភគាំទ្រពីខាងក្រៅចំពោះគ្រួសារដែលរងគ្រោះដោយជំងឺអេដស៍ទេនោះ កុមារ ជាពិសេសក្មេងស្រីនឹងត្រូវបញ្ឈប់លែងអោយរៀនសូត្រ ដោយសារកាត់បាត់បង់ប្រាក់ចំណូលដែលបណ្តាលមកពីជំងឺតម្កាត់និងមរណៈភាពក៏ដូចជាចំណាយក្នុងការថែទាំសុខភាព។ ការវាយតំលៃដូចគ្នានេះបានរកឃើញថាកុមារ ៤០% ក្នុងគ្រួសារដែលរងគ្រោះដោយសារជំងឺអេដស៍ ចាំបាច់ត្រូវឈប់រៀន ហើយ ២១% ចាំបាច់ត្រូវធ្វើការ។ តំរូវការក្នុងការជួយធ្វើការគ្រួសារនិងរកប្រាក់ចំណូលអោយគ្រួសារនឹងកើនឡើង ដោយហេតុថាបុរស ស្ត្រី ជាយុវជនក្មេងៗបានឆ្លងជំងឺនេះ ហើយពួកគេនឹងស្លាប់។

ជំងឺនិងការស្លាប់ក្នុងចំណោមយុវជនក្មេងៗដោយសារ HIV/AIDS នៅកម្ពុជា ដោយគ្មានអន្តរាគមន៍គាំទ្រពីខាងក្រៅ នឹងធ្វើអោយគ្រួសារដែលមានភាពក្រីក្រឈានទៅរកភាពទីទ័ល។ ប្រាក់សន្សំបន្តិចបន្តួចដែលគ្រួសារមាន ត្រូវបានចំណាយយ៉ាងរហ័ស ហើយទ្រព្យសម្បត្តិនានាត្រូវបានលក់ដើម្បីយកលុយមកព្យាបាលជំងឺ។ ការសិក្សាស្រាវជ្រាវមួយនៅក្នុងភូមិចំនួន ១៤៥ នៅក្នុងខេត្តចំនួន ១៥ បានបង្ហាញអោយឃើញថាការបាត់បង់ដីធ្លីបានកើនឡើងយ៉ាងច្រើននៅកម្ពុជា។ ក្នុងចំណោមគ្រួសារដែលមានដីធ្លី ប៉ុន្តែបានបាត់បង់ដី មានគ្រួសារចំនួន ៤០% ដែលបានរាយការណ៍ថាការលក់ដី គឺបណ្តាលមកពីសមាជិកគ្រួសារមានជំងឺ។

ធនាគារអភិវឌ្ឍន៏អាស៊ីផ្តល់នូវសារៈសំខាន់កាន់តែខ្លាំងឡើងៗនៅក្នុងកម្មវិធីផ្ទាល់របស់ខ្លួនចំពោះការអភិវឌ្ឍន៏ហេដ្ឋារចនាសម្ព័ន្ធ។ នៅក្នុងក្របខ័ណ្ឌនៃការវិនិយោគរបស់ខ្លួន ធនាគារអភិវឌ្ឍន៏អាស៊ីចំណាយលើហេដ្ឋារចនាសម្ព័ន្ធសង្គមប្រមាណជា ២៥% នៃកម្មវិធីសរុប ដោយទឹកប្រាក់ផ្តល់ឥណទានសរុបចាប់តាំងពីពេលអោយខ្ចីក្នុងរយៈពេលដប់ឆ្នាំកន្លងមកនេះ មានចំនួនប្រហែល ១៤០ លានដុល្លារ។ ធនាគារអភិវឌ្ឍន៏អាស៊ីមានការវិនិយោគដែលកំពុងដំណើរការនៅក្នុងការអភិវឌ្ឍន៏ហេដ្ឋារចនាសម្ព័ន្ធសង្គម តាមរយៈកម្មវិធីអភិវឌ្ឍន៏វិស័យអប់រំរបស់ខ្លួន និងតាមរយៈការផ្តល់អាហារូបករណ៏ចំពោះសិស្សជាស្ត្រីភេទក្រីក្រនិងចំពោះជនជាតិភាគតិច និងនៅក្នុងវិស័យសុខភាពបឋម ចាប់តាំងពីឆ្នាំ ១៩៩៥ មក។ ការឧបត្ថម្ភគាំទ្រក៏ត្រូវបានផ្តល់ផងដែរតាមរយៈជំនួយបច្ចេកទេសប្រចាំតំបន់ (រួមមាន ប្រទេសកម្ពុជា

សាធារណៈរដ្ឋប្រជាមានិតុឡាវ និងប្រទេសវៀតណាម) ពី *មូលនិធិរបស់ជប៉ុនក្នុងការកាត់បន្ថយភាពក្រីក្រ* សំរាប់ការបង្កាជំងឺអេដស៍ដោយពឹងផ្អែកលើសហគមន៍ និងតាមរយៈគំរោងសុខភាពជាមូលដ្ឋានថ្មីរបស់ធនាគារអភិវឌ្ឍន៍អាស៊ី សំរាប់រយៈពេលប្រាំឆ្នាំខាងមុខ ដែលនឹងចាប់ផ្តើមនៅឆ្នាំ ២០០៣ ដែលនឹងមានផ្នែកជំងឺអេដស៍យ៉ាងច្រើន។

ធនាគារអភិវឌ្ឍន៍អាស៊ីមានការឈឺចាប់ដោយបានដឹងថាស្ត្រីនៅប្រទេសកម្ពុជាមានភាពមិនអំណោយផលច្រើនជាងបុរស ពោលគឺៈ បានទទួលសេវាសុខាភិបាល និងការអប់រំបានតិចតួច (ជាពិសេសគឺនៅថ្នាក់ខ្ពស់ផ្នែកអប់រំ) ការធ្វើការងារមានប្រាក់បំណាច់ (នៅប្រភេទថ្នាក់ខ្ពស់នៃលំដាប់វិជ្ជាជីវៈ) កម្មសិទ្ធដីធ្លី និងមានឱកាសតិចតួចក្នុងការចូលរួមផ្នែកដំណើរការនយោបាយនិងអភិវឌ្ឍន៍។ នៅក្នុងកាលៈទេសៈបែបនេះ ស្ត្រីមានភាពងាយរងគ្រោះចំពោះភាពក្រីក្រ។ ធនាគារអភិវឌ្ឍន៍អាស៊ីបានផ្តល់ការគាំទ្រចំពោះការកសាងសមត្ថភាព ដើម្បីលើកកំពស់ស្ថានភាពស្ត្រីនៅកម្ពុជាចាប់ពីឆ្នាំ ១៩៩៦ មក។ នៅពេលដ៏ខ្លីខាងមុខនេះ ធនាគារអភិវឌ្ឍន៍អាស៊ីក៏នឹងគាំទ្រក្រសួងកិច្ចការនារីនិងអតីតយុទ្ធជនក្នុងការជំរុញអោយមានឱកាសការងារសំរាប់ស្ត្រីនិងការរៀបចំគោលនយោបាយ។ តំរូវការពិសេសរបស់ស្ត្រីនិងពលរដ្ឋងាយរងគ្រោះត្រូវបានយកទៅដាក់បញ្ចូលទៅក្នុងការរៀបចំនិងការអនុវត្តន៍កម្មវិធីនិងគំរោងរបស់ ធនាគារអភិវឌ្ឍន៍អាស៊ីអោយបានច្រើនតាមដែលអាចធ្វើទៅបាន។

សរុបមក មានការទទួលស្គាល់ថាអន្តរាគមន៍ដាច់តែឯងទំនងជាមិនសូវមានប្រសិទ្ធភាពទេ លុះត្រាតែមានកិច្ចប្រឹងប្រែងស្របគ្នាដើម្បីផ្តោតទៅលើបញ្ហាយិនឌ័រ ដោះស្រាយកំណែទំរង់អភិបាលកិច្ច និងបូកសរុបកំលាំងចំរុះនៃដំណើរការអភិវឌ្ឍន៍ភាពជាដៃគូអោយបានកាន់តែទូលាយ។ ចាំបាច់ត្រូវមានវិធីសាស្ត្រសរុបរួមបញ្ចូលគ្នា ដើម្បីកាត់បន្ថយភាពក្រីក្រអោយមានប្រសិទ្ធភាព។ ធនាគារអភិវឌ្ឍន៍អាស៊ីនឹងបន្តធ្វើការយ៉ាងតំហុកនិងយ៉ាងសកម្មជាមួយរដ្ឋាភិបាល និងជាមួយដៃគូអភិវឌ្ឍន៍ទាំងអស់ លៃយ៉ាងណាអោយជំនួយអភិវឌ្ឍន៍ត្រូវបានដាក់បញ្ចូលនិងទទួលការគាំទ្រទៅក្នុងចក្ខុវិស័យផ្ទាល់របស់រដ្ឋាភិបាល ពោលគឺបញ្ចូលទៅក្នុងយុទ្ធសាស្ត្រនិងកម្មវិធីនានាសំរាប់ការអភិវឌ្ឍន៍ដែលមាននិរន្តរភាព។

# ការអនុវត្តន៍
# លំនាំថ្មី
# នៃភាពជាដៃគូ

# ការអនុវត្តន៍នៃលំនាំថ្មីនៃភាពជាដៃគូ

នៅពេលដែលដៃគូអភិវឌ្ឍន៍ឯកភាពលើលំនាំថ្មីភាពជាដៃគូរបស់រដ្ឋាភិបាលនៅក្នុងកិច្ចប្រជុំពិព្រះយោបល់នៅឆ្នាំ ២០០០ គេបានទទួលស្គាល់ថាគំនិតផ្តួចផ្តើមនេះថាបានបង្ហាញនូវបញ្ហាប្រឈមក៏ដូចជាឱកាសល្អផងដែរ។ បញ្ហាប្រឈមទីមួយគឺការបង្កើតនូវយុទ្ធសាស្ត្រទូលំទូលាយមួយសំរាប់អនុវត្តនូវការរៀបចំអំពីភាពជាដៃគូថ្មីៗ។ ជាកិច្ចឆ្លើយតប រដ្ឋាភិបាលបានបង្ហាញនូវឯកសារពិភាក្សានៅឱកាសកិច្ចប្រជុំក្រុមពិគ្រោះយោបល់នៅឆ្នាំ ២០០១ ដោយបានគូសបញ្ជាក់នូវគោលនយោបាយទូលំទូលាយនិងទិសដៅជាយុទ្ធសាស្ត្រសំរាប់កិច្ចអភិវឌ្ឍន៍ភាពជាដៃគូ រាប់ទាំងករណីសិក្សាលើផ្នែកសុខភាព អប់រំ និងការអភិវឌ្ឍន៍ជនបទ និង ការលើកយកមកពិភាក្សាអំពីបញ្ហាយិនឌ័រ។

## វឌ្ឍនភាពនៅឆ្នាំ ២០០០-២០០២

ធនាគារអភិវឌ្ឍន៍អាស៊ីបានទទួលការលើទឹកចិត្តដោយវឌ្ឍនភាពដែលសំរេចបាននៅចន្លោះឆ្នាំ ២០០០ និង ២០០២។ ភាពជាដៃូដែលដឹកនាំដោយរដ្ឋាភិបាលបានទទួលការចង្អុលទិសដោយ *ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច លើកទី ២ ពីឆ្នាំ ២០០១-២០០៥* (SEDP II) ដែលអនុម័តដោយក្រុមប្រឹក្សារដ្ឋមន្ត្រី ហើយនឹងឯកភាពក្នុងពេលឆាប់ៗខាងមុខដោយសភាជាតិ។ SEDP II ដាក់ចេញនូវការ*ចក្ខុវិស័យជាយុទ្ធសាស្ត្រសំរាប់ធានាអោយមានំណើនសេដ្ឋកិច្ច និងសំរាប់កាត់បន្ថយភាពក្រីក្រ* ដោយបញ្ជាក់យ៉ាងច្បាស់នូវការអភិវឌ្ឍន៍ទូលំទូលាយ និងបញ្ជាក់ច្បាស់អំពីបណ្តាអាទិភាពនានាតាមវិស័យក៏ដូចជាកាតព្វកិច្ចធ្វើហិរញ្ញប្បទានដែលមានលក្ខណៈជាការចង្អុលបង្ហាញ។ ការវិភាគបន្ថែមទៀតក៏បានប្រព្រឹត្តទៅនៅក្នុង *ឯកសារស្តីពីយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ* ដែលនឹងជួយអោយផ្តោតការយកចិត្តទុកដាក់លើភាពក្រីក្រនៅក្នុង SEDP II។ បញ្ហាប្រឈមតលូវនេះគឺចាប់ផ្តើមការអនុវត្តន៍ដោយមានប្រសិទ្ធភាពនូវគោលនយោបាយជាតិសំរាប់កាត់បន្ថយភាពក្រីក្រ នៅក្នុងក្របខ័ណ្ឌនៃលំនាំថ្មីនៃភាពជាដៃគូ។

រដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍នានាទទួលស្គាល់ថាការអនុវត្តន៍គោលការណ៍ថ្មីនៃភាពជាដៃគូ ចាំបាច់ត្រូវដាក់បញ្ចូល និងរៀបចំតាមលំដាប់លំដោយទៅតាមស្ថានភាព និងល័ក្ខខ័ណ្ឌសំរាប់កំណែទំរង់គោលនយោបាយ នៅក្នុងផ្នែកនិងកម្មវិធីផ្សេងៗ។ ឯកសារថ្មីដែលរដ្ឋាភិបាលបានបង្ហាញនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ ស្តីពីភាពជាដៃគូឆ្នាំ ២០០២ បានបង្ហាញយ៉ាងច្បាស់ថាមានការសំរេចបាននូវវឌ្ឍនភាពជាច្រើន។ ឯកសារនេះគួសបញ្ជាក់ថាគ្មានលំនាំទោលតែឯងណាមួយសំរាប់ផ្សាភ្ជាប់ភាពជាដៃគូនោះទេ ដូចជាផ្នែកសុខាភិបាល អប់រំ និងសិលា បានអនុម័តនូវយុទ្ធសាស្ត្រផ្សេងពីគ្នានិងខុសប្លែកពីគ្នា។

ដូចដែលរដ្ឋាភិបាលមានគោលបំណង យុទ្ធសាស្ត្រនៃភាពជាដៃគូនានាទាំងនេះគួសបញ្ជាក់នូវប្រធានបទមួយចំនួនរួមគ្នា គឺ ក) កម្មសិទ្ធភាព ការប្តេជ្ញាត្រូវបានពង្រឹង ហើយធនធានត្រូវបានបែងចែក ខ) គំរូមានភាពងាយបត់បែន គ) លំនាំផ្តោតលើអាទិភាពដែលឯកភាពទៅវិញទៅមកត្រូវបានឈានឡើងមួយកំរិត ឃ) ការកំណត់អត្តសញ្ញាណនិងការញែកមុខងាររបស់ដៃគូ ង) បង្កើនសមត្ថភាពសំរបសំរួលនិងតាមដានថ្នាក់ជាតិ ជាមួយម្ចាស់អំណោយ និងជាមួយអង្គការក្រៅរដ្ឋាភិបាល និង ច) ការដាក់បញ្ចូលអភិបាលកិច្ចល្អនៃកំណែទំរង់រដ្ឋបាលសាធារណៈទៅក្នុងដំណើរភាពជាដៃគូ។

## ការពង្រឹងភាពជាដៃគូ

ធនាគារអភិវឌ្ឍន៍អាស៊ីចាត់ទុកថាក្រោយរយៈពេលពីរឆ្នាំ មានពតិមានគ្រប់គ្រាន់ និងមានមេរៀនសំរាប់រដ្ឋាភិបាលនិងដៃគូនានាចាប់ផ្តើមយកទៅធ្វើជាមូលដ្ឋាន។ ទំនងជាដល់ពេលដែលវិស័យជឿនលឿននានាធ្វើអោយវិធីសាស្ត្ររបស់ខ្លួនមានសុក្រិតភាព។ ទំនងជាដល់ពេលសមស្របចំពោះវិស័យមិនជឿនលឿនទាញយកឧត្តមភាពពីក្រសួងសមភាគីនានា ដើម្បីបោះជំហានទៅមុខស្តីពីការអនុវត្តន៍គោលការណ៍នៃភាពជាដៃគូរបស់រដ្ឋាភិបាល។ ជាការពិតណាស់ ធនាគារអភិវឌ្ឍន៍អាស៊ីនឹងឃើញភាពជាដៃគូ នៃក្រុមការងារអន្តរក្រសួង នឹងឈានមុខក្នុងការបង្កើតដំណើរពិនិត្យមើលឡើងវិញ ដែលមានលក្ខណៈជាប្រព័ន្ធតាមរយៈក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

ទស្សនៈរបស់ធនាគារអភិវឌ្ឍន៍អាស៊ីគឺថា បញ្ហាប្រឈមសំរាប់អភិវឌ្ឍន៍ភាពជាដៃគូគឺទើបតែចាប់ផ្តើមនៅឡើយទេ។ ស្ថានភាពបច្ចុប្បន្នអាចត្រូវបានកត់សំគាល់តាមរយៈការភាពភាពជាដៃគូធូររលុងនៅក្នុងវិស័យភាគច្រើន។ ដំណាក់កាលបន្ទាប់ដែលកាន់តែលំបាកគឺការធ្វើអោយមានភាពជាដៃគូជិតស្និទ្ធ

ជាមួយនិងការចាត់ចែងលើកិច្ចប្រតិបត្តិការដែលបានព្រមព្រៀងគ្នាជាមុន។ ប្រការនេះនឹងរួមមានការដាក់អោយមាននូវការរៀបចំលំអិតសំរាប់អនុវត្តនិងគ្រប់គ្រងយុទ្ធសាស្ត្រភាពជាដៃគូទូលាយ ដែលមានកំណត់នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ក្នុងឆ្នាំ ២០០១។

សក្ខីភាពជាអន្តរជាតិ និងបទពិសោធន៍មុននេះនៅកម្ពុជាបង្ហាញថាការរិតបន្តឹងភាពជាដៃគូ គឺជាបញ្ហាប្រឈមមួយដ៏ពិតប្រាកដ។ កិច្ចការនេះនឹងតំរូវអោយរដ្ឋាភិបាលមាននិរន្តរភាពក្នុងការដឹកនាំ និងការប្តេជ្ញារបស់ខ្លួនចំពោះកំណែទំរង់ពិបាកជារឿយៗ។ កិច្ចការនេះតំរូវអោយរដ្ឋាភិបាលមានវិន័យក្នុងការបែងចែកនិងបើកផ្តល់ធនធាន យោងទៅលើអាទិភាពនានាដែលបានឯកភាព។ កិច្ចការនេះនឹងរួមបញ្ចូលនូវម្ចាស់អំណោយ និងអង្គការក្រៅរដ្ឋាភិបាលដែលមានឆន្ទៈក្នុងការធ្វើអោយរលូននូវនីតិវិធីរបស់ខ្លួននៅក្នុងក្របខ័ណ្ឌដែលបានឯកភាព។ កិច្ចការនោះអាចស្នើអោយម្ចាស់អំណោយ និងអង្គការអោយពិនិត្យមើលដោយចំហនិងដោយស្មោះត្រង់នូវវិសាលភាពសំរាប់គំរូគាំទ្របែបថ្មី និងការរៀបចំតាមដាន ហើយនិងត្រួតពិនិត្យ។ សំខាន់ជាងនេះទៅទៀតនោះគឺ កិច្ចការនេះតំរូវអោយមានជំនឿទុកចិត្តទៅវិញទៅមកនៅក្នុងពេលលំបាកដែលចៀសមិនរួច។

សំខាន់ ការរិតបន្តឹងនិងការដាក់អោយប្រតិបត្តិការនូវការចាត់ចែងភាពជាដៃគូផ្សេងៗ នឹងតំរូវអោយមានការប្តេជ្ញានៅក្នុងរយៈពេលវែង។ ភាពជាដៃគូកាន់តែជិតស្និទ្ធ នឹងតំរូវអោយមានការប្តេជ្ញា ដើម្បីសំរេចបាននូវគោលដៅអភិវឌ្ឍន៍ដែលមាននិរន្តរភាព។ នៅក្នុងចំណោមដៃគូពិតប្រាកដ មានលទ្ធភាពតិចតួចប៉ុណ្ណោះសំរាប់លទ្ធិឯកត្តជននិយម និងលទ្ធិឱកាសនិយម។ សាមគ្គីភាពរវាងរដ្ឋាភិបាល និងម្ចាស់ជំនួយមានសារៈសំខាន់ណាស់ ដែលជាមួយគ្នានោះមានវិធានច្បាស់លាស់និងមានតំលាភាពអំពីការចូលរួមនិងការផ្លាស់ប្តូរទស្សនៈស្មោះត្រង់។ ធនាគារអភិវឌ្ឍន៍អាស៊ីសូមយកឱកាសនេះបញ្ជាក់ឡើងវិញនូវការប្តេជ្ញារបស់ខ្លួនចំពោះភាពជាដៃគូបែបនេះជាមួយរដ្ឋាភិបាល។

## មេរៀនដែលបានរៀនសូត្រ

មេរៀនដ៏សំខាន់មួយគឺថាគោលនយោបាយនិងក្របខ័ណ្ឌយុទ្ធសាស្ត្រដែលបានឯកភាពទៅវិញទៅមក រួមមានមុខសញ្ញាច្បាស់លាស់ គឺជាបុព្វល័ក្ខខ័ណ្ឌ ដើម្បីអោយភាពជាដៃគូមានប្រសិទ្ធភាព។ មេរៀនទីពីរគឺការធានានូវកម្មសិទ្ធជាតិនិងការប្តេជ្ញាចំពោះកំណែទំរង់លំបាកលំបិនមិនត្រូវធ្វើឡើងដោយប្រញាប់ប្រញាល់នោះទេ។ ឧទាហរណ៍ នៅក្នុងការអប់រំ និងសុខាភិបាល ដំណើរអភិវឌ្ឍន៍គោលនយោបាយនេះ

មានរយៈពេលបីឆ្នាំ។ លក្ខណៈដែលពាក់ព័ន្ធនោះគឺ ដំណើរការទាំងនេះអាចត្រូវបានជួយសំរួលដោយម្ចាស់ជំនួយនិងដោយការគាំទ្ររបស់អង្គការក្រៅរដ្ឋាភិបាល ដរាបណាជំនួយបច្ចេកទេសត្រូវបានគេមើលឃើញថាមានភាពអព្យាក្រិត ហើយរដ្ឋាភិបាលយកចិត្តទុកដាក់ឆ្លើយតប ជាជាងមានការណែនាំដោយម្ចាស់ជំនួយ ឬដោយផលប្រយោជន៍នៃអង្គការក្រៅរដ្ឋាភិបាល។ សំខាន់គឺថា ភាពជាដៃគូនៅក្នុងការរៀបចំគោលនយោបាយ ចាំបាច់ត្រូវចៀសវាងនូវ "ការធ្វើអោយរាំងស្ទះ" ដល់អាទិភាពនានារបស់រដ្ឋាភិបាល និងរបស់សង្គមស៊ីវិល។

មេរៀនសំខាន់ទីបី ដែលត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងឯកសារកិច្ចប្រជុំពិគ្រោះយោបល់ឆ្នាំ ២០០១ គឺថា គោលនយោបាយដែលផ្អែកលើ *ផែនការសារពើពន្ធរយៈពេលមធ្យម* (MTEF) ជាការសំខាន់ណាស់។ រាល់តំរូវការរបស់ MTEF ផ្នែកវិស័យ ឬផ្នែករៀបចំកម្មវិធី ដើម្បីដាក់ចេញអោយបានច្បាស់នូវមុខងារជាក់លាក់ និងឧត្តមភាពធៀបរបស់រដ្ឋាភិបាល ម្ចាស់ជំនួយ និងវិស័យឯកជននៅក្នុងការធ្វើហិរញ្ញប្បទានកំណែទំរង់ដែលត្រូវបានលើកសំណើ។ ទស្សនៈរយៈពេលមធ្យមនេះមានសារៈសំខាន់ណាស់ក្នុងការផ្តល់គ្រឿងលើកទឹកចិត្តសំរាប់អោយមានការជឿជាក់លើការកសាងផែនការកំណែទំរង់ឆ្ពោះទៅមុខ ដោយដៃគូនានា។ ការដែលអាចប៉ាន់ស្មានទុកជាមុនបានអំពីធនធានដែលមាន ត្រូវបានបែងចែកដោយសមស្របនិងត្រូវបានបើកផ្តល់ទាន់ពេលវេលា គឺជាផ្នែកមួយសំខាន់ណាស់នៃភាពជាដៃគូជិតស្និទ្ធ។ នៅក្នុងន័យនេះ ធនាគារអភិវឌ្ឍន៍អាស៊ី ក៏ដូចជារដ្ឋាភិបាលផងដែរ អោយតំលៃខ្ពស់បំផុតទៅលើសារៈសំខាន់ចំពោះការបង្កើត *ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម* (MTEF) ដោយផ្អែកលើវិស័យអាទិភាព MTFPs ។ នៅក្នុងន័យនេះ សហប្រតិបត្តិការក្នុងចំណោមដៃគូអភិវឌ្ឍន៍សំខាន់ៗ (ADB-IMF, UNDP, DfID និងរដ្ឋាភិបាលហុល្លង់) នៅក្នុងក្របខ័ណ្ឌនៃ *កម្មវិធីជំនួយសហប្រតិបត្តិការបច្ចេកទេស* (TCAP) គឺជាការបោះមួយជំហានដ៏សំខាន់ទៅមុខ។

មេរៀនពាក់ព័ន្ធនោះគឺការបង្កើតនិងការបង្កអោយមានទំនាក់ទំនងរវាងក្រសួងនិងមន្ទីរ មានសារៈសំខាន់ណាស់សំរាប់ធានាអោយមានភាពជាដៃគូដែលមានប្រសិទ្ធភាព។ ភាពជាដៃគូអន្តរក្រសួងនេះមានសភាពសំខាន់ដូចគ្នា ប្រសិនបើមិនសំខាន់ជាងភាពជាដៃគូរវាងរដ្ឋាភិបាលនិងម្ចាស់ជំនួយទេនោះ។ គេត្រូវការអោយមានយន្តការដែលប្រសិទ្ធភាព ដើម្បីធ្វើយ៉ាងណាអោយក្រសួងនិងមន្ទីរនានាបានយល់ដឹងអំពីកំណែទំរង់គោលនយោបាយ និងអំពីធនធានចាំបាច់សំរាប់អនុវត្ត។ ប្រសិនបើគ្មានការយល់ដឹងបែបនេះទេ នោះនឹងមានគ្រោះថ្នាក់យ៉ាងពិតប្រាកដអំពីការមិនជឿទុកចិត្តគ្នា និងការស្តីបន្ទោសអោយគ្នាទៅវិញទៅមក។

សហគមន៍អន្តរជាតិអាចជួយតាមវិធីមួយចំនួន ។ ឧទាហរណ៍ *គណៈកម្មាធិការគ្រប់គ្រងហិរញ្ញវត្ថុអប់រំ* (EFMC-រួមមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា) អាចជាគំរូមួយ ដែលម្ចាស់ជំនួយបច្ចេកទេសអាចជួយសំរួល។ ការដាក់ចេញនូវការបែងចែកហិរញ្ញវត្ថុតាមវិស័យដែលបានឯកភាពគ្នានិងការបើកផ្តល់អោយមុខសញ្ញា ធ្វើជាផ្នែកនៃយុទ្ធសាស្រ្តតាមដានលទ្ធផលអនុវត្តន៍ គឺជាវិធីមួយបែបទៀត។ ឧទាហរណ៍មួយគឺ កិច្ចព្រមព្រៀងរួមគ្នាជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក DfiD អងការសុខភាពពិភពលោក និងរដ្ឋាភិបាលស្តីពីការបើផ្តល់ PAPនៅក្នុងវិស័យអប់រំ និងសុខាភិបាល។

## ការពង្រីកភាពជាដៃគូ

មុខងារនៃភាពជាដៃគូរបស់វិស័យឯកជននិងក្រុមផ្សេងៗនៅសហគមន៍ នៅមិនទាន់កំណត់អោយបានត្រឹមត្រូវនៅឡើយ ហើយនៅមិនទាន់រីកចំរើនទៅមុខ។ មុខងាររបស់ពួកគេ ក្នុងឋានៈជាដៃគូអាចត្រូវបានកែលំអបន្ថែមទៀតតាមវិធីមួយចំនួន។ ដំបូងចាំបាច់ត្រូវបង្កើតអោយមាននីតិកម្មសំរាប់ការ រៀបចំភាពជាដៃគូ ផ្នែកសាធារណៈ-ឯកជន នៅក្នុងវិស័យមួយចំនួន។ បន្ទាប់មក តំរូវអោយមានការគ្រប់គ្រងកាន់ប្រសើរ និងមានតំលាភាពក្នុងការគ្រប់គ្រងវិភាគទានរបស់ផ្នែកឯកជន ជាពិសេសចំពោះសេវាសង្គមដែលនឹងកំណត់បានកាន់តែប្រសើរ និងទទួលស្គាល់នូវវិភាគទានដ៏មានសារៈសំខាន់របស់ពួកគេ។ ទីបីប្រការនេះអាចភ្ជាប់ជាមួយការពង្រឹងយន្តការអភិបាលកិច្ច និងយន្តការគណនេយ្យភាព ជាពិសេសគឺយន្តការក្នុងការអភិវឌ្ឍន៍ជនបទ សេវាសុខភាព និងសេវាអប់រំ។

ករណីសិក្សានានាដែលបង្ហាញដោយរដ្ឋាភិបាល បានគូសបញ្ជាក់នូវតំរូវការអោយមានគំរូភាពជាដៃគូដែលងាយបត់បែន។ ធនាគារអភិវឌ្ឍន៍អាស៊ីខ្លួនឯងទទួលយកនូវមុខងារងាយបត់បែនធ្វើជាដៃគូមួយនៅក្នុងវិស័យខុសៗគ្នា ដោយផ្តល់នូវការគាំទ្រដញ្ញឹងថវិកា គំរោងវិនិយោគ និងការកសាងសមត្ថភាព ដោយផ្អែកលើការវាយតំលៃតំរូវការ។ គោលការណ៍នេះគប្បីជាការវាយតំលៃស្មោះត្រង់នៃវិធីដ៏ល្អបំផុតដែលម្ចាស់ជំនួយនិមួយៗ និងអង្គការក្រៅរដ្ឋាភិបាល អាចធ្វើសកម្មភាពជាដៃគូ ដោយគិតគូរអំពីឧត្តមភាពធៀបនិងកំរិតនៃភាពបត់បែនរបស់ខ្លួន។ ការកើនឡើងនូវប្រសិទ្ធភាពនៃក្រុមការងារវិស័យផ្លូវការ ផ្តល់នូវវេទិការដ៏ល្អមួយចំពោះមាស់ជំនួយ និងចំពោះអង្គការក្រៅរដ្ឋាភិបាល អោយពិនិត្យមើលសារឡើងវិញអំពីចំណុចខ្លាំងរបស់ខ្លួនក្នុងឋានៈជាដៃគូ។

មេរៀនមួយទៀតពីករណីសិក្សាគឺថា ភាពជាដៃគូដែលមានប្រសិទ្ធភាពត្រូវបានបំរើដោយរដ្ឋាភិបាលដែលកៀងគរក្រុមសម្ព័ន្ធមិត្តជាម្ចាស់ជំនួយ-អង្គការក្រៅរដ្ឋាភិបាល ជាជាងវិធីសាស្ត្រដែលដឹកនាំដោយម្ចាស់ជំនួយ។ វិធីសាស្ត្រក្រោយនេះអាចបណ្តាលអោយមានមាស់ជំនួយដឹកនាំដំណើរការទោលតែឯង ហើយធ្វើអោយខូចនូវរបៀបវារៈគោលនយោបាយដែលដឹកនាំដោយរដ្ឋាភិបាល។ មេរៀនពាក់ព័ន្ធនឹងចំណុចនេះគឺថាដៃគូនានានាំមកនូវចំណុចខ្លាំងខុសៗគ្នា។ ទីភ្នាក់ងារមួយចំនួនមានលទ្ធភាពក្នុងការកៀងគរធនធានអ្នកដទៃទៀតនាំមកនូវចំណេះដឹងជំនាញ និងជំនួយបច្ចេកទេស។ ដៃគូមួយចំនួន (ដូចជា អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល) នាំមកនូវបទពិសោធន៍នៃពលរដ្ឋថ្នាក់ក្រោម និងជំនាញក្នុងការសាកល្បងបង្កើតគោលនយោបាយ។ បញ្ហាប្រឈមគឺ សំរេចអោយបាននូវចំណុចខ្លាំងចំរុះនេះដោយប្រុងប្រយ័ត្ន។

ធនាគារអភិវឌ្ឍន៍អាស៊ីគាំទ្រយ៉ាងខ្លាំងនូវចលនាឆ្ពោះទៅរកដំណើរការពិនិត្យមើលឡើងវិញប្រចាំឆ្នាំរវាងរដ្ឋាភិបាល និងដៃគូរួមជាមួយគ្នា។ យន្តការនេះផ្តល់នូវគ្រឿងលើកទឹកចិត្តចំពោះដៃគូនានាអោយផ្តោតទៅលើលទ្ធផលអនុវត្តន៍ជាជាងទៅលើធាតុចូលនិងសកម្មភាពផ្សេងៗ។ ការពិនិត្យមើលឡើងវិញទាំងនេះក៏ផ្តល់ផងដែរនូវកំលាំងជំរុញក្នុងការពង្រឹងប្រព័ន្ធគ្រប់គ្រងនិងប្រព័ន្ធពត៌មានតាមដាន ហើយជំរុញនូវការផ្លាស់ប្តូរទស្សនៈដោយស្មោះត្រង់និងបើចំហចំពោះវិស័យនិងលទ្ធផលអនុវត្តន៍កម្មវិធី។ ជាងនេះទៅទៀតធនាគារអភិវឌ្ឍន៍អាស៊ី និងម្ចាស់ជំនួយដទៃទៀតកំពុងតែត្រៀមលក្ខណៈដាក់បញ្ចូលនូវបេសកកម្មត្រួតពិនិត្យជាទៀងទាត់ដោយមានការពិនិត្យមើលប្រចាំឆ្នាំសារឡើងវិញ។ ប្រការនេះផ្តល់នូវការផ្តោតមួយច្បាស់លាស់ចំពោះបេសកកម្មបែបនេះនិងកាត់បន្ថយបន្ទុករដ្ឋាភិបាលក្នុងការបំរើនូវទស្សនកិច្ចជាច្រើនដាច់ដោយឡែកពីគ្នានៃម្ចាស់ជំនួយនិងអង្គការក្រៅរដ្ឋាភិបាលនានា។

## ការកសាងសមត្ថភាពជាយុទ្ធសាស្ត្រ

បទពិសោធន៍កាលពីពេលថ្មីៗកន្លងទៅនៃកិច្ចអភិវឌ្ឍន៍ភាពជាដៃគូនៅកម្ពុជា បង្ហាញអោយឃើញនូវសារៈសំខាន់នៃការកសាងសមត្ថភាពជាតិដែលគ្រោងទុកបានល្អ ជាពិសេសគឺសំរាប់កាកសាងផែនការគោលនយោបាយ ផែនការជាយុទ្ធសាស្ត្រ និងការតាមដាន។ សហគមន៍អន្តរជាតិចាំបាច់ត្រូវផ្តល់អាទិភាពក្នុងការពង្រឹងសមត្ថភាពគ្រប់គ្រងជំនួយ ការពិភាក្សាលើគោលនយោបាយ ការវិភាគពត៌មាន និងការផ្សព្វផ្សាយ។ ទស្សនៈរបស់ ធនាគារអភិវឌ្ឍន៍អាស៊ីគឺថា ការកសាងសមត្ថភាពលើការកសាងកុងសង់

ស៊ុស ការជំរុញ និងការពិគ្រោះជាមួយភាគីពាក់ព័ន្ធ នៅជាបញ្ហាដែលមិនទាន់ត្រូវបានយកចិត្តទុកដាក់នៅឡើយ ។ ការផ្តោតកាន់តែខ្លាំងទៅលើផ្នែកទាំងនេះអាចជួយពង្រឹងក្រុមសហគមន៍និងជួយសង្គមស៊ីវិលធ្វើជាដៃគូអភិវឌ្ឍន៍ ។

ធនាគារអភិវឌ្ឍន៍អាស៊ីទទួលស្គាល់ថាខ្លួនចាំបាច់ត្រូវតែពង្រឹងជាបន្តនូវសមត្ថភាពរបស់ខ្លួនផ្ទាល់ក្នុងការធ្វើសកម្មភាពជាដៃគូ ។ ធនាគារអភិវឌ្ឍន៍អាស៊ីត្រូវបានលើកទឹកចិត្តដោយសារមានការកើនឡើងនូវប្រសិទ្ធភាពនៃក្រុមការងាររដ្ឋាភិបាលនិងម្ចាស់ជំនួយ ហើយប្តេជ្ញាដើរតួអោយបានពេញលេញ ។ ចាំបាច់ត្រូវកសាងសមត្ថភាពម្ចាស់ជំនួយនិងអងការក្រៅរដ្ឋាភិបាលតាមទំរង់នានាមួយចំនួន ។ ទីមួយ ក្រុមការងារអាចបង្កើតការងារនិងផែនការសកម្មភាពរបស់ខ្លួន ។ ទីពីរ ចាំបាច់ត្រូវមានការយល់ដឹងនូវភារកិច្ចរវាងការិយាល័យនៅក្នុងប្រទេសនិងទីស្នាក់ការកណ្តាល ។ នៅក្នុងករណីខ្លះ ការិយាល័យនៅមូលដ្ឋានចាំបាច់ត្រូវពង្រឹង ដើម្បីអោយរ៉ាប់រងបាននូវមុខងារពលកម្មច្រើននៃការតាមដានការរីកចំរើននិងការពិភាក្សាដែលដៃគូមួយត្រូវមាន ។ ទីបី ចាំបាច់ត្រូវមានគោលការណ៍ឯកភាពគ្នា និងមានការអនុវត្តន៍ចំពោះការផ្សព្វផ្សាយពត៌មានរវាងរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ធ្វើយ៉ាងណាអោយភាគីពាក់ព័ន្ធទាំងអស់ត្រូវបានជូនដំណឹងដោយពេញលេញ ។

មានការទទួលស្គាល់កាន់តែកើនឡើង ដែលថាភាពជាដៃគូមានការជាប់ពាក់ព័ន្ធជាមួយការប្រកាន់យកនូវទស្សនៈទូលាយនៃការកែទំរង់ ។ ដៃគូដែលមានប្រសិទ្ធភាព ចាំបាច់ត្រូវមានលទ្ធភាពសំលឹងមើលហួសពីវិស័យនិមួយៗ ផលប្រយោជណ៏កម្មវិធីឬផលប្រយោជន៍នៃគំរោងនិមួយៗ ។ ការលើកយកមកពិចារណានូវកំណែទំរង់អភិបាលកិច្ចនិងកំណែទំរង់រដ្ឋបាលមានសារៈសំខាន់ណាស់ចំពោះការអនុវត្តន៍កម្មវិធីអភិវឌ្ឍន៍របស់រដ្ឋាភិបាល ។ ជាការលើកទឹកចិត្តដែលការអភិវឌ្ឍន៍ជនបទ កំណែទំរង់វិស័យអប់រំ និងសុខាភិបាលបានដាក់បញ្ចូលនូវបញ្ហាទាំងនេះ ។ ធនាគារអភិវឌ្ឍន៍អាស៊ីសូមជំរុញយ៉ាងខ្លាំងចំពោះការសាកល្បងកំណែទំរង់រដ្ឋបាលនៅក្នុងការអភិវឌ្ឍន៍តាមវិស័យ (ដូចជា ករណីនេះអប់រំជាដើម) ដើម្បីអភិវឌ្ឍយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលអោយកាន់តែទូលាយបន្ថែមទៀត ។

ធនាគារអភិវឌ្ឍន៍អាស៊ីក៏ជំរុញការសាកល្បងធ្វើវិមជ្ឈការនិងវិសហមជ្ឈការលើមុខងារទីភ្នាក់ងារសេវារួមមានមុខងារច្បាស់លាស់សំរាប់ក្រុមប្រឹក្សាឃុំ-សង្កាត់ដែលជាប់ឆ្នោតថ្មីៗ ។ ក្រុមប្រឹក្សាឃុំ-សង្កាត់តំណាងអោយឱកាសល្អពិតប្រាកដមួយក្នុងការពង្រឹងមុខងាររួមសហគមន៍និងសង្គមស៊ីវិលធ្វើជាដៃគូអភិវឌ្ឍន៍ ។ មានឱកាសជាច្រើនសំរាប់សាកល្បងនូវគំនិតផ្តួចផ្តើមបែបនេះនៅក្នុងការអភិវឌ្ឍន៍ជនបទ

ក៏ដូចជាវិស័យសុខាភិបាល និងវិស័យអប់រំ ។ ម្ចាស់ជំនួយនិងអង្គការក្រៅរដ្ឋាភិបាលអាចជួយក្នុងការកសាងផែនការ ការស្វែងរកប្រភពធនធាន និងការតាមដានការសាកល្បងទាំងនេះធ្វើជាមូលដ្ឋានមួយសំរាប់ការអភិវឌ្ឍន៍យុទ្ធសាស្ត្រអោយកាន់តែទូលាយ ។

ជាចុងបញ្ចប់ ធនាគារអភិវឌ្ឍន៍អាស៊ីជំរុញអោយរដ្ឋាភិបាលនិងដៃគូធ្វើការជាមួយគ្នា ដើម្បីធ្វើអោយមានភាពស៊ីសង្វាក់គ្នានិងអោយមានសនិទានភាពនូវរចនាសម្ព័ន្ធលើកទឹកចិត្ត ។ ការដាក់អោយមានប្រាក់វិភាជន៍ខុសៗគ្នាធ្វើអោយមាននិរន្តរភាពនៃគំរោងស្របគ្នានិងអង្គភាពគ្រប់គ្រងកម្មវិធី ទាក់ទាញបុគ្គលិកសំខាន់ៗចេញពីមុខតំណែងនិងមុខងារសំខាន់ៗ ហើយធ្វើអោយប៉ះពាល់ជាអវិជ្ជមានចំពោះការចាត់តាំងផ្នែកស្ថាប័ននិងអភិវឌ្ឍន៍ការគ្រប់គ្រង ។ ផលវិបាកទាំងនេះគឺធ្វើអោយមានការហូរចេញនូវសមត្ថភាពដោយសារតែរបបផ្តល់ប្រាក់វិភាជន៍ខុសៗគ្នា ។ ធនាគាអភិវឌ្ឍន៍អាស៊ីសូមស្វាគមន៍ក្រុមបេសកកម្មអាទិភាពថ្មីរបស់រដ្ឋាភិបាលថាជាជំហានដំបូងនៅក្នុងការដោះស្រាយបញ្ហានេះ ។ ធនាគាអភិវឌ្ឍន៍អាស៊ីត្រៀមលក្ខណៈជាស្រេចក្នុងការធ្វើកិច្ចការជាចំណែករបស់ខ្លួនក្នុងការជួយសំរួលការរៀបចំភាពជាដៃគូឱ្យកាន់តែរឹងមាំ ដើម្បីជួយរដ្ឋាភិបាលក្នុងការអនុវត្តន៏នូវសក្តានុពលពេញលេញនៃលំនាំភាពជាដៃគូថ្មី ។

# សៀវភៅបោះផ្សាយថ្មីៗរបស់ធនាគារអភិវឌ្ឍន៍អាស៊ី

២០០២

- ទស្សនវិស័យអភិវឌ្ឍន៍អាស៊ី
- ការកសាងសម្ព័ន្ធភាពដើម្បីអោយមានតំលាភាពនៅកម្ពុជា : ឯកសារសន្និសីទ ដែលរៀបចំរួមគ្នាជាមួយមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម

២០០១

- របាយការណ៍ប្រចាំឆ្នាំរបស់ធនាគាអភិវឌ្ឍន៍អាស៊ី
- ចក្ខុវិស័យនៃការអភិវឌ្ឍន៏វិស័យហិរញ្ញវត្ថុកម្ពុជា ២០០១-២០១០
- ពត៌ថ្មី៧ស្តីពីយុទ្ធសាស្ត្រនិងកម្មវិធីរបស់ធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំកម្ពុជា
- គំរូវការផ្នែកសុខាភិបាលនិងអប់រំនៃជនជាតិភាគតិចនៅមហាតំបន់អនុមេគង្គ
- ការវាយតំលៃដែលមានការចូលរួមនៅកម្ពុជា
- ស្ត្រីនិងការជំរុញការអភិវឌ្ឍន៏មីក្រូសហគ្រាសនិងសហគ្រាសខ្នាតតូចៈ ឯកសារសិក្ខាសាលាដែលរៀបចំរួមគ្នាជាមួយក្រសួងកិច្ចការនារីនិងអតីតយុទ្ធជន
- បញ្ហាអភិបាលកិច្ចគន្លឹះនៅកម្ពុជា សាធារណៈរដ្ឋប្រជាមានិតុប្រជាធិបតេយ្យឡាវ ថៃ និង វៀតណាម
- បរិស្ថានស្ថិតក្នុងអន្តរកាលនៅកម្ពុជា សាធារណៈរដ្ឋប្រជាមានិតុប្រជាធិបតេយ្យឡាវ ថៃ និង វៀតណាម

២០០០

- ការពង្រឹងអភិបាលកិច្ចដើម្បីអភិវឌ្ឍន៍ដោយនិរន្តរភាពនៅកម្ពុជា
  រៀបចំដោយវិទ្យាស្ថានបណ្តុះ បណ្តាលដើម្បីអភិវឌ្ឍន៍កម្ពុជាសំរាប់ធនាគារអភិវឌ្ឍន៏អាស៊ី
- យុទ្ធសាស្ត្ររបស់ធនាគារអភិវឌ្ឍន៏អាស៊ីចំពោះប្រតិបត្តិការសំរាប់កម្ពុជាៈ
  ការបង្កើតអោយមាន កំណើតឡើងវិញនៃផ្នែកសេដ្ឋកិច្ច សង្គមកិច្ច